ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ហេតុអ្វីបានជាតុលាការខ្មែរក្រហមសំខាន់សម្រាប់សង្គមកម្ពុជា?
- ពីអំពើហិង្សាទៅរកការទទួលខុសត្រូវ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៩៣ ខែកញ្ញា ឆ្នាំ២០០៧

**ស្វែងរកការពិត**

លេខ៩៣ ខែកញ្ញា ឆ្នាំ២០០៧

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រៈ ហេតុអ្វីបានជាតុលាការខ្មែរក្រហមសំខាន់សម្រាប់សង្គមកម្ពុជា...១

**ផ្នែកឯកសារ**

◆ ឡុង មុយ ហៅ ដួន ៖ មេក្រុមបកប្រែភាសាខ្មែរ-ចិន......................៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ..............................................៨

◆ គុកខ្មែរក្រហម.......................................................................១៣

◆ ពីអំពើហិង្សាទៅរកការទទួលខុសត្រូវ .......................................១៩

◆ សេចក្តីស្រលាញ់និងអាពាហ៍ពិពាហ៍.........................................២៥

**ផ្នែកច្បាប់**

◆ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា.................................២៨

◆ សេចក្តីជូនដំណឹងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ......៣៩

◆ ស្វែងយល់អំពីសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះ .................៤០

**វេទិកាពិភាក្សាសាធារណៈ**

◆ ការបង្កើតឲ្យមានការចងចាំ....................................................៤៧

◆ ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ ...................................៤៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការលំបាកដែលខ្ញុំបានជួប ....................................................៥៤



ប្រជាជនកំពុងចូលទស្សនាគុកនៃមន្ទីរស-២១



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** អេង កុកថាយ, ផេង ពង្សរ៉ាស៊ី, ឌី ខាំបូលី, ប៊ីជូ ម៉ុនយ៉ាស, លី សុខឃាង, ដេវីដ សេហ៊ុរ, មេយ៉រ, ជ្រោន, រ៉ូវ៉េ និងរ៉ូប៊ឺត ហេលមិន វ៉ាន់ថាន់ ពៅដារ៉ា, អេតែល ហ៊ីហ្គូនេត, ភី ប៊ុនថាន់ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ ៖** ព្រំ ផល្លា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** លី សុផល **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន តារាវពិដោរ

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ហេតុអ្វីបានជាតុលាការខ្មែរក្រហមសំខាន់សម្រាប់សង្គមកម្ពុជា? យុត្តិធម៌សម្រាប់ពេលអនាគត មិនមែនសម្រាប់ជនរងគ្រោះ

ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅកាន់ទីជនបទ ។ មានថ្ងៃមួយខ្មែរក្រហមបានចាប់ខ្លួនបងថ្លៃខ្ញុំពីបទលួចអង្ករពីរោងបាយសហករណ៍ ហើយវាយគាត់រហូតស្លាប់ ។ នៅពេលក្រោយមកក្នុងយប់នោះ ប្រពន្ធរបស់គាត់ (បងស្រីខ្ញុំ) ក៏ឈឺពោះ ហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យខ្មែរក្រហម ។ នៅទីនោះ ខ្មែរក្រហមបាននិយាយថា បងស្រីខ្ញុំថាគាត់ឈឺដោយសារតែគាត់ហូបបាយដែលដាំពីអង្ករលួចមកនោះ ដូច្នេះត្រូវវះពោះរបស់គាត់ដើម្បីរកការពិត ។ បងស្រីខ្ញុំក៏ត្រូវស្លាប់ដូចគ្នា ។

៣០ឆ្នាំក្រោយមក ក្រុមគ្រួសារខ្ញុំគាំទ្រការដាក់ឲ្យមានការកាត់ទោសខ្មែរក្រហមដែលអាចផ្តល់យុត្តិធម៌សម្រាប់ការស្លាប់របស់បងស្រីខ្ញុំ ។ ក្រោយរបបប៉ុលពត ប្រធានភូមិនៅកន្លែងដែលសមាជិកគ្រួសារខ្ញុំមួយចំនួនបានបាត់ខ្លួនបាននាំគ្នាជិះកង់មកភ្នំពេញដើម្បីសុំទោសគ្រួសារខ្ញុំដោយមានចេកនិងសាច់ជាការគបស្នង ។ នៅក្នុងក្រុមគ្រួសារ គ្មាននរណាម្នាក់ទទួលការសុំទោសពីប្រធានភូមិម្នាក់នេះទេ លើកលែងតែម្តាយរបស់ខ្ញុំដែលនិយាយថាប៉ុណ្ណឹងគ្រប់គ្រាន់ហើយ ។ ឥរិយាបថម្តាយខ្ញុំគឺពិតជាអ្នកកាន់ពុទ្ធសាសនាម្នាក់ ហើយប្រធានភូមិក៏បានស្ងប់ចិត្ត ។ ម្តាយខ្ញុំមិនដែលចង់ឲ្យខ្ញុំត្រឡប់មកប្រទេសកម្ពុជានិងធ្វើការទាក់ទងនឹងច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យទេ ហើយគាត់ក៏មិនយល់ថាហេតុអ្វីបានជាខ្ញុំមិនរស់នៅសហរដ្ឋអាមេរិកទៅ ។ កន្លងមក ម្តាយខ្ញុំធ្លាប់ជឿជាក់ថាមានតុលាការគឺជារឿងល្អ ហើយវានឹងមានប្រសិទ្ធភាពបើមានការគាំទ្រពីសហគមន៍អន្តរជាតិ ។

ក្មួយស្រីធារីរបស់ខ្ញុំយល់ឃើញមួយផ្សេងទៀត ។ នាងអាយុបាន៥ឬ៦ឆ្នាំនៅពេលដែលឪពុកម្តាយស្លាប់ ហើយនាងបានរស់នៅសហរដ្ឋអាមេរិកស្ទើរតែមួយជីវិត ។ មានម្តងនោះក្មួយស្រីខ្ញុំបានសរសេរមកខ្ញុំដោយនិយាយថា ខ្ញុំមិនជឿថាយុត្តិធម៌ត្រូវផ្តល់គ្រប់គ្រាន់សម្រាប់អ្វីដែលបានកើតមានចំពោះគ្រួសាររបស់ខ្ញុំទេ ។ គ្មានយុត្តិធម៌ណានៅក្នុងពិភពលោកដែលអាចសងគ្រួសារមកខ្ញុំវិញឡើយ ។ ក្មួយស្រីខ្ញុំមិនដែលចង់ត្រឡប់មកកម្ពុជា ឬក៏មកសួរសុខទុក្ខក្រុមគ្រួសារដែលមានជីវិតរស់នៅក្នុងប្រទេសកម្ពុជាទេ ដោយមានជំនឿថាការពិត កម្ពុជាបច្ចុប្បន្នគ្រាន់តែជារូបភាពបំភ័ន្តភ្នែកប៉ុណ្ណោះ ។

ខ្ញុំយល់ឃើញខុសពីនេះ តុលាការមានសារសំខាន់ ហើយយើងត្រូវការការកាត់សេចក្តីនៅមុនពេលដែលយើងអាចឈានទៅដល់ចំណុចនៃការលើកលែងពិតប្រាកដ ។ យុត្តិធម៌ទទួលបានរួចជាស្រេចសម្រាប់កម្រិតមួយចំនួនៈ វាត្រូវបានបែងចែកកម្រិតតាមតំបន់នៅក្នុងឆ្នាំ១៩៨០ នៅពេលដែលប្រជាជនបានកាន់កាប់ច្បាប់ដោយផ្ទាល់ដៃ ហើយបានសម្លាប់ខ្មែរក្រហមដែលធ្លាប់ប្រព្រឹត្តបទឧក្រិដ្ឋឃោរឃៅជាច្រើននាក់ ។ ដោយហេតុផលនេះខ្ញុំយល់ថា ការកាត់ទោស (ប្រសិនបើជោគជ័យ) និងមិនផ្តល់យុត្តិធម៌ធំដុំដល់ជនរងគ្រោះទេ ព្រោះវាគ្រាន់តែផ្តល់គំនិតមួយដល់ប្រជាជនថា យុត្តិធម៌អាចមាននៅពេលអនាគត ។

ក្រុមគ្រួសារកម្ពុជាទាំងក្នុងស្រុកនិងនៅបរទេសក៏បានគាំទ្រលើការកាត់ទោសដែរ ។ នេះពីព្រោះតែអំពើប្រល័យពូជសាសន៍គឺជាសកម្មភាពនយោបាយ ហើយនឹងនៅតែបែបនេះ ។ ក្រោយរយៈពេល៣០ឆ្នាំ ប្រជាជនមិនបានគិតទៅលើការសងសឹកផ្ទាល់ខ្លួនឡើយ ។ ប្រជាជនខ្វាយខ្វល់តែអំពីថាតើការកាត់ទោសអាចនឹងមានឥទ្ធិពលដល់អនាគតនិងប្រទេសរបស់ខ្លួនយ៉ាងដូចម្តេច? ប៉ុន្តែប្រជាជនយល់ឃើញយុត្តិធម៌ចេញពីទស្សនៈនយោបាយផ្សេងៗគ្នា ។

## ប្រជាជនរស់រានជីវិតក្នុងប្រទេសកម្ពុជា

ប្រជាជនដែលរស់រានមានជីវិតមាន២ក្រុម ។ ទីមួយគឺអ្នកដែលនៅរស់ ហើយគាំទ្រតុលាការ ។ អ្នកភាគច្រើននៅក្រុមនេះមិនដែលបានចាកចេញទៅក្រៅប្រទេសទេ ហើយបានធ្វើការ

សម្រេចថាយ៉ាងហោចណាស់អនាគតរបស់គាត់សម្រេចទៅលើការគ្រប់គ្រងរបស់គណបក្សប្រជាជនកម្ពុជាដែលប្រជាជនយល់ថាជាអ្នកដែលបានរំដោះប្រទេសកម្ពុជាពីរបបខ្មែរក្រហម ហើយបានធ្វើការវាយប្រយុទ្ធបណ្តេញកងទ័ពខ្មែរក្រហមក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ខណៈពេលដែលគ្មានការអើពើពីសំណាក់សហគមន៍អន្តរជាតិមកលើប្រទេសកម្ពុជា ។ ជាភ័ស្តុតាងនៃការតាំងចិត្តរបស់ក្រុមនេះដើម្បីរៀបចំតុលាការប្រកបដោយលក្ខណៈយុត្តិធម៌ អ្នកទាំងនោះបានចង្អុលបង្ហាញមន្ត្រីនៅក្នុងរដ្ឋាភិបាលដែលជាអតីតខ្មែរក្រហម និងបានថ្លែងជាសាធារណៈពីការស្ម័គ្រចិត្តរបស់ខ្លួនដើម្បីបង្ហាញខ្លួននៅមុខតុលាការ ។ ក្រុមនេះក៏បានសម្គាល់ពីអសមត្ថភាពរបស់អង្គការសហប្រជាជាតិក្នុងការនាំខ្មែរក្រហមទៅកាន់ហិបឆ្នោតនៅក្នុងការបោះឆ្នោតជាតិឆ្នាំ១៩៩៣ ដូច្នេះហើយទើបមិនអាចបង្កើតនីតិរដ្ឋនៅប្រទេសកម្ពុជាបាន ។ ក្រុមនេះមិនជឿជាក់លើសហគមន៍អន្តរជាតិទេ ហើយយល់ថាអង្គការសហប្រជាជាតិក៏មានកំហុសមួយផ្នែកសម្រាប់វប្បធម៌និទ្ទណ្ឌភាពរបស់ប្រទេសកម្ពុជាដែរ ។ ក្រុមទី២គឺទាក់ទងនឹងប្រជាជនជាច្រើនដែលបានធ្វើមាតុភូមិនិវត្តន៍ពីព្រំដែនថៃនៅទសវត្សរ៍ឆ្នាំ១៩៩០ ។ ក្រុមនេះតែងតែប្រឆាំងរដ្ឋាភិបាល ហើយជឿថាបញ្ហាជាតិដូចជាភាពក្រីក្រនិងអំពើពុករលួយគឺមានទំនាក់ទំនងដោយផ្ទាល់នឹងគណបក្សប្រជាជនកម្ពុជា ។ ក្រុមនេះយល់ថាតុលាការនេះគ្រាន់តែធ្វើការដើម្បីលុបលាងរូបភាពគ្រប់គ្រងរបស់គណបក្សនេះប៉ុណ្ណោះ ។ ដូច្នេះក្រុមនេះកំពុងតែស្នើសុំឲ្យមានការគ្រប់គ្រងបន្ថែមពីអន្តរជាតិទៅលើដំណើរការនេះ និងចង់ឃើញមន្ត្រីដែលជាអតីតខ្មែរក្រហមត្រូវបាននាំខ្លួនទៅវិនិច្ឆ័យទោសព្រមទាំងសង្ឃឹមថារដ្ឋាភិបាលបច្ចុប្បន្ននឹងចូលរួមដោះស្រាយដែរ ។

## ជនភៀសខ្លួនកម្ពុជា

ក្រុមមាននិន្នាការនយោបាយខ្លាំងក៏មានធ្វើការបែងចែកដែរ ។ បក្សមួយដែលគាំទ្ររដ្ឋាភិបាលបានបញ្ចេញសំឡេងនៅក្នុងការគាំទ្ររបស់ខ្លួនចំពោះតុលាការ ។ មនុស្សមួយចំនួនក្នុងចំណោមនោះបានវិលត្រឡប់មកកម្ពុជានិងបានចូលរួមនៅក្នុងបញ្ហាតុលាការ ព្រមទាំងសង្ឃឹមថា ជាឱកាសបង្កើនសេដ្ឋកិច្ចរបស់ខ្លួនតាមរយៈការគាំទ្រពីគណបក្សកំពុងកាន់អំណាច ។

ក្រុមបីផ្សេងទៀតប្រឆាំងនឹងតុលាការ ។ ក្រុមទីមួយរួមបញ្ចូលទាំងអ្នកគាំទ្ររបស់អតីតព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហនុ ដែលបារម្ភថា ព្រះអង្គនឹងអាចត្រូវបាននាំខ្លួនទៅកាត់ទោសនៅមុខតុលាការ (ក៏មានអ្នកគាំទ្រដូចនេះក្នុងចំណោមអ្នកដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាដូចគ្នា) ។ ដូចជាព្រះមហាក្សត្រ ក្រុមនេះប្រកែកថាលុយដែលផ្តល់ឲ្យតុលាការគួរតែចំណាយលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាវិញប្រសើរជាង ។ ក្រុមទីពីរគឺជាការសម្រេចរបស់ប្រជាជនដែលប្រឆាំងនឹងគណបក្សកាន់អំណាចហេតុផលនយោបាយ ។ អ្នកមួយចំនួនអាចទទួលបានទិដ្ឋាការទៅកាន់ប្រទេសទី៣ក្រោយការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យដោយទទួលយកជំហរប្រឆាំងបក្សកុម្មុយនីស្តដែលខ្លួនប្រកាន់យករហូតដល់សព្វថ្ងៃ (អំឡុងទសវត្សរ៍ឆ្នាំ១៩៨០គណបក្សប្រជាជនកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគណបក្សកាន់អំណាចកុម្មុយនីស្តវៀតណាម) ។ ជាចុងក្រោយគឺ ជនភៀសខ្លួនមួយក្រុមតូចដែលធ្លាប់ជាខ្មែរក្រហម ។ អ្នកទាំងនេះជាធម្មតាភ័យខ្លាចជីវិតអតីតកាលរបស់ខ្លួនអាចនឹងត្រូវបានលាតត្រដាង ។

## អ្នកជំនាន់ក្រោយ

នៅខណៈពេលដែលអ្នកទាំងនេះមិនមែនជាអ្នកនយោបាយ កូនៗរបស់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យគឺជាពន្លកនៃប្រជាជនថ្មី ហើយការជឿជាក់និងក្តីសង្ឃឹមរបស់ក្មេងៗទាំងនោះត្រូវបានយកមកគិតគូរ ។ ក្រុមនេះមានទំនាក់ទំនងជិតស្និទ្ធនិងជាអ្នកជាតិនិយម ។ ភាគច្រើននៃអ្នកទាំងនេះយល់ថា វាពិបាកជឿថាប្រជាជនកម្ពុជាអាចសម្លាប់គ្នាឯងបាន ដូច្នេះហើយអ្នកទាំងនេះយល់ថា ជនបរទេសជាអ្នកបង្កឲ្យមានអំពើប្រល័យពូជសាសន៍នៅប្រទេសរបស់ខ្លួន ។ មួយចំនួនទៀតចង់សិក្សាពីអ្វីដែលបានកើតឡើង ប៉ុន្តែមិនមានអ្វីដែលជាវគ្គសិក្សាដូចជាវារៈនយោយបាយមួយទេ ។ អ្នកផ្សេងទៀតចាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ ដោយមើលទៅរបបប្រល័យពូជសាសន៍នៅក្នុងលក្ខខណ្ឌខ្មៅនិងស ៖ ខ្មែរក្រហមតែងតែអាក្រក់ ហើយនឹងនៅតែដូច្នេះ ។ ទោះបីជាយ៉ាងណាក៏ដោយក្រុមទាំងពីរហាក់ដូចជាប្រសើរច្រើន ដែលអាចធ្វើការសន្ទនាជាមួយគ្នាជាង

ក្មេងជំទង់ដែលនៅរស់ ។

**ឱកាសសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ប្រហែលជាសំណួរដែលសំខាន់បំផុតចំពោះតុលាការគឺទាំងរដ្ឋាភិបាលរបស់កម្ពុជានិងអង្គការសហប្រជាជាតិដែលភាគីទាំងពីរបានគាំទ្រខ្មែរក្រហមពីអតីតកាល («រដ្ឋាភិបាលផ្តល់នូវការលើកលែងទោសដោយទទួលមកវិញនូវសន្តិភាពនៅអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ និងអង្គការសហប្រជាជាតិអនុញ្ញាតឲ្យខ្មែរក្រហមកាន់កាប់កៅអីនៅអង្គការសហប្រជាជាតិអស់រយៈពេល១០ឆ្នាំ») អាចរកដំណោះស្រាយដែលជួយក្រុមនីមួយៗរកក្តីសង្ឃឹមសម្រាប់អនាគតតាមរយៈតុលាការ ។

ទាំងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិមានការជជែកចំពោះទង្វើដែលភាគីទាំងពីរបានប្រព្រឹត្ត ប៉ុន្តែនៅក្នុងក្រសែភ្នែករបស់ជនរងគ្រោះនិងប្រជាជនកម្ពុជាក្រោមអាយុ២៥ឆ្នាំ ភាគីទាំងពីរមានរឿងរ៉ាវច្រើនដើម្បីធ្វើការពន្យល់ ។ ជាការចម្លែកវត្តមានតុលាការជាឱកាសដ៏ល្អសម្រាប់ភាគីទាំងពីរដើម្បីទទួលបានការជឿជាក់និងការគោរពនៅប្រទេសកម្ពុជា ។ ប្រសិនបើរដ្ឋាភិបាលប្រកាសឲ្យដឹងជាសាធារណៈនិងត្រឹមត្រូវ ហើយលទ្ធផលការជឿជាក់ជាសាធារណៈអាចឲ្យខ្លួនបន្តឆ្ពោះទៅមុខជាមួយនឹងគោលនយោបាយរបស់រដ្ឋាភិបាល ។ សកម្មភាពស្រដៀងគ្នារបស់អង្គការសហប្រជាជាតិអាចបង្កើតប្រជាប្រិយភាពនិងការគាំទ្ររបស់រដ្ឋាភិបាលចំពោះសកម្មភាពរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ។ ដូចជា ជ័យជម្នះដែលអាចមើលឃើញនឹងអនុញ្ញាតឲ្យមានការរៀបចំបន្ថែម ការធ្វើអន្តរាគមន៍ ឬការកាត់ទោសអំពើប្រល័យពូជសាសន៍នៅកន្លែងផ្សេងទៀតនៅក្នុងពិភពលោក ។ វិធីសំខាន់មួយដែលអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជាទទួលបានការជឿជាក់ពីប្រជាជនគឺតាមរយៈទំនាក់ទំនងជាសាធារណៈក្នុងភាពត្រឹមត្រូវនិងផ្តល់ឱកាសឲ្យស្មើៗគ្នា ។ ការពេញចិត្តឬមិនពេញចិត្តលទ្ធផលរបស់ក្រុមផ្សេងៗគ្នានេះ វាមិនសំខាន់ជាងបញ្ហារបស់ខ្លួនត្រូវបានយកមកគិតគូរមុនគេនោះទេ ។

ឧទាហរណ៍ នៅពេលព្រះមហាក្សត្រស្នើសុំឲ្យភាគីអង្គការសហប្រជាជាតិមកពិភាក្សាជាមួយព្រះអង្គ អ្នកទាំងនោះគួរតែទៅ ។ អ្នករាជានិយមអាចត្រូវបានលើកទឹកចិត្តនិងអ្នកផ្សេងទៀតនឹងអាចយល់រឿងទាំងអស់ដែលកំពុងតែលេចឮ ។ ទោះបីជាយ៉ាងណា ការឆ្លើយតបរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវាគួរតែបើកចំហជាសាធារណៈទើបកម្ពុជាបានទទួលនូវយុត្តិធម៌មួយពិតប្រាកដ ។

វាជាការសំខាន់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តល់ចម្លើយមួយចំនួនទៅឲ្យក្រុមទាំងនេះអំពីមូលហេតុនិងអ្នកដែលត្រូវទទួលខុសត្រូវ ។ តុលាការនឹងទុកឲ្យប្រជាជនវិនិច្ឆ័យអ្វីដែលពិតប្រាកដដែលខ្លួនអាចទទួលយកនិងធ្វើការពិភាក្សានិងអ្វីដែលអ្នកទាំងនេះយល់ថាយុត្តិធម៌សម្រាប់ទាំងអស់គ្នា ។ ជាចុងក្រោយសម្រាប់ប្រជាជនគឺថា ការកាត់សេចក្តីនឹងត្រូវធ្វើឡើង ។ **ឆាំង យុ**

# ឡុង មុយ ហៅ ជួន : មេក្រុមបកប្រែភាសាខ្មែរ-ចិន នៅមន្ទីរ ក-១៦

ឡុង មុយ បានបម្រើបដិវត្តន៍តាំងពីទសវត្សរ៍ឆ្នាំ១៩៧០ ។ នៅក្នុងឆ្នាំ១៩៧៧ ឈ្មោះនេះត្រូវបានចាប់ខ្លួននិងបញ្ជូនមកគុកទួលស្លែងដើម្បីសួរចម្លើយពីបទចោទប្រកាន់ថាជាសេ.អ៊ី.អានិងជាជនក្បត់ដោយបានបម្រើឲ្យបក្សកុកម៉េងតាំង ។ ក៏ប៉ុន្តែចាប់ពីចុងឆ្នាំ១៩៧៦ គ្មានសាច់ញាតិណាម្នាក់បានដឹងពីជោគវាសនារបស់ មុយ ថាយ៉ាងណានោះទេ ។ នៅពេលថ្មីៗនេះ មុយ ត្រូវបានសាច់ញាតិនិងមិត្តភក្តិរកឃើញនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ។

**អំពីចម្លើយសារភាព**

ឡុង មុយ ហៅ ជួន (ឈ្មោះបដិវត្តន៍) កើតនៅថ្ងៃទី២១ កញ្ញា ឆ្នាំ១៩៤៨នៅភូមិស្វាយពល់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ។ មុយ មានតួនាទីមេក្រុមបកប្រែភាសាចិននៅមន្ទីរក-១៦នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឪពុករបស់ មុយ បានភៀសខ្លួនមកប្រទេសកម្ពុជាតាំងពីអាយុ១៨-១៩ឆ្នាំដើម្បីគេចពីបក្សកុម្មុយនីស្តចិន ។ មុនមកដល់ប្រទេសកម្ពុជាឪពុករបស់ មុយ គឺជាសមាជិកបក្សកុកម៉េងតាំង ។ នៅក្នុងចម្លើយសារភាព មុយ បាន

និយាយលម្អិតច្រើនអំពីសកម្មភាពកុកម៉ីងតាំងក្នុងការប្រឆាំងជាមួយនឹងខ្មែរក្រហម ។ កុកម៉ីងតាំងបានកកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ មុយ នៅស្រុកពារាំង ខេត្តព្រៃវែង ជាទីកន្លែងដែលមានអណិកជនចិនរស់នៅច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ក្រោមការដឹកនាំរបស់ តែ ហេងគ្រី ហៅ លី ជៀល ក្នុងគោលនយោបាយប្រឆាំងនឹងបក្សកុម្មុយនីស្តនិងគាំទ្ររបបសេរីដែលដឹកនាំដោយ ជាង កាយជៀក (មេដឹកនាំបក្សកុកម៉ីងតាំងប្រឆាំងនឹងលទ្ធិកុម្មុយនីស្តចិន) ។ នៅក្នុងឆ្នាំ១៩៥៧ ប្រធានបក្សនេះបានបើកអង្គប្រជុំជ្រើសរើសគ្រូនៅក្នុងសាលារៀនចិនស្វាយពល់ណាដែលមានគោលជំហរកុកម៉ីងតាំងដើម្បីមកបង្រៀនកម្មវិធីសិក្សានៅក្នុងសៀវភៅដែលបោះពុម្ពនៅប្រទេសតៃវ៉ាន់និងសិង្ហបុរី ។ នៅតាមសាលារៀនមានដាក់ទង់ជាតិសញ្ញាកុកម៉ីងតាំង ដើម្បីជាការសម្តែងភាពស្មោះត្រង់របស់ខ្លួនចំពោះបក្សនេះនិងពាក្យស្លោកផ្សេងៗដែលប្រឆាំងនឹងខ្មែរក្រហមទៀតផង ។ មុយ ដែលកាលនោះទទួលភារកិច្ចក្តាប់អណិកជនចិនឃុំព្រៃញ្ញៅនិងយុវជនដែលជាកូនសមាជិកកុកម៉ីងតាំងនៅភូមិស្វាយពល់ ហើយបានដឹកនាំយុវជនដែលជាកូនរបស់សមាជិកកុកម៉ីងតាំងចូលរួមធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ទៀតផង ។ នៅពេលបានមកធ្វើការនៅភ្នំពេញ មុយ មានទំនាក់ទំនងជាមួយ យ៉ាន់ ផេង ហើយ ផេង បានមកបញ្ចុះបញ្ចូល មុយ ចូលរួមបដិវត្តន៍នៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៦៩ ដោយទទួលភារកិច្ចបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ឲ្យបានជ្រៅដើម្បីស៊ីរូងផ្ទៃក្នុងនិងទាក់ទងខ្សែក្បត់ ។ ក្រោយពេលរដ្ឋប្រហារបានមួយខែ សាលារៀនចិនត្រូវបានបិទទ្វារដោយសារសិស្សត្រូវបានចោទថាសុទ្ធតែមានគំនិតម៉ៅនិយម ។ ស៊ីផេង បានបញ្ជូន មុយ ឲ្យទៅធ្វើការជាមួយគណៈស្រុកពារាំងឈ្មោះ កែវ វ៉ាន់ ។ បានរយៈពេល១០ថ្ងៃ កែវ វ៉ាន់ ក៏បានបញ្ជូន មុយ ទៅប្រចាំការនៅតំបន់២២រហូតដល់ពាក់កណ្តាលខែតុលា ទុំ ក៏បានចាត់តាំងឲ្យទៅបំពេញភារកិច្ចនៅស្រុកកងមាសរយៈពេលជិតបីខែទៀតមុនពេលផ្លាស់ទៅធ្វើជាប្រធានមន្ទីរសិល្បៈតំបន់២២ ។ ដោយសារមានទំនាស់គ្នាជាមួយប្រធាននៅទីនោះ មុយ ក៏បានសុំផ្លាស់ទៅបម្រើការងារនៅក្រសួងវប្បធម៌នៅឯស្រុកកំណើតវិញរហូតដល់ថ្ងៃរំដោះទូទាំងប្រទេស ។ មុយ បានភ្ជាប់ទំនាក់ទំនងជាមួយសមាជិកបក្សកុកម៉ីងតាំងវិញ ហើយទទួលភារកិច្ចដឹកនាំសមាជិកចាស់ៗនិងក្តាប់អណិកជនចិននៅឃុំព្រែកញ្ញៅ ។ ក្រោយពីខិតខំធ្វើការងារដើម្បីឲ្យអ្នកនៅជុំវិញខ្លួនពេញចិត្ត មុយ បានអប់រំយុវជនកុកម៉ីងតាំងអំពីការដឹកនាំផ្តាច់ការអំពីបក្សកុម្មុយនីស្ត និងឲ្យខិតខំដឹកជញ្ជូនស្បៀង ដូចជា ស្រូវ អង្ករទៅតំបន់ខ្លាំង ។ ដោយមើលឃើញ មុយ សកម្មការងារ ចិន សេង និង យូ លឹម បានចាត់តាំងឲ្យធ្វើជាជំនួយការរបស់ក្រសួងវប្បធម៌និងបញ្ចូលជាសមាជិកសេ.អ៊ី.អា នៅខែឧសភា ឆ្នាំ១៩៧៣ ។ នៅពេលនោះហើយ ដែល មុយ មានលទ្ធភាពចុះទៅមូលដ្ឋានដើម្បីឃោសនាប្រឆាំងនឹងអង្គការ ។ មុយ និង ឈួន បានដឹកនាំកូនរបស់កុកម៉ីងតាំងធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ដឹកទំនិញទៅតំបន់ខ្លាំងនិងធ្វើសកម្មភាពប្រឆាំងផ្សេងៗដូចជាបានអូសទាញកម្លាំងជាសមាជិកសេ.អ៊ី.អា បានកាន់តែច្រើន ។



ឡុង មុយ

នៅក្នុងឆ្នាំដដែលនេះ មុយ និងសមាជិកជាច្រើនបានចូលរួមប្រជុំនិងទទួលផែនការពីប្រធានបក្សកុកម៉េងតាំង ដេញថ្លៃទិញស្រូវពីប្រជាជនក្នុងតម្លៃខ្ពស់ជាងពួកកុម្មុយនីស្ដដើម្បីទុកលក់នៅថ្ងៃខាងមុខ ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៤ មុយ និងមិត្តភក្ដិបានអូសទាញកម្លាំងបួននាក់បញ្ចូលជាសមាជិក សេ.អ៊ី.អា ហើយបន្ទាប់មកដាក់ផែនការឲ្យសមាជិកថ្មីធ្វើនិងបានចុះធ្វើសកម្មភាពផ្ទាល់ដូចជាគប់គ្រាប់បែបចូលទៅក្នុងស្រះទឹក ដាន់ពន្លិចទូកចូលទៅក្នុងទន្លេ ស្រាយមងនិងកាប់បំផ្លាញចោល ។ នៅក្នុងឆ្នាំ១៩៧៥ មុយ បានណែនាំឲ្យសមាជិកនៅក្នុងក្រសួងវប្បធម៌ធ្វើវិច្ឆេទកម្មខាងសេដ្ឋកិច្ចមុនពេលអង្គការចូលរួមជាសហករណ៍ភូមិ និងបានដឹកនាំកម្លាំងទៅកាប់បំផ្លាញទំនប់ទឹកដែលទើបជីកថ្មីបង្ហូរទឹកចូលស្រូវ ។

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៥ ទុំ បានណែនាំឲ្យ មុយ មកធ្វើជាអ្នកបកប្រែភាសាចិននៅមន្ទីរក-១៦នៅភ្នំពេញ ។ ការងារបកប្រែមមាញឹកខ្លាំង មុយ បានទៅស្នើសុំមនុស្សម្នាក់ពីតំបន់២២ដើម្បីមកជួយ ។ នៅក្នុងមន្ទីរក-១៦ មុយ បានអនុវត្តផែនការមួយចំនួនដូចជា បំបែកសាមគ្គីភាពកម្ពុជា-ចិន បន្ទុះបន្ថប់តម្លៃបក្សកុម្មុយនីស្ដក្នុងការថែរក្សាសម្បត្តិរដ្ឋ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិរដ្ឋ បង្កទំនាស់ក្នុងគណៈមន្ទីរនិងរវាងពីក្រុមមួយទៅក្រុមមួយនិងអូសទាញកម្លាំងបានបីនាក់ឲ្យចូលសេ.អ៊ី.អា ។ មុយ បានធ្វើសកម្មភាពប្រឆាំងរហូតដល់ថ្ងៃចាប់ខ្លួន ។ សូមបញ្ជាក់ថានៅក្នុងបញ្ជីឈ្មោះរបស់មន្ទីរស-២១ បានកត់ត្រាថា «ឡុង មុយ ហៅដួន ជាមេក្រុមមន្ទីរក-១៦ តួនាទីសេនាធិកា ។ ចាប់ខ្លួននៅថ្ងៃទី១៦-៧-៧៧ ។ កម្ទេចចោលថ្ងៃទី២៣-១០-១៩៧៧» ។

## អំពីការសិក្សានិងការងារមុនពេលបាត់ខ្លួន

នៅក្នុងគ្រួសារមធ្យមមួយ មុយ ជាកូនទី២នៅក្នុងចំណោមបងប្អូន៩នាក់ដែលមានឪពុកជាជនជាតិចិន ឈ្មោះ លីវ ហាន់ ភីន មានស្រុកកំណើតនៅខេត្តក័ងតុងនៃប្រទេសចិនប្រជាមានិតបានភៀសខ្លួនមករស់នៅក្នុងស្រុកពារាំងរៀបការប្រពន្ធនិងប្រកបមុខរបរដួញដូរនៅផ្សារស្វាយពល់ ។ មុយ ប្រៀបដូចជាកូនប្រុសច្បងនៅក្នុងគ្រួសារដែរ ដោយសារថាកូនទីមួយគឺជាកូនស្រី ។ នៅអាយុ៩ឆ្នាំ មុយ ត្រូវឪពុកបញ្ជូនឲ្យចូលរៀនភាសាខ្មែរនិងរៀនភាសាចិននៅសាលារៀនចិនស្វាយពល់ ។ ដោយព្រួយបារម្ភខ្លាចការសិក្សារបស់កូនមិនបានល្អ លីវ ហាន់ ភីន បានបញ្ជូនមក មុយ មករៀននៅទីក្រុងភ្នំពេញនៅសាលារៀនឯកជនចិនមួយឈ្មោះថា «សុង ចេង» និងក្រោយមកបានផ្លាស់ទៅរៀននៅសាលារៀន «ម៉េង សែ»ហើយបានបញ្ចប់ការសិក្សាត្រឹមថ្នាក់ឌីប្លូមចិន ។ រហូតដល់ឆ្នាំ១៩៦៣ មុយ បានវិលត្រឡប់ទៅស្រុកកំណើតធ្វើជាគ្រូបង្រៀនភាសាចិននៅសាលារៀនចិនស្វាយពល់អស់រយៈពេលបីឆ្នាំកន្លះគឺពីឆ្នាំ១៩៦៣ដល់ឆ្នាំ១៩៦៦ ។

នៅក្នុងឆ្នាំ១៩៦៧ មុយ បានមកបង្រៀននៅសាលារៀនឯកជនចិនមួយឈ្មោះ «ដុង កុក» នៅទីក្រុងភ្នំពេញរហូតដល់ថ្ងៃរដ្ឋប្រហារ តាមការណែនាំពីបងជីដូនមួយឈ្មោះ យ៉ាន ដេង (អ៊ាង ស៊ីដេង) ដែលជាគ្រូបង្រៀនភាសាចិនដែរ ។ លីវ ហាន់ ភីន មានការព្រួយបារម្ភអំពី មុយ យ៉ាងខ្លាំងខ្លាចកូនប្រកាន់យកផ្លូវខុស ហើយបានទូន្មានកូនយ៉ាងច្រើនឲ្យប្រយ័ត្នប្រយែងក្នុងការបង្រៀនសិស្សចៀសវាងកុំឲ្យមានការប៉ះពាល់ដល់នយោបាយព្រោះថាសភាពការណ៍ស្រុកទេសមិនសូវល្អ ពិសេសក្នុងការទាក់ទងជាមួយ ស៊ីដេង ដោយសារគាត់ដឹងថា ស៊ីដេង ជានិស្សិតបញ្ចប់ការសិក្សានៅប្រទេសចិន ហើយទទួលការអប់រំអំពីលទ្ធិម៉ៅនិយមយ៉ាងឆ្អិនឆ្អៅ ។ មុយ បានប្រកាន់ខ្ជាប់ការទូន្មានរបស់ឪពុកបានមួយរយៈ ។ ក្នុងការបង្រៀនសិស្ស មុយ អប់រំសិស្សកុំឲ្យពាក់ព័ន្ធក្នុងរឿងនយោបាយដែរ ។ ចាប់តាំងពីពេលនោះមកឪពុកម្ដាយបងប្អូនមិនបានដឹងអំពីការងារផ្ទៃក្នុងរបស់អ្នកទាំងពីរឡើយ ។ ប្រហែលជាក្នុងឆ្នាំ១៩៧១ដល់ឆ្នាំ១៩៧២ ពេលដែលកងទ័ពភូមិភាគវាយដណ្ដើមបានតំបន់២២ មុយ បានទៅប្រចាំការនៅស្រុកពញាឮ និងស្រុកមុខកំពូល បានមួយរយៈក៏ផ្លាស់មកស្រុកកំណើតវិញ ហើយធ្វើការនៅក្រសួងវប្បធម៌ស្រុក ។ ពេលមកលេងផ្ទះម្ដងៗ មុយ តែងតែនិយាយប្រាប់ឪពុកម្ដាយបងប្អូនអំពីការងាររបស់ខ្លួនខ្លះៗដែរ ប៉ុន្តែពុំបាននិយាយលម្អិតថាខ្លួនបានធ្វើអ្វីនោះទេ ។ ទើបតែក្រោយថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ មុយ ដឹងច្បាស់ថា មុយ បម្រើការឲ្យបដិវត្តន៍ ។ ប៉ុន្តែអ្វីៗជ្រុលពេលទៅហើយ ឪពុកម្ដាយរបស់ មុយ ក៏មិនអាចជំទាស់ពីរឿងនេះទៀតដែរ ដោយសារថា ជំនាន់នោះយុវជននៅក្នុងភូមិសុទ្ធតែចូលបម្រើកងទ័ពទាំងអស់ ។ ប្រសិនបើ មុយ មិនចូលបដិវត្តន៍ទេ

នោះ ក្រុមគ្រួសាររបស់ មុយ ប្រាកដជាត្រូវអ្នកគ្រប់គ្រងរករឿង មិនឲ្យរស់នៅបានសេចក្តីសុខឡើយ ។ ដោយមាន មុយ ជាបងែ្អក ប្អូនៗពីរនាក់ក៏បានចូលបដិវត្តន៍ ហើយក្រុមគ្រួសារក៏មិនសូវទទួល ការរិះគន់ឬវាយប្រហារអ្វីពីគណៈភូមិដែរ ។ ក្រោយមក មុយ បាន ផ្លាស់ទៅធ្វើការនៅភ្នំពេញ ។ នៅឆ្នាំ១៩៧៦ មុយ បានមកលេង ឪពុកម្តាយបងប្អូននៅស្រុកកំណើត ហើយប្រាប់បងស្រីថា «ត្រឡប់ ទៅភ្នំពេញវិញ បែបលែងបានមកហើយ ព្រោះគេ(អង្គការ) ឲ្យទៅរៀននៅចិន» ។ ប៉ុន្តែមុននោះបន្តិច មុយ បានមកលេងស្រុក ពីរដងដែរ ហើយថែមទាំងបានយករូបថតពីរសន្លឹកដែលខ្លួននៅ វត្តភ្នំយកមកទុកនៅផ្ទះទៀតផង ។ តៃ ដែលត្រូវជាប្អូនប្រុសទី៦ បាននិយាយថា «មកភូមិវិញបានប៉ុន្មានដើងត្រឡប់ទៅវិញថា គេទៅរៀននៅស្រុកចិន ស្រាប់តែបាត់ដំណឹងរហូត» ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ឪពុកម្តាយនិងបងប្អូននៅ ស្រុកកំណើតទន្ទឹងរង់ចាំផ្លូវ មុយ គ្រប់ៗគ្នា ហើយបានតាមស៊ើបសួរ រកដំណឹងតាមរយៈអ្នកដែលបានត្រឡប់មកភូមិវិញទៀតផង ។ ក្រោយមកលេចឮពាក្យចចាមអារាមពីអ្នកភូមិថា បានឃើញ មុយ ធ្វើដំណើរទៅទិសលិច តាំងពីនោះមកគ្មានលេចឮដំណឹងអ្វី បន្តិចសោះឡើយ ។ រឿងរ៉ាវទាំងអស់បានបង្កើតជាចម្ងល់មួយនៅ ក្នុងក្រុមគ្រួសាររបស់ មុយ ថា «បើនៅរស់ ម៉េចក៏យូរហើយមិន ឃើញមក?» ទោះជាយ៉ាងណាការបាត់ខ្លួនរបស់ មុយ នៅឋិតនៅ ក្នុងភាពអាថ៌កំបាំងដដែល ។ នៅឆ្នាំ២០០០ បន្ទាប់ពីឪពុកម្តាយធ្វើ មរណកាលបានមួយឆ្នាំមិត្តភក្តិរបស់ តៃ ដែលធ្វើការនៅសាលា ស្រុក ហើយបានអានទស្សនាវដ្តីស្វែងរកការពិត បានមកប្រាប់ថា បានឃើញចម្លើយរបស់ មុយ ។ តៃ ក៏បានប្រញាប់ប្រញាល់ទៅខ្ចី សៀវភៅនេះពីសាលាស្រុក ហើយនាំដំណឹងនេះទៅប្រាប់បងប្អូន របស់គាត់ ។ សេចក្តីសារភាពនេះជាផ្នែកមួយដែលធ្វើក្រុមគ្រួសារ របស់គាត់បានដឹងពីសញ្ញាណខ្លះៗ ប៉ុន្តែវានៅតែធ្វើឲ្យបងប្អូន របស់ តៃ មិនទាន់ច្បាស់ក្នុងចិត្តមួយភាគរយឡើយ ដោយសារនៅ ក្នុងសេចក្តីសង្ខេបនោះមិនបានបញ្ជាក់ពីថ្ងៃស្លាប់របស់ មុយ ។ តៃ ក៏ធ្វើបន្តការស្រាវជ្រាវតទៅទៀត ។

## អតីតអ្នករួមបដិវត្តន៍

ស៊ូ បច្ចុប្បន្នរស់នៅទីក្រុងភ្នំពេញបានមានប្រសាសន៍ថា គាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំងពេលឃើញសេចក្តីសារភាពមួយសន្លឹក ឈ្មោះ ឡុង មុយ ហៅ ដួន ពីព្រោះថាជាមនុស្សម្នាក់ដែលគាត់ ធ្លាប់ស្គាល់និងមានទំនាក់ទំនងគ្នាកាលពីជាង៣០ឆ្នាំមុន ។ ស៊ូ រំឭកថា បានជួប ឡុង មុយ ចំនួនពីរលើក ។ លើកទី១ គឺនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៧០ជាថ្ងៃ ដែល មុយ បានទទួលការចាត់តាំងពី អ៊ាង ស៊ីផេង ជាអ្នកក្តាប់អណិកជនចិននៅរដ្ឋធានីមកទទួលគាត់ ជាមួយប្រពន្ធនិងមនុស្សពីរនាក់ទៀតទៅកាន់តំបន់រំដោះ ប៉ុន្តែ គាត់ពុំបានស្គាល់ឈ្មោះរបស់ មុយ នៅឡើយទេ ដោយសារថា ជំនាន់នោះការប្រាប់ឈ្មោះគឺរឿងលាក់ការណ៍បំផុត ។ មុយ បាន នាំគាត់ទាំងប្អូនឡើងកាណូតទៅព្រែកពោធិ៍ រួចបន្តដំណើរទៅកាន់ ស្រុកមេសប្រចាន់នៅក្នុងខេត្តព្រៃវែង ដើម្បីប្រគល់គាត់ទៅឲ្យ ឈ្មោះ កែវ វ៉ាន់ ជាគណៈស្រុក ។ ចាប់តាំងពីពេលនោះមកគាត់ មិនដែលបានជួប មុយ ឡើយ ។ រហូតដល់ឆ្នាំ១៩៧១ គាត់ទាំងពីរ បានជួបគ្នាម្តងទៀតនៅក្រសួងវប្បធម៌ផ្នែករោងពុម្ពនៅតំបន់ ២២ ។ មុយ បានបបួលគាត់ទៅលេងផ្ទះរបស់ អ៊ាង ស៊ីផេង ដើម្បី ឲ្យការទំនាក់ទំនងរបស់គាត់កាន់តែមានភាពស្និទ្ធស្នាល ។ នៅពេល នោះហើយដែលគាត់បានស្គាល់ឈ្មោះ មុយ ពិតប្រាកដ ។ ក្រោយ ពីនោះមកគាត់ទាំងពីរក៏ដាច់ការទាក់ទងគ្នារហូត ។ បន្ទាប់ពីបាន អានចម្លើយសារភាព បូករួមនឹងអ្វីដែលគាត់ធ្លាប់មានទំនាក់ទំនង ស៊ូ វាយតម្លៃថា មានចំណុចខ្លះពិតនិងចំណុចខ្លះនិយាយបំផ្លើស ដែលនេះប្រហែលជាមានការធ្វើទារុណកម្មទើប មុយ ឆ្លើយបែប នេះ ។ ការពិត មុយ ជាមនុស្សស្មោះត្រង់នឹងអង្គការ ប៉ុន្តែ ដោយសារមានការបោសសម្អាតថ្នាក់លើដែលជាបក្សពួករបស់ សោ ភឹម ដែលត្រូវបានចោទប្រកាន់ថា អ្នកបូព៌ាសុទ្ធតែជាជន ក្បត់អង្គការ ពេលនោះអង្គការចាប់ទាំងបក្សពួកនិងខ្សែរយៈក្បត់ ទាំងអស់ ។ នៅក្នុងទស្សនៈរបស់អង្គការ ប្រជាជន១៧មេសាត្រូវ បានចាត់ទុកថាជនសេ.អ៊ី.អាដោយស្វ័យប្រវត្តិ ហើយអ្នកដែល ចូលដៃជើងជាមួយវៀតណាមត្រូវបានចាត់ទុកថា ជាកា.ហ្សេ.បេ ហើយត្រូវអង្គការចាប់ខ្លួនទាំងអស់ដែរ ។

បន្ទាប់ពីបានអានចម្លើយនេះ តៃ និងបងប្អូនមានសង្ឃឹមតិច ណាស់ដែលថាបងប្រុសនៅរស់ ព្រោះថាអ្នកទោសភាគច្រើនដែល ត្រូវបានសួរចម្លើយនៅមន្ទីរស-២១កម្រមានជីវិតរស់ណាស់ ។

តែ ទទួលស្គាល់ថា ចម្លើយនេះជាសេចក្តីសារភាពរបស់បងប្រុសគាត់ពិតមែន ដោយសារថានៅក្នុងចម្លើយបាននិយាយពាក់ព័ន្ធឈ្មោះអ្នកស្រុកអ្នកភូមិរបស់គាត់ច្រើននាក់ ។ «ដល់ពេលឃើញចម្លើយហ្នឹង ប្រាកដជាចម្លើយរបស់គាត់ហើយ ព្រោះមិនមានអ្នកក្រៅណាអាចសរសេរឈ្មោះអ្នកស្រុកភូមិជាមួយគ្នាទេ» ។ ប៉ុន្តែចម្លើយមួយចំនួនទៀតក៏និយាយបំភ្លើសដើម្បីឲ្យរួចខ្លួនតែប៉ុណ្ណោះ «ដល់អានទៅឃើញថា មើលទៅពិតខ្លះមិនពិតខ្លះ និយាយយកតែរួចខ្លួន...ចេះតែដាក់ផ្តេសផ្តាសខ្លះទៅឲ្យតែពេញ ។ ពួកហ្នឹងធ្វើយូរៗលែងទុកចិត្តគ្នាឯង ។ គោលបំណងរបស់គាត់ធ្វើដើម្បីប្រទេសជាតិ ហើយសង្ឃឹមថាជួយឲ្យប្រទេសបានរីកចំរើន ។ គាត់ស្មោះត្រង់ជាតិ ទៅជាគេចោទគាត់ថា ក្បត់ជាតិទៅវិញ» ។

ចម្លើយសារភាពនេះជាប្រភពព័ត៌មានមួយដ៏សំខាន់សម្រាប់បងប្អូនរបស់ តែ ដែលបានទន្ទឹងរង់ចាំដំណឹងរយៈពេលច្រើនឆ្នាំ ។ តែ បង្ហាញពីអារម្មណ៍របស់គាត់ថា «បានឯកសារអស់សង្ស័យ លែងមានភាពស្រពិចស្រពិលទៀតហើយ ។ ដឹងថាគាត់ស្លាប់នៅកន្លែងណា ។ ខ្ញុំធូរស្បើយក្នុងចិត្ត ទោះបីជាថាមានកំហឹងចំពោះទង្វើខ្មែរក្រហមក៏ដោយ ប៉ុន្តែយូរៗទៅណាយហើយ» ។ មិនតែប៉ុណ្ណោះ សេចក្តីសារភាពនេះបានឆ្លុះបញ្ចាំងឲ្យឃើញអំពីមូលហេតុមួយចំនួនដែលនាំឲ្យ មុយ ត្រូវបានសម្លាប់និងសំខាន់សម្រាប់តុលាការទៀតផង ។ តែ បន្តថា ឯកសារនេះផ្តល់សារសំខាន់ច្រើនដូចជាបង្ហាញឲ្យដឹងអំពីការស្លាប់របស់ជនរងគ្រោះនិងសកម្មភាពឃោរឃៅរបស់របបនេះ ផ្តល់ជាឯកសារតម្កល់នៅសារមន្ទីរសម្រាប់ឲ្យអ្នកជំនាន់ក្រោយស្វែងយល់អំពីរបបដ៏ព្រៃផ្សៃនេះនិងភស្តុតាងដ៏សំខាន់សម្រាប់តុលាការ ។ ក្រៅពីនេះ តែ ព្រួយបារម្ភខ្លាចក្មេងៗជំនាន់ក្រោយមិនបានសិក្សាអំពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ «ស្រុកខ្មែរយើងកូនសិស្សមិនទាន់មានរៀនតាមប្រវត្តិរបស់ខ្លួនទេ អនាគតទៅក្មេងជំនាន់ក្រោយប្រហែលអត់ជឿថាខ្មែរក្រហមឃោរឃៅដល់ប៉ុណ្ណឹងទេ» ។ បន្ទាប់ពីទទួលបានព័ត៌មានទាំងអស់នេះ តែ នៅមិនទាន់នឹកឃើញត្រូវធ្វើអ្វីនៅឡើយ ពីព្រោះគាត់ហាក់ដូចជាមិនទាន់មានសង្ឃឹមមួយរយភាគរយថាតុលាការអាចកាត់ទោសមេដឹកនាំធំៗទាន់ពេលវេលា ។

ទោះជាយ៉ាងណា តែ បន្ថែមចុងក្រោយថា គាត់គ្មានទាមទារអ្វីទេ ក្រៅពីសុំឲ្យតុលាការដែលកំពុងតែដំណើរការនាពេលបច្ចុប្បន្ន រកយុត្តិធម៌មួយត្រឹមត្រូវទៅតាមនីតិវិធីច្បាប់ប៉ុណ្ណោះ ។ **លី សុផល**



# ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ជំពូកទី៥
## ភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ

*នៅឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកកម្ពុជាប្រជាធិបតេយ្យទៅជា៦ភូមិភាគ ដែលរួមមាន៣២តំបន់។ ភូមិភាគនីមួយៗគឺយកខេត្តពីរឬច្រើនមកបញ្ចូលគ្នា ឬកាត់ចេញពីខេត្តនេះខ្លះឬខេត្តនោះខ្លះមកបញ្ចូលគ្នា។ ភូមិភាគនិងតំបន់ទាំងអស់សុទ្ធតែត្រូវបានដាក់កំណត់សម្គាល់ជាលេខ។ ភូមិភាគនីមួយៗចែកចេញជាច្រើនតំបន់ ហើយតំបន់នីមួយៗចែកចេញជាស្រុក ឃុំ និងសហករណ៍។*

***ភូមិភាគបូព៌ា*** *(ភូមិភាគ២០៣) ដឹកនាំដោយ សោ ភឹម ដែលធ្វើអត្តឃាតនៅខែឧសភា ឆ្នាំ១៩៧៨។ ភូមិភាគនេះរួមមានខេត្តព្រៃវែងនិងខេត្តស្វាយរៀងទាំងមូល ផ្នែកខ្លះនៃខេត្តកំពង់ចាមដែលស្ថិតនៅត្រើយខាងកើតទន្លេមេគង្គទាំងអស់និងកាត់ចេញពីស្រុកមួយក្នុងខេត្តក្រចេះគឺស្រុកឆ្លូង និងកាត់យកស្រុកខ្លះពីខេត្តកណ្តាលដែលរួមមានស្រុកខ្សាច់កណ្តាល ល្វាឯម និងមុខកំពូល។ ភូមិភាគនេះចែកចេញជាប្រាំតំបន់ដែលរួមមាន តំបន់២០ តំបន់២១ តំបន់២២ តំបន់២៣ និង តំបន់២៤។*

***ភូមិភាគនិរតី*** *(ភូមិភាគ៤០៥) ដឹកនាំ ដោយ ឈិត ជឿន ហៅតាម៉ុក។ ភូមិភាគនេះរួមមានខេត្តកំពតនិងខេត្តតាកែវទាំងមូល ស្រុកពីរក្នុងខេត្តកំពង់ស្ពឺ (ស្រុកសំរោងទង និងស្រុកគងពិសី) និងស្រុកប្រាំក្នុងខេត្តកណ្តាល (ស្រុកកណ្តាលស្ទឹង ស្អាង កោះធំ កៀនស្វាយ និងស្រុកលើកដែក)។ ភូមិភាគនេះចែកចេញជាបួន*



*កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមធ្វើទស្សនកិច្ចជនបទ*

តំបន់ គឺតំបន់១៣ តំបន់៣៣ តំបន់៣៥ និងតំបន់២៥ ។

**ភូមិភាគឧត្តរ** (ភូមិភាគ៣០៣) ដឹកនាំ ដោយ កុយ ធួន ហៅ ធុច ពីឆ្នាំ១៩៧០ទៅដើម ឆ្នាំ១៩៧៦ ។ បន្ទាប់ពី កុយ ធួន ត្រូវបានចាប់ខ្លួន និងសម្លាប់នៅគុកទួលស្លែងនៅឆ្នាំ១៩៧៦ តែ ពក ត្រូវបានចាត់តាំងជាលេខាភូមិភាគ ។ នៅឆ្នាំ១៩៧៧ តែ ពក ត្រូវបានចាត់តាំងឲ្យធ្វើជាលេខាភូមិភាគកណ្ដាលដែលទើបបង្កើតថ្មី ហើយលេខាថ្មីរបស់ភូមិភាគឧត្តរគឺ កង ចាប ។ ភូមិភាគនេះរួមមានខេត្តកំពង់ធំទាំងមូល ផ្នែកខាងលិចទន្លេមេគង្គទាំងអស់នៃខេត្តកំពង់ចាម និងស្រុកមួយក្នុងខេត្តក្រចេះ (ស្រុកព្រែកប្រសប់) ហើយចែកចេញជាបីតំបន់គឺតំបន់៤១ តំបន់៤២ និងតំបន់៤៣ ។

**ភូមិភាគពាយ័ព្យ** (ភូមិភាគ៥៦០) ដឹកនាំដោយ ញឹម រស់ ។ ភូមិភាគនេះរួមមានខេត្តពោធិសាត់និងខេត្តបាត់ដំបងទាំងមូល ដែលចែកចេញជាប្រាំពីរតំបន់គឺតំបន់១ តំបន់២ តំបន់៣ តំបន់៤ តំបន់៥ តំបន់៦ និងតំបន់៧ ។




*ភូមិភាគនិងតំបន់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦*



កម្មាភិបាលខ្មែរក្រហមធ្វើការប្រមូលផលស្រូវ

***ភូមិភាគបស្ចិម*** (ភូមិភាគ៤០១) ដឹកនាំដោយ ជូ ជេត ។ ភូមិភាគនេះរួមមាន ខេត្តកោះកុងនិងខេត្តកំពង់ឆ្នាំងនិងផ្នែកខ្លះនៃខេត្តកំពង់ស្ពឺ ហើយបែកចេញជាប្រាំតំបន់គឺតំបន់៣១ តំបន់៣២ តំបន់៣៧ តំបន់១៥ និងតំបន់១១ ។

***ភូមិភាគឦសាន*** (ភូមិភាគ១០៨) ដឹកនាំដោយ ណៃ សារ៉ាន់ ហៅ យ៉ា (សម្លាប់នៅឆ្នាំ១៩៧៦) ។ ភូមិភាគនេះ រួមមានខេត្តរតនគិរី ខេត្តមណ្ឌលគិរី ផ្នែកខ្លះនៃខេត្តក្រចេះ និងផ្នែកខ្លះនៃខេត្តស្ទឹងត្រែង ដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ ។ ភូមិភាគនេះបែកចេញជាប្រាំមួយតំបន់ គឺ តំបន់១០១ តំបន់១០២ តំបន់១០៤ តំបន់ ១០៥ តំបន់១០៧ និងតំបន់ ៥០៥ ។

ក្នុងឆ្នាំ១៩៧៦នេះ កម្ពុជាប្រជាធិបតេយ្យបានបង្កើតតំបន់ស្វយ័តចំនួនពីរផ្សេងទៀតដែលទាក់ទងការងារផ្ទាល់ជាមួយគណៈកម្មាធិការមជ្ឈិមបក្ស ប៉ុន្តែមិនតាមរយៈភូមិភាគណាមួយទេ ។ តំបន់ទាំងនេះរួមមានតំបន់សៀមរាប ឧត្តរមានជ័យ(តំបន់១០៦) និងតំបន់ព្រះវិហារ(តំបន់១០៣) ។ ក្រុងកំពង់សោម (បច្ចុប្បន្នក្រុងព្រះសីហនុ) ក៏ត្រូវបានចាត់តាំងដោយឡែកពីភូមិភាគដែរ ។

នៅឆ្នាំ១៩៧៧ ភូមិភាគថ្មីមួយទៀត គឺភូមិភាគកណ្តាលត្រូវបានបង្កើតឡើង ។ ភូមិភាគនេះមានទីតាំងស្ថិតនៅត្រង់អតីតភូមិភាគឧត្តរ ចំណែកភូមិភាគឧត្តរថ្មីត្រូវបានប្តូរទីតាំងទៅតំបន់សៀមរាប-ឧត្តរមានជ័យនិងតំបន់ព្រះវិហារ ។ តំបន់ក្រចេះ (ឬតំបន់៥០៥) និងតំបន់មណ្ឌលគិរី(ឬតំបន់១០៥) ត្រូវបានបំបែកចេញពីភូមិភាគឦសាននិងចាត់តាំងជាតំបន់ស្វយ័ត ។

## ជំពូកទី៦
## គម្រោងផែនការបួនឆ្នាំ (១៩៧៧-១៩៨០)

ខ្មែរក្រហមបានធ្វើការបោសសម្អាតទីក្រុងនិងទីប្រជុំជននានា ដើម្បីលុបបំបាត់ចោលការរស់នៅតាមទីក្រុង និងកសាងកម្ពុជាមួយថ្មីដោយពឹងផ្អែកលើការពង្រីកផលិតកម្មស្រូវ ។ ដើមឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានប្រញាប់ប្រញាល់រៀបចំផែនការបួនឆ្នាំលើកទីមួយ (១៩៧៧-១៩៨០) ដែលតម្រូវឲ្យធ្វើការប្រមូលផ្តុំនូវរាល់សម្បត្តិឯកជនទាំងអស់និងដាក់ការដាំដុះស្រូវជាអាទិភាពចម្បងរបស់ជាតិ ។ បន្ទាប់ពីបញ្ហោសន្តិសុខ

ជាតិ សមូហភាវូបនីយកម្មគឺជាគោលនយោបាយដ៏សំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ។

ប្រជាជនកម្ពុជាមិនដែលជួបប្រទះការប្រមូលផ្តុំបែបនេះទេតាំងពីមុនមក ។ ប៉ុន្តែក្នុងឆ្នាំ១៩៧៦ ប្រជាជនគ្រប់រូបត្រូវបានតម្រូវឲ្យប្រមូលទ្រព្យសម្បត្តិឯកជនទាំងអស់របស់ខ្លួន (រួមទាំងសម្ភារផ្ទះបាយផង) ដើម្បីប្រើប្រាស់រួម ។ ជាផ្នែកមួយនៃដំណើរការនេះដែរ គ្រួសារខ្មែរទាំងអស់ត្រូវបានបំបែកចេញពីគ្នា ហើយប្រជាជនគ្រប់រូបត្រូវបានចាត់តាំងឲ្យទៅធ្វើការតាមក្រុមរៀងៗខ្លួន ។ ប្តីប្រពន្ធត្រូវបានបំបែកឲ្យរស់នៅផ្សេងពីគ្នា ហើយកូនៗត្រូវបានបំបែកចេញពីឪពុកម្តាយ ។


កងចល័តនារីខ្មែរក្រហមធ្វើការប្រមូលផលស្រូវ

ផែនការបួនឆ្នាំមានគោលដៅសម្រេចឲ្យបានផលិតផលស្រូវបីតោនក្នុងមួយហិកតាជាមធ្យម ។ នេះជាកិច្ចការមួយដែលមិនអាចធ្វើទៅកើត ដោយហេតុថាប្រជាជនកម្ពុជាមិនដែលត្រូវបានបង្ខំឲ្យធ្វើការដាំដុះស្រូវយ៉ាងសម្បើមក្នុងទូទាំងប្រទេសបែបនេះទេតាំងពីបុរាណកាលមក ។ ជាងនេះទៅទៀត ប្រទេសជាតិត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាម ហើយកង្វះខាតឧបករណ៍ សត្វពាហនៈ និងកង្វះខាតកម្លាំងពលកម្មមាំមួន ។

ផែនការបួនឆ្នាំមានរួមបញ្ចូលទាំងគម្រោងដាំបន្លែបង្ការ ហើយសង្ឃឹមថានឹងអាចទាញយកប្រាក់ចំណូលពីអនុផលព្រៃឈើ ការនេសាទ ការចិញ្ចឹមសត្វ និងការដាំដើមឈើ ។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យសង្ឃឹមថា នឹងធ្វើឲ្យកម្ពុជាមានឯករាជ្យពេញបរិបូរណ៍ទាំងវិស័យសេដ្ឋកិច្ច ក៏ដូចជាវិស័យនយោបាយ និងមានបំណងប្រែក្លាយកម្ពុជាពីប្រទេសកសិកម្មអន់ថយឲ្យទៅកសិកម្មសម័យទំនើបមួយ ។

ទោះជាយ៉ាងនេះក្តី មេដឹកនាំទាំងនេះមិនបានគិតដល់ផលវិបាកនៃការអនុវត្តន៍ផែនការនេះ និងទុក្ខវេទនារបស់ប្រជាជនបណ្តាលមកពីការធ្វើការហួសកម្លាំង លក្ខខណ្ឌរស់នៅមិនល្អ ការទទួលទានអាហារមិនគ្រប់គ្រាន់ ការខ្វះខាតសេរីភាពនិងសិទ្ធិជាមូលដ្ឋាន ហើយនិងជំងឺដែលគ្មានការព្យាបាល ។ ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ លក្ខខណ្ឌរស់នៅរបស់ប្រជាជនមានសភាពយ៉ាប់យឺនយ៉ាងខ្លាំង ។ របបនេះបានបំផ្លាញសុភមង្គលនិងសេចក្តីថ្លៃថ្នូរជាមនុស្សរបស់ប្រជាជនកម្ពុជាស្ទើរគ្មានសល់ចន្លោះ ។ ប្រជាជនភាគច្រើនដឹងថាប្រទេសមួយត្រូវការអ្នកចេះដឹងដើម្បីអភិវឌ្ឍន៍ ។ ប៉ុន្តែ ខ្មែរក្រហមបានសម្លាប់បញ្ញវន្តនិងអ្នកបច្ចេកទេសអស់ជាច្រើនហើយបានបិទសាកលវិទ្យាល័យ សាលារៀន និងមជ្ឈមណ្ឌលអប់រំដទៃទៀតនៅទូទាំងប្រទេស ។ ខ្មែរក្រហមបានបញ្ជូនកសិករពីជនបទដែលពុំមានបទពិសោធន៍ឲ្យមកធ្វើការនៅតាមរោងចក្រមួយចំនួនតូចនៅទីក្រុងភ្នំពេញទៅវិញ ។


ការសម្តែងសិល្បៈរបស់កងយុវជនយុវនារី

កម្ពុជាប្រជាធិបតេយ្យបានចែកដីស្រែទៅជាដីស្រែល្អលេខមួយ និងដីស្រែមិនល្អធម្មតា ។ ទិន្នផលសម្រាប់ដីស្រែធម្មតាគឺបីតោនក្នុងមួយហិកតា ចំណែកដីស្រែលេខមួយកសិករត្រូវធ្វើឲ្យបានពីប្រាំមួយទៅប្រាំពីរតោនក្នុងមួយហិកតា ។ ជាងនេះទៅទៀត ទិន្នផលស្រូវនឹងត្រូវបង្កើនជារៀងរាល់ឆ្នាំ ។

នៅក្នុងទ្រឹស្តីដែលបានចែងក្នុងផែនការបួនឆ្នាំនេះ ទិន្នផលស្រូវត្រូវបានបែងចែកជាបួនចំណែក ។ មួយចំណែកសម្រាប់ជាស្បៀងរបស់ប្រជាជនដែលម្នាក់ៗទទួលបាន៣១២គីឡូក្រាមស្រូវក្នុងមួយឆ្នាំ ឬ០,៨៥គីឡូក្រាមស្រូវក្នុងមួយថ្ងៃ ។ មួយចំណែកទៀតសម្រាប់ធ្វើពូជ ហើយមួយចំណែកទៀតសម្រាប់ទុកបម្រុង ។ ចំណែកចុងក្រោយដែលជាចំណែកធំជាងគេនោះត្រូវបានយកទៅលក់នៅឯបរទេសដើម្បីប្តូរយកសាច់ប្រាក់ដែលអាចប្រើប្រាស់ដើម្បីទិញម៉ាស៊ីនសម្រាប់ធ្វើស្រែចម្ការ គ្រឿងសព្វាវុធនិងទំនិញផ្សេងៗទៀត ។

ដោយសារតែទិន្នផលស្ទើរតែមិនគ្រប់តាមផែនការដែលបានកំណត់នោះ មានស្រូវតិចតួចណាស់ដែលរក្សាទុកសម្រាប់ចិញ្ចឹមប្រជាជននិងសម្រាប់គ្រាប់ពូជ ។ ផ្ទុយទៅវិញស្រូវភាគច្រើនត្រូវបានយកទៅផ្គត់ផ្គង់កងទ័ពនិងកម្មកររោងចក្រនិងនាំចេញទៅប្រទេសចិន និងប្រទេសសង្គមនិយមដទៃទៀត ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្ទើរតែគ្មានអ្នកណាម្នាក់ធ្លាប់ទទួលបានរបបអាហារគ្រប់គ្រាន់ទេ ។ ប្រជាជនភាគច្រើនហូបតែបបរលាយពោត ដើមចេកនិង ដើមល្ហុង ហើយទទួលបានរបបអង្ករតិចជាងកន្លះកំប៉ុងទឹកដោះគោក្នុងមួយថ្ងៃ ។ មានតែកម្មាភិបាលនិងកងទ័ពខ្មែរក្រហមប៉ុណ្ណោះដែលមានបាយហូបគ្រប់គ្រាន់ ។ អ្នកដែលនៅរស់រានមានជីវិតទាំងអស់ពីរបបនេះយល់ស្របថា អ្វីដែលគាត់ចងចាំបំផុតក្រៅពីការបង្ខំឲ្យធ្វើការហួសកម្លាំងនិងការកាប់សម្លាប់នោះគឺការខ្វះខាតអាហារយ៉ាងខ្លាំង ។

អ៊ុំ សារ៉េត អាយុ៥៧ឆ្នាំ ប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ បានរៀបរាប់ពីជីវិតឈឺចាប់របស់គ្រួសារគាត់ ដោយសារការហូបមិនគ្រប់គ្រាន់ថា៖ នៅឆ្នាំ១៩៧៦ ដោយទ្រាំមិនបាននឹងការស្រេកឃ្លានឪពុកខ្ញុំបានដួសកូនក្អុកមកស្ងោរហូប ដោយគាត់គិតថានោះគឺជាកូនត្រី ។ ថ្ងៃមួយកម្មាភិបាល ខ្មែរក្រហមម្នាក់បានសម្លាប់ពស់មានពិសមួយ ហើយយកមកទុកចោលនៅលើរបង ។ គាត់ដឹងដែរថាពស់នោះមានពិស ប៉ុន្តែគាត់នៅតែពិសាទៀតរហូតធ្វើឲ្យគាត់ស្លាប់ ។ ប្អូនស្រីខ្ញុំនិងកូនៗស្លាប់ដោយសារតែការអត់ឃ្លាន ។ គ្រួសាររបស់ខ្ញុំក៏ស្ថិតនៅក្នុងស្ថានភាពដូចគ្នាដែរ ។ យើងបានខិតខំធ្វើស្រែចម្ការយ៉ាងច្រើន ប៉ុន្តែយើងមិនដែលបានហូបគ្រប់គ្រាន់ទេ ។ ដោយឃ្លានខ្លាំងពេក ពេលខ្លះខ្ញុំកាត់ដើមត្រាវព្រៃមកស្ងោរហូប ។ ពេលហូបហើយ រមាស់ពេញខ្លួន ។ កូនៗខ្ញុំយំទ្រហឹងពេញផ្ទះ ។ ថ្ងៃមួយខ្ញុំទៅស្ទូចត្រី ។ ប្រធានកងតំរាមខ្ញុំថា "ធ្វើបុកថៅកទាបទៅអង្គុយស្ទូចត្រី ប្រយ័ត្នអង្គការយកទៅសម្លាប់ចោល" ។ ដោយការខ្វះអាហារ កូនរបស់ខ្ញុំម្នាក់ធ្លាក់ខ្លួនឈឺជាទម្ងន់ ។ ខ្ញុំបានយកខ្សែកទៅដូរយកអង្ករមកដាំបាយឲ្យកូនខ្ញុំហូប ។ កូនខ្ញុំហូបបាយច្រើនណាស់ តែជំងឺរបស់វាកាន់តែធ្ងន់ធ្ងរឡើងជាលំដាប់ ហើយក៏ស្លាប់បាត់ទៅ ។ កូនខ្ញុំពីរនាក់ទៀតនិងប្តីរបស់ខ្ញុំក៏ធ្លាក់ខ្លួនឈឺដែរ ដោយសារតែហូបមិនគ្រប់គ្រាន់ ។ ទោះជាយ៉ាងនេះក្តី ខ្ញុំ-ប្តី ហើយនិងកូនបានប្រឹងប្រែងរស់យ៉ាងវេទនាជាទីបំផុត ។

**(នៅមានត)**

**ឌី ខាំបូលី**



សកម្មភាពជញ្ជូនដីនៅក្នុងគម្រោងលើកទំនប់ដីកប្រឡាយ

# គុកខ្មែរក្រហម

## ខេត្តរតនគិរី

### ស្រុកបានលុង

### ១) មន្ទីរសន្តិសុខបឹងកន្សែងឬអូរកន្សែង

*វាលស្រែនិងព្រៃស៊ុបទ្រុបនៅខាងក្រោយមន្ទីរពេទ្យបង្អែកខេត្តរតនគិរី គឺជាបរិវេណមន្ទីរសន្តិសុខបឹងកន្សែងរបស់ខ្មែរក្រហម ។ នៅជាប់ជើងភ្នំមានផ្ទះមួយខ្នងសាងសង់ឡើងតាមរបៀបផ្ទះជនជាតិភាគតិច ប្រជាជនខ្លះកំពុងប្រកបការងារធ្វើស្រែចម្ការនៅលើផ្ទៃដីដ៏ធំទូលាយនៃអតីតមន្ទីរសន្តិសុខបឹងកន្សែងនេះ ។*

*មន្ទីរសន្តិសុខបឹងកន្សែងស្ថិតនៅក្នុងភូមិទួយ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី ត្រូវសាងសង់ឡើងពីឈើដំបូលប្រក់ស្បូវ ជញ្ជាំងបាំងដោយដើមឫស្សី កាលពីឆ្នាំ១៩៧២និងឆ្នាំ១៩៧៣ ។ មន្ទីរសន្តិសុខនាពេលនោះមានលក្ខណៈដូចម៉ារីយេទាហាន(បន្ទាយទាហាន) ដែលមានផ្ទះ៥ - ៦ខ្នងរាងទ្រវែងជាប់ៗគ្នា ។ ជនរងគ្រោះរាប់សិបនាក់ត្រូវខ្មែរក្រហមចាប់ដាក់នៅទីនេះដោយសារតែប្រព្រឹត្តខុសនឹងមាគ៌ាបដិវត្តន៍ ។ អ្នកទោសនៅមន្ទីរសន្តិសុខបឹងកន្សែងនៅមិនទាន់ទទួលរងការធ្វើទារុណកម្មខ្លាំងក្លានៅឡើយទេ ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ កងសន្តិសុខបានបង្អត់អាហារអ្នកទោសជាបណ្តើរៗ ដោយម្នាក់ៗទទួលរបបបាយតែមួយកូនចានប៉ុណ្ណោះក្នុងមួយពេល ។ ក្រោយមក របបអាហារដ៏តិចតួចនេះត្រូវអង្គការកាត់ចោលទាំងស្រុង ដោយចែករបបអង្ករជំនួសវិញ ។ នៅឆ្នាំ១៩៧៦និងឆ្នាំ១៩៧៧ អ្នកទោស៣នាក់បានទទួលរបបអង្ករមួយកំប៉ុងសម្រាប់ហូបក្នុងមួយថ្ងៃ ។ ចំណែកសម្លវិញ គ្មានអ្វីក្រៅពីស្លឹកដំឡូងមីនិងគល់ចេកឡើយ ។*

*ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ កងសន្តិសុខមិនត្រឹមតែបង្អត់អាហារអ្នកទោសប៉ុណ្ណោះទេ ថែមទាំងធ្វើទារុណកម្មយ៉ាងខ្លាំងរហូតដល់នាំយកទៅសម្លាប់ចោលជាច្រើននាក់ទៀតផង ។*

*ប៊ុន វ៉ាន់ថា អាយុ៥៩ឆ្នាំ បច្ចុប្បន្នមានទីលំនៅឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី ជាអតីតអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសជាច្រើននាក់ដែលជាប់នៅមន្ទីរសន្តិសុខបឹងកន្សែងតាំងពីឆ្នាំ១៩៧៣ ដោយសាររដ្ឋអំណាចចោទប្រកាន់ថាជាភ្នាក់ងារបម្រើវៀតណាមហៅថា «កា.ហ្សេ.បេ» និងជាខ្សែរយៈ «សេ.អ៊ី.អា» របស់ចក្រពត្តិអាមេរិក ។ នៅជំនាន់នោះមួយផ្នែកនៃមន្ទីរនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ហើយមួយផ្នែកទៀតនៅក្រោមការគ្រប់គ្រងរបស់របបសាធារណរដ្ឋខ្មែរ ។ ប្រជាជនត្រូវរស់នៅក្នុងតំបន់មួយ ដែលគ្មានច្បាប់ទម្លាប់ ទទួលរងនូវការធ្វើបាប និងធ្វើទុក្ខបុកម្នេញគ្រប់បែបយ៉ាងពីអ្នកកាន់អំណាចទាំងសងខាង ។ វ៉ាន់ថា និយាយពីមូលហេតុដែលគាត់ត្រូវជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខបឹងកន្សែងថាមកពីគាត់សរសេរលិខិតមួយច្បាប់ក្នុងគោលបំណងផ្ញើទៅនួន ជា ដែលកាលនោះ មាននាទីជាអ្នក*


មន្ទីរសន្តិសុខអូរកន្សែង

តំណាងប្រជាជនប្រចាំនៅខេត្តរតនគិរីដើម្បីប្តឹងពីការធ្វើបាប ធ្វើទុក្ខបុកម្នេញ និងការរស់នៅគ្មានច្បាប់ទម្លាប់ ។ ប៉ុន្តែសំបុត្រនេះមិនបានយកទៅប្រគល់ឲ្យ នួន ជា ដោយផ្ទាល់ទេ គឺតាមរយៈសមមិត្ត ទុំ ជាកម្មាភិបាលទទួលខុសត្រូវភូមិភាគឦសានដែលសន្យាថានឹងយកទៅប្រគល់ឲ្យ នួន ជា ដោយផ្ទាល់ដៃ ។ វ៉ាន់ថា ត្រូវអង្គការកត់ឈ្មោះទុកក្នុងបញ្ជីបន្ទាប់ពីបានប្រគល់សំបុត្រនេះទៅឲ្យ ទុំ ។ បន្តិចក្រោយមក វ៉ាន់ថា និងប្រពន្ធរបស់គាត់ត្រូវខ្មែរក្រហមចាប់យកទៅដាក់ឃុំឃាំង ។ វ៉ាន់ថា ត្រូវកងសន្តិសុខប្រើឲ្យអារឈើ លើកឈើហ៊ុប ដីកដីដាំដើមខ្នុរ ដើមដូង បោចស្មៅ និងជម្រះស្មៅ ដំឡូងមី ។ វ៉ាន់ថា បានត្អូញត្អែរថា «វាជារឿងអយុត្តិធម៌បំផុតសម្រាប់អ្នកទោស ព្រោះពួកខ្មែរក្រហមអាចធ្វើអ្វីៗបានគ្រប់យ៉ាង ទោះជារឿងខុសសីលធម៌ក៏ដោយ ។

រៀងរាល់ល្ងាចវេលាម៉ោង៨:៣០នាទី ខ្មែរក្រហមបានបញ្ជាឲ្យអ្នកទោសទាំងអស់ត្រឡប់ចូលមន្ទីរឃុំឃាំងវិញដើម្បីចូលរួមប្រជុំបំពាក់បំប៉នគោលជំហរបដិវត្តន៍ ។ នៅពេលយប់ អ្នកទោសដេកតម្រៀបជាជួរៗលើគ្រែដោយមានដាក់ខ្នោះកជើងទៀតផង ការធ្វើបែបនេះគឺដើម្បីងាយស្រួលដល់កងសន្តិសុខដើររាប់ចំនួន ។ វ៉ាន់ថា និយាយថា សន្តិសុខប្រើសោផលិតនៅប្រទេសចិនមកចាក់ភ្ជាប់ខ្នោះកជើងអ្នកទោសទៅនឹងរនុកដែកវែងៗ ។ ជួនកាលអ្នកទោសត្រូវដេកទាំងជើងជាប់ខ្នោះដោយមានតែខោខ្លីប៉ុណ្ណោះ ។

ព្រលឹមស្រាងៗ ស្នូរជួងបានបន្លឺឡើងជាសញ្ញាឲ្យអ្នកទោសទៅប្រជុំជួរដើម្បីទទួលភារកិច្ចទៅតាមមុខងាររៀងខ្លួន ។ កម្មាភិបាលឈ្មោះ សែ និង ឆាង បានបើកអង្គប្រជុំរៀងរាល់ព្រឹកមាន ។ សែ មានស្រុកកំណើតនៅខេត្តតាកែវ ជាប្រធានមន្ទីរសន្តិសុខបឹងកន្សែងទទួលបន្ទុកការងារនយោបាយ ។ ចំណែក ឆាង (មានស្រុកកំណើតនៅខេត្តកំពង់ចាម) ជាអនុប្រធានទទួលបន្ទុកយោធា ។ វ៉ាន់ថា ប្រាប់ថាប្រហែលពីម៉ោង៩ដល់ម៉ោង១២អធ្រាត្រនា យប់មួយនោះគាត់បានឃើញកងសន្តិសុខហៅឈ្មោះអ្នកទោសយកទៅសម្លាប់ ។

ដោយសារខ្វះអនាម័យ ការផ្គត់ផ្គង់អាហារមិនគ្រប់គ្រាន់ និងថ្នាំសង្កូវផង បណ្តាលឲ្យអ្នកទោសកើតជំងឺជាច្រើនប្រភេទ ។ អ្នកទោសឈឺធ្ងន់អង្គការមិនបានបញ្ជូនទៅព្យាបាលភ្លាមៗឡើយ ។ ផ្ទុយទៅវិញអ្នកដែលមានជំងឺទាំងប៉ុន្មានត្រូវកងសន្តិសុខចងដៃចងជើងនិងចងក្បាលជង្គង់ រួចយកស្នែងសែងយកទៅសម្លាប់ចោលតែម្តង ។ វ៉ាន់ថា លបមើលព្រឹត្តិការណ៍ទាំងនេះជារៀងរាល់យប់តាមប្រឡោះជញ្ជាំងដែលធ្វើពីរនាបឫស្សី ។

នៅឆ្នាំ១៩៧៩ វ៉ាន់ថា និងអ្នកទោសមួយចំនួនបានរត់ចេញពីមន្ទីរឃុំឃាំងនេះ ក្រោយពេលដែលសន្តិសុខខ្មែរក្រហមភៀសខ្លួនចេញអស់ ។

បច្ចុប្បន្ន អតីតមន្ទីរសន្តិសុខនេះមិនមានបន្សល់ទុកវត្ថុតាងអ្វីបន្តិចឡើយ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ រាយ ជាអតីតមេបញ្ជាការកងអនុសេនាតូចខ្មែរក្រហមឈរជើងនៅតាមព្រំដែនខេត្តរតនគិរី និងប្រទេសវៀតណាមកាលពីឆ្នាំ១៩៧៧ ហើយបច្ចុប្បន្នជាកសិករនៅភូមិ៦ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី បានចង្អុលប្រាប់ដើមខ្នុរ និងដើមដូងជាច្រើនដើមដែលអ្នកទោសបានដាំ ។ នៅឆ្នាំ១៩៨០ រាយ ឃើញសំណល់របងលួសខ្នោះឃ្នាងនិងរនុកដែកជាច្រើនស្ថិតនៅរាយប៉ាយពេញបរិវេណមន្ទីរសន្តិសុខ ។ នៅឆ្នាំ១៩៨៤ អតីតមន្ទីរឃុំឃាំងរបស់ខ្មែរក្រហមនៅបឹងកន្សែងត្រូវអាជ្ញាធរខេត្តរុះរើ ហើយសង់មន្ទីរឃុំឃាំងថ្មីមួយនៅភ្នំស្វាយ ស្ថិតនៅក្នុងភូមិភ្នំស្វាយ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរីជំនួសវិញ ។

## ៣) មន្ទីរសន្តិសុខភូមិ៦

មន្ទីរសន្តិសុខភូមិ៦ ស្ថិតនៅភូមិ៦ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ មន្ទីរនេះបានបន្សល់ទុកនូវសំណង់មន្ទីរសន្តិសុខរបស់ខ្មែរក្រហមមួយនិងវត្ថុតាងជាច្រើន ។ វ៉ាន ឆាយ អាយុ៦៧ឆ្នាំ រស់នៅភូមិ៦ ឃុំឡាបានសៀក ស្រុកបានលុង បាននិយាយថា គាត់បានប្រទះឃើញសំណង់មន្ទីរសន្តិសុខមួយ ផ្ទះបាយមួយខ្នង ដុំដែកមួយដែលធ្វើកាំបិតនិងខ្នោះ ព្រមទាំងផ្ទះសម្រាប់កម្មាភិបាលស្នាក់នៅមួយខ្នងទៀតនៅក្នុងបរិវេណមន្ទីរសន្តិសុខភូមិ៦ ដែលមានបណ្តោយប្រហែល១០០ម៉ែត្រនិងទទឹង៥០ម៉ែត្រ ។ ប៉ុន្តែសព្វថ្ងៃសំណល់វត្ថុតាងទាំងនោះត្រូវរលាយបាត់អស់ហើយ ។

# ក្រុងព្រះសីហនុ

## ខណ្ឌព្រៃនប់

### ១) មន្ទីរសន្តិសុខតានៃ



មន្ទីរសន្តិសុខវាលស្បូវ

មន្ទីរសន្តិសុខតានៃស្ថិតនៅភូមិតានៃ សង្កាត់ជើងគោ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។ រោងវែងធំៗបី-បួនខ្នង និងផ្ទះស្នាក់នៅរបស់កម្មាភិបាលមួយចំនួនទៀត ត្រូវខ្មែរក្រហមសាងសង់ឡើងនៅក្នុងបរិវេណមន្ទីរសន្តិសុខនេះ ។ សួស ញ៉ាន បច្ចុប្បន្នរស់នៅសង្កាត់ជើងគោ ខណ្ឌព្រៃនប់ បានបញ្ជាក់ថា ខ្មែរក្រហមបានហាមឃាត់ប្រជាជនមិនឲ្យដើរឆ្លងកាត់ទីតាំងមន្ទីរសន្តិសុខតានៃឡើយ ។ គង់ សាមឿន បាននិយាយពីការនាំជនរងគ្រោះមកកាន់មន្ទីរសន្តិសុខតានៃថា ក្នុងមួយលើកៗមានចំនួនជាង ១០នាក់ ។ មួយចំនួនត្រូវនាំយកទៅសម្លាប់ក្នុងចម្ការទុរេននិងចម្ការសាវម៉ាវស្ថិតនៅក្នុងភូមិបត់សិរមាន់ សង្កាត់ព្រៃនប់ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។ «មានគ្រូបង្រៀនម្នាក់ដេកក្បែរខ្ញុំត្រូវខ្មែរក្រហមហៅយកទៅទាំងយប់ ដោយប្រាប់ឲ្យទៅដកដើមចចូតយកមកធ្វើកន្ទេល ប៉ុន្តែទៅរហូតមិនឃើញវិលត្រឡប់មកវិញទេ» ។ គង់ សាមឿន នៅចាំបានថា មានគ្រូបង្រៀនជាច្រើននាក់ទៀតត្រូវចាប់ខ្លួនមកដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខតានៃ ក្រោយមកត្រូវនាំយកទៅសម្លាប់ទាំងអស់ ។



មន្ទីរសន្តិសុខទួលចម្ការកៅស៊ូ

នៅក្រោយឆ្នាំ១៩៧៩ គ្រូបង្រៀនប្រមាណ៦០ភាគរយត្រូវខ្មែរក្រហមសម្លាប់ និងស្លាប់ដោយសារជំងឺ ការបង្អត់បាយ និងការបាក់កម្លាំង ។

### ២) មន្ទីរសន្តិសុខវាលស្បូវ

មន្ទីរសន្តិសុខវាលស្បូវស្ថិតនៅក្នុងភូមិព្រែកផ្លាវ សង្កាត់ទឹកល្អក់ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។ សំ ចាន់ អាយុ៥៤ឆ្នាំ ភេទប្រុស ជាអតីតអ្នកទោសនៅក្នុងមន្ទីរសន្តិសុខវាលស្បូវ ។ នៅឆ្នាំ១៩៧៧-៧៨ មុនក្លាយខ្លួនជាអ្នកទោស ចាន់ មានមុខងារជាប្រធានក្រុម ។ នៅចុងឆ្នាំ១៩៧៨ គាត់ត្រូវអង្គការចាប់ខ្លួនដោយចោទប្រកាន់ថា មានជាប់ទាក់ទងរឿងខុសសីលធម៌ ។ នៅពេលកងសន្តិសុខបញ្ជូនទៅដាក់គុកជាលើកដំបូង ចាន់ ដឹងថា មានអ្នកទោសមួយចំនួនត្រូវកងសន្តិសុខយកទៅសម្លាប់រួចទៅហើយ ។ ចាន់ ត្រូវឃ្នុបដាក់ខ្នោះនៅពេលយប់ និងជាប់ច្រវាក់ជើងនៅពេលថ្ងៃព្រោះថាគាត់ត្រូវទៅធ្វើពលកម្មនៅក្រោមន្ទីរឃុំឃាំង ។ ចាន់ បានបន្ថែមថា ជនជាតិវៀតណាមម្នាក់ក៏ត្រូវខ្មែរក្រហមចាប់ខ្លួនមកដាក់គុកនៅមន្ទីរសន្តិសុខវាលស្បូវដែរ ហើយត្រូវបង្ខំឲ្យធ្វើការជាទម្ងន់ ។

ការយកអ្នកទោសម្តងប្រាំនាក់ពីមន្ទីរឃុំឃាំងវាលស្បូវទៅសម្លាប់ចោលបានកើតមានជារៀងរាល់ថ្ងៃ ។ មាស ឃាល ជាអ្នក

ទោសរបស់មន្ទីរនេះបានប្រាប់ឲ្យដឹងថា អ្នកទោសទាំងអស់ត្រូវកេណ្ឌទៅលើកទំនប់នៅក្បាលព្រែក ហើយក្រោយមកត្រូវកងសន្តិសុខនាំយកទៅសម្លាប់នៅចម្ការម្រេចនៅក្នុងបរិវេណមណ្ឌលក្បាលព្រែក ភូមិព្រែកផ្អាវ សង្កាត់ទឹកល្អក់ ខណ្ឌព្រៃនប់ ។



មន្ទីរសន្តិសុខទួលចម្ការកៅស៊ូ

### ៣) មន្ទីរសន្តិសុខទួលចម្ការកៅស៊ូ

ចម្ការកៅស៊ូ ដែលស្ថិតនៅក្នុងភូមិព្រៃនប់ទី៣ សង្កាត់ព្រៃនប់ ខណ្ឌព្រៃនប់ គឺជាទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហម ។ មុននឹងធ្វើការសម្លាប់អ្នកទោសទាំងអស់សុទ្ធតែត្រូវខ្មែរក្រហមនាំមកដាក់ឃុំឃាំងបណ្តោះអាសន្ននៅក្នុងអតីតបរិវេណមន្ទីរពេទ្យនិងនៅក្នុងវត្តមួយរយៈសិន ហើយទីតាំងទាំងពីរនេះស្ថិតនៅក្នុងបរិវេណចម្ការកៅស៊ូដូចគ្នា ។ ឡឹង សាម៉េន ជាអនុប្រធានសង្កាត់ព្រៃនប់ បានរាយការណ៍ថា នៅខាងក្រោយសាលារៀនដែលជាអតីតមន្ទីរពេទ្យរបស់ខ្មែរក្រហមមានប្រជាជនជាច្រើននាក់បាននាំគ្នាមកកាស់រណ្តៅសាកសពដើម្បីរកមាស ។

### ៤) មន្ទីរសន្តិសុខកោះខ្យង



មន្ទីរសន្តិសុខកោះខ្យង

មន្ទីរសន្តិសុខកោះខ្យង ស្ថិតនៅក្នុងភូមិកោះខ្យង សង្កាត់អូរជ្រៅ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។

នៅឆ្នាំ១៩៧៩ អតីតមន្ទីរសន្តិសុខកោះខ្យងរបស់ខ្មែរក្រហមមានបន្សល់ទុកសំណង់មន្ទីរឃុំឃាំងចំណាស់មួយនិងមន្ទីរតូចៗមួយចំនួនស្ថិតនៅជុំវិញ ព្រមទាំងខ្ទះឃ្នាងជាច្រើនដែលស្ថិតនៅរាយប៉ាយពាសពេញទីនោះ ។ កោះខ្យងមានទំហំដីប្រមាណ ២គីឡូម៉ែត្រការេ ។ បច្ចុប្បន្ននេះ សំណង់និងខ្ទះឃ្នាងទាំងប៉ុន្មានត្រូវប្រជាជនកម្ទេចចោលទាំងអស់ ហើយយកទីតាំងនេះសង់លំនៅដ្ឋាន ។

ក្នុងរបបខ្មែរក្រហម កោះខ្យងគឺជាមន្ទីរសន្តិសុខធំមួយនៅក្រុងព្រះសីហនុ ក្រោមការគ្រប់គ្រងដ៏តឹងរ៉ឹងរបស់ឈ្មោះ សឿន ។ អ្នកទោសច្រើននាក់ណាស់ដែលខ្មែរក្រហមចាប់ខ្លួនមកដាក់ក្នុងមន្ទីរឃុំឃាំងនេះ ទោះបីជាមានកំហុសបន្តិចបន្តួចក៏ដោយ ។ ទូច ស៊ីនឿន អាយុ៤២ឆ្នាំ ជាស្នងការនគរបាលក្រុងព្រះសីហនុ ជាអ្នកទោសរបស់មន្ទីរនេះបានឲ្យដឹងថា ទោសកំហុសរបស់គាត់កើតឡើងដោយសារគាត់ទទួលដំឡូងមីមួយមើមពីមិត្តភក្តិម្នាក់ឈ្មោះ គៀន មកលាក់ទុកនៅក្បាលដំណេក ។

អគារមួយធំជាងគេនៅក្នុងបរិវេណមន្ទីរសន្តិសុខកោះខ្យង គឺជាកន្លែងដែល ស៊ីនឿន ជាប់ឃុំឃាំងដំបូងបង្អស់មុននឹងត្រូវបញ្ជូនបន្តទៅកាន់មន្ទីរមួយទៀត ដែលខ្មែរក្រហមហៅថា ជាមន្ទីររៀនសូត្រ អប់រំកែប្រែ និងលត់ដំការងារ ។ មន្ទីរសន្តិសុខកោះខ្យងមានអគារឃុំឃាំងចំនួន៤ខ្នង ។ អគារធំជាងគេដែលប្រក់ស័ង្កសីនិងជញ្ជាំងស័ង្កសីដែរនោះគឺជាកន្លែងឃុំឃាំងអ្នកទោសកម្រិតធ្ងន់

ហើយមួយផ្នែកនៃអគារនេះគឺជាកន្លែងសួរចម្លើយ ។ អ្នកទោសប្រភេទនេះមិនត្រូវបានដោះខ្នោះចេញឲ្យមកធ្វើការនៅខាងក្រៅឡើយ ។ ចំណែកមន្ទីរបីទៀត គឺជាកន្លែងលត់ដំការងារ និងជាកន្លែងដាក់អ្នកទោសកម្រិតស្រាល ។ អ្នកទោសត្រូវឆ្នាំគុកដាក់ខ្នោះនិងច្រវាក់ជាប់រហូតទោះជានៅពេលបំពេញការងារ បន្ទោរបង់ផ្ទុតទឹក និងហូបបបរក៏ដោយ ។ អ្នកទោសត្រូវបន្ទោរបង់នៅនឹងកន្លែងសម្រាករបស់ខ្លួនតែម្តងដោយគ្រាន់តែកាយដីកប់វិញប៉ុណ្ណោះ ។ ចំណែកឯរបបបបរ អ្នកទោសបានទទួលតែមួយកូនចានប៉ុណ្ណោះ ហើយពេលហូបម្តងៗខ្មែរក្រហមបានកំណត់ពេលវេលាទៀត ព្រោះត្រូវយកចានដាក់របបទៅឲ្យអ្នកទោសម្នាក់ទៀត ។ ខ្មែរក្រហមធ្វើបែបនេះលុះត្រាអ្នកទោសទាំងអស់បានហូបគ្រប់គ្នា ។ ស៊ី នឿន បានប្រាប់ថា ប្រសិនបើអ្នកទោសណាម្នាក់ហូបរបបរបស់ខ្លួនមិនទាន់អស់ ហើយដល់ម៉ោងដែលខ្មែរក្រហមកំណត់យកចានបបរនឹងត្រូវដកហូតមកវិញដែរ ហើយយកទៅឲ្យអ្នកទោសម្នាក់ទៀត ។ ការសួរចម្លើយអ្នកទោសកម្រិតស្រាលបានធ្វើឡើងរៀងរាល់មួយសប្តាហ៍ម្តង ។ ចំណែកអ្នកទោសកម្រិតធ្ងន់ត្រូវកងសន្តិសុខសួរចម្លើយមួយថ្ងៃបីដងជាមួយនឹងទារុណកម្មយ៉ាងព្រៃផ្សៃ ។ ប៉ាក សំឌិន អាយុ៤៨ឆ្នាំ ជាអតីតអ្នកទោសនៅក្នុងមន្ទីរសន្តិសុខកោះខ្សែងដែលត្រូវបានចោទប្រកាន់ពីបទថា បានលួចស្រូវសមូហភាព បាននិយាយពីបម្រាមក្នុងពេលសួរចម្លើយថា ខ្មែរក្រហមហាមមិនឲ្យនិយាយច្រើន បើសួរត្រង់ណាត្រូវតែឆ្លើយត្រង់ហ្នឹង ។ សំឌិន បញ្ជាក់ពីរឿងនោះថា តាមពិតគាត់ដើរចូលក្នុងព្រៃដើម្បីរកបេះផ្លែឈើយកមកទុកហូប ។ ប៉ុន្តែចៃដន្យគាត់បានជួបនឹងកម្មាភិបាលខ្មែរក្រហមនៅទីនោះ ហើយក៏ត្រូវចាប់ខ្លួនតែម្តង ។ សំឌិន ត្រូវបានចាប់ខ្លួននៅដើមឆ្នាំ១៩៧៧ ។ នៅពេលកងសន្តិសុខបញ្ជូនគាត់មកកាន់មន្ទីរសន្តិសុខកោះខ្សែង សំឌិន ឃើញរថយន្តខ្មែរក្រហមដឹកប្រជាជនជាច្រើនទៅកាន់មន្ទីរសន្តិសុខកោះខ្សែងដូចគាត់ដែរ ។ ស៊ី នឿន ត្រូវអ្នកសួរចម្លើយសួរម្តងដែរ ប៉ុន្តែមិនទទួលរងទណ្ឌកម្មធ្ងន់ធ្ងរឡើយ ដោយសារគាត់ឆ្លើយទៅតាមអ្វីដែលខ្មែរក្រហមចង់បាន ។ ពេលធ្វើទារុណកម្ម ខ្មែរក្រហមបានប្រើកៅស៊ូភ្ជៀងរុំមុខ រំពាត់ ព្រនង់ ផ្តៅ ពូថៅ និងខ្សែភ្លើងសម្រាប់ឆក់ ។ អ្នកទោសខ្លះត្រូវស្លាប់នៅក្នុងពេលសួរចម្លើយ ហើយខ្លះទៀតត្រូវរងរបួសជាទម្ងន់ ។ ចំណែកអ្នកទោសដែលពុំទាន់សួរចម្លើយក៏មានស្លាប់ជាច្រើនដែរដោយសារការបង្អត់អាហារនិងជំងឺ ។

អ្នកទោសស្ទើរតែទាំងអស់ត្រូវកងឈ្លបខ្មែរក្រហមនាំមកកាន់មន្ទីរសន្តិសុខនៅពេលយប់ ហើយដាក់ឃុំឃាំងទៅតាមប្រភេទកំហុសរបស់អ្នកទោសម្នាក់ៗ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយក៏នៅមានអ្នកទោសកម្រិតធ្ងន់ខ្លះត្រូវឆ្នាំគុកបញ្ជូនទៅកាន់មន្ទីរឃុំឃាំងកម្រិតស្រាលដែរ ព្រោះអ្នកទាំងនោះបានកែប្រែខ្លួនទៅតាមមាគ៌ាបដិវត្តន៍បានឆាប់រហ័ស ។ ការងារដែលអ្នកទោសត្រូវធ្វើគឺដាំដំឡូង ធ្វើបង្គី និងការងារផ្សេងៗទៀត ។ កងសន្តិសុខខ្មែរក្រហម ដើរឃ្លាំមើលអ្នកទោសបំពេញការងារជានិច្ច ។ បន្ទាប់ពីជាប់គុកធំអស់រយៈពេល២ខែ ស៊ី នឿន ត្រូវបានបញ្ជូនទៅកាន់មន្ទីរទី២អស់រយៈពេល៧ខែទៀត ។ ចុងក្រោយបង្អស់ ទើបអង្គការបញ្ជូនទៅដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខតានៃ ។ សំឌិន បានរៀបរាប់ពីសកម្មភាពនៅក្នុងមន្ទីរឃុំឃាំងថា គាត់ឃើញខ្មែរក្រហមវះពោះអ្នកទោសលូកយកថ្លើមរួចយកសាកសពទៅបោះចោលក្នុងរណ្តៅ ។ ជួនកាល សំឌិន ឃើញអ្នកទោសត្រូវកងឈ្លបកាត់ក្បាលចេញពីដងខ្លួនទៀតផង ។ មានអ្នកទោសពីរនាក់បានលួចរត់ចេញពីមន្ទីរឃុំឃាំង ប៉ុន្តែកងសន្តិសុខចាប់ខ្លួនបានមកវិញ ហើយវះពោះយកថ្លើមមកស្ងោរស្លឹកថ្នឹង ។

គាំ យោ អាយុ៥៧ឆ្នាំ ធ្លាប់ជាប់គុកនៅមន្ទីរសន្តិសុខកោះខ្សែងអស់រយៈពេល៣ឆ្នាំ ដោយសារតែគាត់លួចបេះផ្លែស្វាយហូប ។ ឈ្មោះ មិត្ត និងបក្ខពួកបានចាប់គាត់ពីចម្ការស្វាយយកទៅកាន់សហករណ៍ ហើយបន្ទាប់មកត្រូវបញ្ជូនទៅកាន់មន្ទីរសន្តិសុខកោះខ្សែងទៀត ។ គាំ យោ និយាយថា ជនរងគ្រោះជាច្រើនត្រូវខ្មែរក្រហមដឹកតាមរថយន្តមកកាន់មន្ទីរសន្តិសុខកោះខ្សែងនៅក្នុងឆ្នាំ១៩៧៦ និងបន្តរហូតដល់ឆ្នាំ១៩៧៧ទៀត ដែលក្នុងមួយថ្ងៃៗមានរថយន្តដឹកអ្នកទោសមកកាន់ទីនេះពី៣ទៅ៥គ្រឿង ។ អ្នកទោសទាំងអស់ដែលជាប់នៅមន្ទីរសន្តិសុខកោះខ្សែងមានចំនួនរាប់ពាន់នាក់ដែលភាគច្រើនខ្មែរក្រហមប្រមូលមកពីស្រុកស្រែអំបិល ខេត្តកោះកុង និងជុំវិញក្រុងកំពង់សោម ។ មន្ទីរសន្តិសុខកោះខ្សែង ឃុំឃាំងអ្នកទោស បុរស ស្ត្រី និងក្មេងដោយឡែកពីគ្នា ។

ឡេង យាន អាយុ៤៤ឆ្នាំ សព្វថ្ងៃរស់នៅក្នុងខណ្ឌព្រៃនប់បាននិយាយថា កងសន្តិសុខតែងនាំយកអ្នកទោសពី៣ទៅ៥នាក់ទៅសម្លាប់ចោលជារៀងរាល់យប់ ។ ការសម្លាប់មនុស្សច្រើនធ្វើឡើងតាមវិធីដដែលៗ គឺវះពោះយកថ្លើមនិងប្រមាត់ ។ យាន បានបញ្ជាក់ថា គាត់បានឃើញកងសន្តិសុខហាលប្រមាត់មនុស្សក្បែររណ្តៅសាកសព ។


មន្ទីរសន្តិសុខតាសេក

នៅចុងឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមដែលប្រចាំការនៅមន្ទីរសន្តិសុខកោះខ្យងបាននាំគ្នាដកថយ ខ្លះទទួលបញ្ជាឲ្យទៅទប់ទល់ជាមួយកងទ័ពរណសិរ្សនិងខ្លះទៀតរត់យករួចខ្លួនតែម្តង ។ ចំណែកអ្នកទោសត្រូវខ្មែរក្រហមដឹកតាមត្រាក់ទ័រយកទៅកាន់មន្ទីរសន្តិសុខតានៃបន្តទៀត ប៉ុន្តែមានអ្នកទោសច្រើននាក់ណាស់ត្រូវបានសម្លាប់និងស្លាប់ដោយសារជំងឺនៅតាមផ្លូវ ។ ស៊ុំ នឿន និយាយថា ក្នុងចំណោមអ្នកទោសទាំង១៨៣នាក់ មានតែអ្នកទោស១៣នាក់ប៉ុណ្ណោះដែលមានជីវិតត្រឡប់មកវិញ ។

បច្ចុប្បន្ននេះ មន្ទីរសន្តិសុខកោះខ្យងត្រូវប្រជាជនក្នុងភូមិសង់លំនៅដ្ឋានពាសពេញ ។ ក៏ប៉ុន្តែដើមដូងជាច្រើនដើមដែលខ្មែរក្រហមដាំត្រូវបានរក្សាទុកដើម្បីជាចំណុចសម្គាល់ថាជាទីតាំងមន្ទីរសន្តិសុខកោះខ្យង ។

### ៥) មន្ទីរសន្តិសុខតាសេក ហៅ អូរកំបុត

មន្ទីរសន្តិសុខអូរកំបុតស្ថិតនៅភូមិអូរតាសេក សង្កាត់អូរខកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។ មន្ទីរសន្តិសុខនេះមានរោងធំៗចំនួន៣ខ្នង ស្ថិតនៅចំកណ្តាលរោងតូចៗមួយចំនួនទៀតដែលជាកន្លែងស្នាក់នៅរបស់កងសន្តិសុខនិងមន្ទីរធ្វើការរបស់កម្មាភិបាលខ្មែរក្រហម ។ ទ្រា មិនថូ អាយុ៤៨ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងសង្កាត់អូរខកញ៉ាហេង ខណ្ឌព្រៃនប់ប្រាប់ថា បន្ទាប់ពីថ្ងៃរំដោះឆ្នាំ១៩៧៩គាត់ឃើញរោងធំៗទាំង៣នេះនៅមានទ្រង់ទ្រាយដូចដើមទាំងអស់ ។

កាលពីជំនាន់ខ្មែរក្រហម រោងធំជាងគេក្នុងចំណោមរោងទាំងបីគឺជាមន្ទីរឃុំឃាំង ។ នៅខាងក្រោយរោងធំនេះចម្ងាយប្រហែល១០០ម៉ែត្រមានរោងមួយទៀតជាមន្ទីរសួរចម្លើយអ្នកទោស និងមានដើមឈើធំៗពីរដើមសម្រាប់ចងអ្នកទោសធ្វើទារុណកម្ម ។ នៅជាប់មែកឈើមានចងខ្សែពួរមួយ ឬពីរខ្សែទៀតដើម្បីព្យួរ-កអ្នកទោស ។ មិនថូ និយាយថា ក្រោយឆ្នាំ១៩៧៩ គាត់ឃើញមានស្នាមឈាមជាប់នឹងដើមឈើទាំងពីរនេះ ។ អ្នកទោសភាគច្រើនត្រូវកងសន្តិសុខនាំយកទៅសម្លាប់នៅទីតាំងពិឃាតមួយស្ថិតនៅចម្ងាយប្រហែល ២០០ម៉ែត្រពីមន្ទីរសន្តិសុខ ។

**ផេង ពង្សរ៉ាស៊ី**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# ពីអំពើហិង្សានៅរកការទទួលខុសត្រូវ

ប្រជាជនប្រមាណពីរលាននាក់បានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម (១៩៧៥ដល់ឆ្នាំ១៩៧៩) ។ ក៏ប៉ុន្តែរយៈពេលជិត៣០ឆ្នាំកន្លងទៅនេះ ជនរងគ្រោះភាគច្រើននៅតែមិនយល់ថាហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្សច្រើនយ៉ាងនេះ ហើយប្រជាជនពិបាកនឹងជឿថា ខ្មែរហ៊ានសម្លាប់ខ្មែរដូចគ្នាយ៉ាងនេះ ។

រយៈពេលជាច្រើនឆ្នាំបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ យុត្តិធម៌តាមផ្លូវច្បាប់សម្រាប់អំពើឃោរឃៅដែលបានប្រព្រឹត្តឡើងដោយខ្មែរក្រហមមិនទាន់កើតមាននៅឡើយទេ ដោយសារតែប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល ។ សហគមន៍អន្តរជាតិបានបង្វែរការចាប់អារម្មណ៍របស់ខ្លួនទៅលើសង្គ្រាមត្រជាក់វិញ ហើយមិនបានជួយធ្វើអន្តរាគមន៍ដើម្បីបញ្ឈប់អំពើហិង្សានៅក្នុងប្រទេសកម្ពុជា និងក៏មិនបានជួយប្រទេសកម្ពុជាឲ្យមានស្ថិរភាពដែរ ។ ពេលវេលាជិតពីរទសវត្សរ៍បានកន្លងផុត មុនពេលរាជរដ្ឋាភិបាលកម្ពុជាស្នើសុំស្វែងបង្កើតតុលាការពិសេសមួយដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា ។

យុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាគឺមិនមែនគ្រាន់តែជាតុលាការចម្រុះមួយដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០០៦ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនតូចប៉ុណ្ណោះទេ ប៉ុន្តែមានវិធីផ្សេងៗទៀតដែលអាចជាជំនួយក្នុងការបំពេញបន្ថែមដល់កិច្ចខិតខំប្រឹងប្រែងរបស់តុលាការខ្មែរក្រហមនិងនាំយកយុត្តិធម៌តាមរូបភាពមួយជូនជនរងគ្រោះ ។ បន្ទាប់ពីសេចក្តីផ្តើមដោយសង្ខេបអំពីរបបនេះ សំណេរនេះនឹងស្វែងរកមូលហេតុដែលខ្មែរក្រហម (ជាពិសេសកម្មាភិបាលថ្នាក់ក្រោម) សម្លាប់មនុស្ស ហើយនឹងបញ្ចប់ដោយគំនិតមួយចំនួនដែលថាតើត្រូវដាក់ឲ្យឧក្រិដ្ឋជនទាំងនេះទទួលខុសត្រូវរបៀបណា និងថាតើត្រូវនាំយកយុត្តិធម៌និងការផ្សះផ្សាជាតិបែបណាសម្រាប់សង្គមកម្ពុជា ។

## ប្រវត្តិសង្ខេប

បន្ទាប់ពីអាណានិមនិយមបារាំងបានបញ្ចប់ ប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់របបសង្គមរាស្ត្រនិយមដែលដឹកនាំដោយសម្តេច ព្រះនរោត្តម សីហនុ ដែលប្រជាជនរស់នៅប្រកបដោយសុខសន្តិភាព ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាមិនអាចគេចផុតពីឥទ្ធិពលនៃសង្គ្រាមត្រជាក់ឡើយ ថ្វីបើសម្តេចព្រះនរោត្តម សីហនុ បានរក្សាជំហរនយោបាយអព្យាក្រឹតក៏ដោយ ។ ព្រះអង្គគាំទ្រប្រទេសកុម្មុយនីស្តដោយអនុញ្ញាតឲ្យវៀតណាមខាងជើងបោះទីតាំងលើទឹកដីកម្ពុជា ហើយវាយប្រយុទ្ធជាមួយវៀតណាមខាងត្បូង ។ នៅខណៈពេលដែលគេស្តីឈ្មោះព្រះអង្គចុះអន់ថយ ឧត្តមសេនីយ៍របស់ព្រះអង្គឈ្មោះ លន់ នល់ បានធ្វើរដ្ឋប្រហារប្រឆាំងព្រះអង្គដោយជោគជ័យ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។

រដ្ឋាភិបាលលន់ នល់ បានបន្តសង្គ្រាមស៊ីវិលបង្ហូរឈាមជាមួយពួកកុម្មុយនីស្ត (ដែលត្រូវបានទទួលស្គាល់ថាជាខ្មែរក្រហម) អស់រយៈកាលជិត៥ឆ្នាំនៃការគ្រប់គ្រងរបស់ខ្លួនពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ។ បដិវត្តន៍នេះបានទទួលការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាជនក្រីក្រ ដែលជួយឲ្យខ្មែរក្រហមផ្តួលរំលំរដ្ឋាភិបាលលន់នល់បាន ។ ខ្មែរក្រហមបានឲ្យឈ្មោះខ្លួនឯងជាផ្លូវការថា «បក្សកុម្មុយនីស្តកម្ពុជា» ដែលបានគ្រប់គ្រងប្រទេសចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ បន្ទាប់ពីដណ្តើមអំណាចបានភ្លាម ខ្មែរក្រហមបានបង្ខំប្រជាជនជិតពីរលាននាក់ដែលធ្លាប់រស់នៅក្នុងទីក្រុងនិងទីរួមខេត្តផ្សេងៗឲ្យទៅកាន់ទីជនបទដើម្បីចាប់ផ្តើមប្រកបការងារកសិកម្ម ។ ប្រជាជនរាប់ពាន់នាក់បានស្លាប់នៅក្នុងអំឡុងពេលផ្លាស់ប្តូរទីកន្លែងរស់នៅ ។

ខ្មែរក្រហមបានប្រកាន់យកគំនិតកុម្មុយនីស្ត ដោយបានផ្លាស់ប្តូរប្រទេសកម្ពុជាឲ្យទៅជាសង្គមជនបទដែលគ្មានវណ្ណៈ គ្មានអ្នកមាន និងគ្មានអ្នកក្រ ។ ខ្មែរក្រហមបានលុបបំបាត់ចោលនូវរូបិយវត្ថុ ទីផ្សារសេរី សាលារៀន ទ្រព្យសម្បត្តិឯកជន សម្លៀកបំពាក់បែបបរទេស ការគោរពប្រណិប័តន៍សាសនា និងវប្បធម៌ប្រពៃណី ។ សាលារៀននិងមហាវិទ្យាល័យ ទីសក្ការបូជា វិស័យ

ជិនួញផ្សេងៗ និងអគាររដ្ឋាភិបាលត្រូវបានបិទទ្វារ ឬប្រែក្លាយឲ្យទៅជាគុក កន្លែងលត់ដំ ឬឃ្លាំងផ្សេងៗ ។ គ្មានមធ្យោបាយធ្វើដំណើរសមរម្យសម្រាប់អ្នកដែលមិនមែនជាកម្មាភិបាលខ្មែរក្រហមទេ ។ ការកម្សាន្តនានាត្រូវបានហាមឃាត់ ហើយមានតែការសម្តែងសិល្បៈជាផ្លូវការប៉ុណ្ណោះទើបត្រូវបានអនុញ្ញាតឲ្យទស្សនា ហើយសិល្បៈនោះសោតសុទ្ធតែបង្កប់នូវការឃោសនាមនោគមវិជ្ជាថែមទៀត ។

មេដឹកនាំខ្មែរក្រហមបានព្យាយាមកែប្រែប្រទេសកម្ពុជាដោយផ្លាស់ប្តូរនូវអ្វីដែលខ្មែរក្រហមយល់ថា ជាឧបសគ្គសេរីភាពជាតិនិងយុត្តិធម៌សង្គមទៅជាបដិវត្តន៍ដោយកម្ចាំងនិងស្មារតី ។ ដោយសារតែជឿជាក់ថា ប្រជាជនក្រីក្របានទទួលរងការជិះជាន់សង្កត់សង្កិននិងត្រូវចាត់ទុកជាទាសករ ខ្មែរក្រហមបានស៊ូះស្វែងដើម្បីរំដោះនិងផ្តល់អំណាចដល់ប្រជាជនឡើងវិញដើម្បីឲ្យខ្លួនបានក្លាយជាម្ចាស់លើខ្លួនឯងក្នុងការរស់នៅក្នុងសង្គមជាតិ ។

ខ្មែរក្រហមបានផ្តល់បុព្វសិទ្ធិឲ្យប្រជាជនមូលដ្ឋាន (ប្រជាជនដែលរស់នៅក្នុងតំបន់ដែលខ្មែរក្រហមកាន់កាប់មុនឆ្នាំ១៩៧៥) ដែលភាគច្រើនជាប្រជាជនក្រីក្រ ។ ប្រជាជន១៧មេសា ឬប្រជាជនថ្មី ត្រូវបានបង្ខំឲ្យធ្វើការធ្ងន់និងជាមុខសញ្ញាដែលត្រូវសម្លាប់ ។ ខ្មែរក្រហមក៏បានសម្លាប់កងទ័ពនិងសមាជិកបក្សរបស់ខ្លួនជាច្រើន ដោយចោទប្រកាន់ថាជាជនក្បត់ឬប្រឆាំងនឹងអង្គការ ។ បច្ចុប្បន្នមេដឹកនាំខ្មែរក្រហមនៅតែបដិសេធមិនទទួលខុសត្រូវចំពោះការសម្លាប់ទាំងនេះទេ ។ មេដឹកនាំខាងលើនិយាយថា កម្មាភិបាលថ្នាក់ក្រោមជាអ្នកអនុវត្តការសម្លាប់ដោយខ្លួនឯង ។ ក៏ប៉ុន្តែកម្មាភិបាលទាំងនេះភាគច្រើននិយាយថាខ្លួនអនុវត្តតាមតែបញ្ជារបស់មន្ត្រីថ្នាក់ខ្ពស់ប៉ុណ្ណោះ ។

## មូលហេតុនៃការសម្លាប់

អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ មីសែល តូស៊ីក បង្កើតទស្សនៈនៃអំពើហិង្សាមួយតាមរយៈការវិភាគទំនាក់ទំនងរវាងមន្ត្រីរបស់ក្រុមហ៊ុនអាណានិគមមួយនិងជនជាតិឥណ្ឌាអាមេរិកខាងត្បូង (ជនជាតិដើមរបស់អាមេរិក) ។ កម្មករឥណ្ឌាជាច្រើនដែលធ្វើការប្រមូលជ័រកៅស៊ូឲ្យក្រុមហ៊ុនត្រូវបានបង្ខំឲ្យធ្វើការទាំងថ្ងៃទាំងយប់ ហើយទទួលទារុណកម្មទៀតផង (មួយចំនួននៃអ្នកដែលរងទារុណកម្ម ត្រូវចងឆ្កាងសំយុងក្បាលចុះក្រោម) ។ជួនកាលជនដៃដល់ជាពួកស្បែកស បានសម្លាប់កម្មករឥណ្ឌាដោយកាត់ជាបំណែកៗនិងសម្លាប់កូនអ្នកទាំងនោះដោយវាយបោកទៅនឹងដើមឈើឬជញ្ជាំង ។ មនុស្សចាស់ដែលធ្វើការមិនកើតក៏ត្រូវបានសម្លាប់ ហើយសាកសពត្រូវយកធ្វើជាអាហារសម្រាប់ឆ្កែរបស់ក្រុមហ៊ុន ។

តើយើងត្រូវឆ្លើយតបយ៉ាងដូចម្តេច ក្នុងនាមជាអ្នកបានឃើញហេតុការណ៍គួរឲ្យរន្ធត់ទាំងអស់នេះ? យើងទាំងអស់គ្នាមុខជាចង់និយាយថាអ្នកដែលប្រព្រឹត្តអំពើរន្ធត់បែបនេះគួរតែត្រូវផ្តន្ទាទោស ។ ក៏ប៉ុន្តែមានទស្សនៈផ្សេងទៀតយល់ថា ជនសង្ស័យដែលជាជនដៃដល់ទាំងនោះមានអារម្មណ៍ថាខ្លួនធ្វើឡើងដោយមានហេតុផលមួយត្រឹមត្រូវ ។ តូស៊ីក កត់សម្គាល់ថា បុគ្គលិកក្រុមហ៊ុនរស់នៅក្នុងភាពភ័យខ្លាចចំពោះការស្លាប់ដោយសារការវាយប្រហារ ការរៀបចំផែនការ ការបះបោរ និងការក្បត់ ។ ជាងនេះទៅទៀតបុគ្គលិកទាំងនោះកាន់តែមានការភ័យខ្លាចបន្ទាប់ពីបានឮរឿងរ៉ាវថាជនជាតិឥណ្ឌាស៊ីសាច់មនុស្ស ។ ដើម្បីការពារខ្លួនឯង បុគ្គលិកទាំងនោះគិតថាខ្លួនចាំបាច់ត្រូវតែសម្លាប់ ។ និយាយសរុបចេញពីករណីនេះ ពេលមនុស្សរស់ក្នុងពិភពមួយដែលភ័យខ្លាច វិធីតែមួយដែលដើម្បីអាចជួយសង្គ្រោះខ្លួនឯងគឺត្រូវប្រព្រឹត្តអំពើអាក្រក់ទាំងនោះ ។ ពេលណាដែលមនុស្សប្រឈមមុខនឹងសេចក្តីស្លាប់ វាជាប្រតិកម្មពីធម្មជាតិមួយដើម្បីតបតវិញការពារជីវិតរស់នៅរបស់ពួកគេ ។

ទស្សនៈនេះក៏អាចឆ្លើយតបទៅនឹងរបបខ្មែរក្រហមដែលកម្មាភិបាលខ្មែរក្រហមទាំងនោះគិតថា ខ្លួនក៏ជាជនរងគ្រោះនិងរស់នៅដោយភ័យខ្លាចជានិច្ច ។ ស្ត្រីនិងបុរសដែលធ្វើការនៅក្នុងកន្លែងជាមួយគ្នា បានរាយការណ៍ពីគ្នាទៅវិញទៅមកដើម្បីសង្គ្រោះជីវិតខ្លួនឯង ។ កម្មាភិបាលជិត៦០០នាក់ក្នុងចំណោមកម្មាភិបាលចំនួន១៧០០នាក់ដែលធ្វើការនៅមន្ទីរគុកសម្ងាត់ស-២១ត្រូវបានសម្លាប់ ។ មានការបោសសម្អាតមួយចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៩៧៧ ហើយអ្នកប្រវត្តិសាស្ត្រជាច្រើនជឿថា ប្រសិនបើគ្មានវត្តមានវៀតណាមមកដល់ទីក្រុងភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩ ទេ ការបោសសម្អាតនេះទំនងជានៅតែបន្ត ។

កម្មាភិបាលខ្មែរក្រហមជាច្រើនព្រួយបារម្ភអំពីជោគវាសនារបស់ខ្លួន នៅពេលដែលឃើញមិត្តភក្តិរបស់ខ្លួនត្រូវបានយកទៅសម្លាប់ ។ អ្នកទាំងនេះព្យាយាមសម្តែងភាពស្មោះត្រង់របស់ខ្លួនជូនបក្សដោយប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើន ហើយបើមិនធ្វើដូច្នោះទេអ្នកទាំងនេះត្រូវបានចាត់ទុកថាជាសត្រូវនឹងត្រូវយកទៅសម្លាប់ដូចជាជនរងគ្រោះដែលខ្លួនបានសម្លាប់ដែរ ។

នៅពីក្រោយជម្លោះនិងអំពើហិង្សា ភាពភ័យខ្លាចនិងមន្ទិលសង្ស័យក៏កើតមានក្នុងចំណោមមេដឹកនាំខ្មែរក្រហមដែរ ។ ដូចប៊ុន ចាន់ម៉ុល បាននិយាយថា មេដឹកនាំខ្មែរក្រហមមិនដែលទុកចិត្តអ្នកដែលធ្វើការជាមួយខ្លួនទេ ។ មេដឹកនាំទាំងនោះភ័យខ្លាចថាសហការីរបស់ខ្លួននឹងសម្លាប់និងដណ្តើមតំណែងរបស់ខ្លួន ។ ការបោសសម្អាតរបស់មេដឹកនាំខ្មែរក្រហមក្នុងរវាងឆ្នាំ១៩៧៧និងឆ្នាំ១៩៧៨ គឺជាលទ្ធផលកើតចេញពីការភ័យថានឹងមានរដ្ឋប្រហារផ្តួលរំលំមួយ ដូច្នេះមេដឹកនាំខ្មែរក្រហមបានចាប់ផ្តើមចាប់សត្រូវរបស់ខ្លួន ។ ហេតុដូច្នេះខ្មែរក្រហមបែងយ៉ាងច្បាស់រវាង «ពួកយើង» និង «ពួកគេ» ដើម្បីធានាថា «ពួកយើង» រស់ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ «ពួកយើង» សំដៅទៅលើប្រជាជាតិ ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងក្រុមអ្នកស្រែចម្ការ ក្រុមបដិវត្តន៍ កងទ័ព និងប្រព័ន្ធប្រមូលផ្តុំ ។ «ពួកគេ» រួមបញ្ចូលទាំងក្រុមចក្រពត្តិនិយម និងសមាជិកក្រុមមូលធន-សក្តិភូមិនិយម ដូចជាវណ្ណៈពូជពង្សក្សត្រ ក្រុមដែលធ្លាប់បម្រើក្នុងរបបលន់នល់ អ្នកមាន និងអ្នកដែលរស់នៅទីក្រុងឬនៅតាមទីរួមខេត្ត ។ នៅក្នុងទស្សនៈរបស់ខ្មែរក្រហម ក្រុមក្រោយៗនេះសុទ្ធតែមានគ្រោះថ្នាក់ និងត្រូវបំផ្លាញប្រសិនបើរបបនេះចង់នៅមានជីវិតយូរអង្វែង ។

ក្នុងការអនុវត្តន៍ការសម្លាប់មនុស្សដ៏ច្រើននេះ ជនដៃដល់បានប្រព្រឹត្តដូចតាមការរៀបរាប់ពន្យល់របស់ អាប៉ាឌូរ៉ៃ (Appadurai) ថាវាគឺជាកត្តាចាំបាច់ដំបូងដើម្បីបន្ទាបសត្រូវឲ្យមានតម្លៃទាបជាងមនុស្ស ។ ដោយបង្កើតនូវការបែងចែកយ៉ាងច្បាស់រវាងជនដៃដល់និងជនរងគ្រោះ វាជាការងាយស្រួលក្នុងការបង្ហាញឲ្យឃើញថា ជនរងគ្រោះទាំងអស់នោះមានជីវិតដូចសំរាមឬជីវិតដែលមានឋានៈទាបនៅក្នុងសង្គម ។ ជនដៃដល់របស់មន្ទីរឃុំឃាំងស-២១បានធ្វើឲ្យអ្នកទោសក្លាយទៅជាមនុស្សដែលមានឋានៈជាសត្វ ។ ជនរងគ្រោះមានក្លិនខ្លួនមិនល្អ កើតចៃចេញពីស្បែក និងរូបកាយស្គមស្គាំង ស្ថិតក្នុងស្ថានភាពបែបនេះវាគ្រប់គ្រាន់ណាស់ទៅហើយដែលឲ្យកម្មាភិបាលខ្មែរក្រហមវាយតម្លៃអ្នកទោសទាបជាងមនុស្សទៅទៀតនោះ ។ អ្នកសួរចម្លើយនិងសន្តិសុខគុកបានហៅអ្នកទោសទាំងនោះថា «វា» ជាបុរិសសព្វនាមដែលបង្ហាញពីការបន្ថុះបន្ថោក ព្រោះពាក្យនេះប្រើសម្រាប់តែហៅសត្វប៉ុណ្ណោះ ។ ពេលខ្លះអ្នកទោសទាំងនោះត្រូវបានបង្ខំឲ្យគោរពរូបសត្វឆ្កែ (ដែលប្រជាជនខ្មែរចាត់ទុកថាជាពពួកសត្វថ្នាក់ជាន់ទាប) ហើយនៅពេលអ្នកទោសធ្វើតាមបែបនេះហាក់ដូចជាឲ្យអ្នកសួរចម្លើយទាំងនោះវាយតម្លៃខ្លួនថាជា «មនុស្សថោកទាប» ដូច្នោះដែរ ។

អ្នកនិពន្ធ ស៊ូស្សាន សុនថេក (Susan Sontag) បានលើកឡើងថា អ្នកទោសត្រូវបានបន្ថោកបន្ថោននៅគ្រប់វប្បធម៌ទាំងអស់ ។ យើងដឹងថាវាកើតឡើងនៅក្នុងជំរំប្រមូលផ្តុំរបស់ពួកណាហ្ស៊ីអាល្លឺម៉ង់ ប៉ុន្តែវាក៏បានកើតឡើងផងដែរនៅក្នុងគុក អាប៊ូហ្គ្រេប (Abu Ghrab) ក្នុងប្រទេសអ៊ីរ៉ាក់ ជាទីកន្លែងដែលអាមេរិកាំងបានធ្វើអ្វី «ដែលពួកគេបានប្រាប់ដោយពាក្យសម្តីឬដោយអារម្មណ៍ដល់អ្នកទោសដែលទាហានអាមេរិកាំងមានអំណាចលើទាំងនោះសមនឹងទទួលរងការបន្ថុះបន្ថោក និងទារុណកម្មនេះ» ។ ទាហានអាមេរិកប្រព្រឹត្តអំពើឃោរឃៅបែបនេះព្រោះខ្លួនត្រូវបានធ្វើឲ្យជឿថា អ្នកទោសដែលខ្លួនធ្វើទារុណកម្មសុទ្ធតែជាសមាជិកនៃពូជសាសន៍ឬសាសនាដែលទាបជាងខ្លួន ។

## យុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា

យុត្តិធម៌ត្រូវបានយល់ឃើញខុសគ្នាដោយមនុស្សផ្សេងៗគ្នា ។ អ្នកខ្លះឲ្យនិយមន័យថា យុត្តិធម៌គឺជាការកាត់ទោសអ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋ ហើយអ្នកខ្លះទៀតយល់ថា យុត្តិធម៌ជាដំណើរការមួយដែលអាចបញ្ចប់នូវការឈឺចាប់ដែលខ្លួនធ្លាប់មាន ។ អស់រយៈពេលជិត៣០ឆ្នាំមកហើយចាប់តាំងពីរបបខ្មែរក្រហមបានដួលរលំទៅ ប៉ុន្តែពុំមានសមាជិកខ្មែរក្រហមណាម្នាក់ដែលត្រូវបានកាត់ទោសសម្រាប់ការប្រព្រឹត្តរបស់ពួកគេឬក៏ផ្តល់យុត្តិធម៌នៅឡើយទេ ។ ទាំងនេះគឺមកពីមានទំនាស់នៅលើបញ្ហាថា តើជនទាំងនោះគួរត្រូវកាត់ទោសដោយតុលាការអន្តរជាតិឬតុលាការ

ក្នុងស្រុក ។

លើសពីនេះទៅទៀត ជនជាតិខ្មែរនៅតែរស់នៅក្នុងស្ថានភាពមានសិទ្ធិមនុស្សតិចតួចដដែល ។ អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ជូឌី លេដ្ជឺវូត និង ឃាង អុន (Judy Ledgerwood និង Kheang Un) បានរកឃើញថា គ្មានរដ្ឋាភិបាលណាមួយរបស់ប្រទេសកម្ពុជា (ទោះបីជាគ្រប់គ្រងដោយប្រទេសបារាំង ស្តេច ពួកកុម្មុយនីស្ត ឬពួកសាធារណរដ្ឋក្តី) ធ្វើឲ្យប្រជាជនរស់នៅដោយមានការគោរពដល់សិទ្ធិមនុស្សនោះទេ ។ ទោះបីជាមេដឹកនាំជាន់ខ្ពស់ក្នុងរដ្ឋាភិបាលបច្ចុប្បន្នផ្តល់អាទិភាពឲ្យមានមូលដ្ឋានគ្រឹះផ្នែកសេដ្ឋកិច្ចដែលចាំបាច់ដល់សិទ្ធិមនុស្សក៏ដោយ ក៏អ្នកដឹកនាំទាំងនោះបានបញ្ជាក់បន្ថែមទៀតថា ការខិតប្រឹងប្រែងផ្តល់យុត្តិធម៌ក្នុងការនាំអតីតខ្មែរក្រហមទៅកាត់ទោសអាចបង្កឲ្យកើតមានសង្គ្រាមស៊ីវិលម្តងទៀតដែលជាហេតុធ្វើឲ្យបញ្ហាសិទ្ធិមនុស្សក្លាយជាបញ្ហាផ្នែកសន្តិសុខនិងស្ថិរភាពរបស់ជាតិមួយ ។

## បញ្ហានេះនឹងអាចធ្វើឲ្យក្លាយទៅជាចំណុចគ្រោះថ្នាក់

មនុស្សមួយចំនួនបានអះអាងថា តុលាការចម្រុះអន្តរជាតិនិងក្នុងស្រុកនេះនឹងមិនអាចផ្តល់យុត្តិធម៌គ្រប់គ្រាន់ដល់ប្រជាពលរដ្ឋកម្ពុជានោះទេ ពីព្រោះរដ្ឋាភិបាលធ្លាប់ស្ទាក់ស្ទើរក្នុងការកាត់ទោសខ្មែរក្រហម ហើយរដ្ឋាភិបាលនេះនៅចង់មានឥទ្ធិពលលើតុលាការនោះទៀតផង ។ បន្ថែមពីលើនោះទៀត មន្ត្រីរាជការកម្ពុជាមួយចំនួនបានបញ្ចេញយោបល់ថា ផលប្រយោជន៍និងមនោគមវិជ្ជារបស់ប្រទេសមហាអំណាចបានធ្វើឲ្យប្រទេសទាំងនោះបំភ្លេចចោលនូវការពិត យុត្តិធម៌និងសិទ្ធិមនុស្ស ហើយលែងខ្វាយខ្វល់ពីរបបដែលបានសម្លាប់ប្រជាជនខ្មែរអស់រាប់លាននាក់ ។

លោក គ្រេក អេចឆេសាន់ បានកត់សម្គាល់លើគោលជំហររបស់រដ្ឋាភិបាលខ្មែរថា មានការផ្លាស់ប្តូរច្រើនជាងមួយដង ។ នៅក្នុងឆ្នាំ១៩៩៥ គណបក្សគ្រប់គ្រងអំណាច «គណបក្សប្រជាជនកម្ពុជា» បានអះអាងបញ្ជាក់ពីជំហរគាំទ្រក្នុងការនាំខ្លួនអ្នកប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះឲ្យមកទទួលទោស ។ ដោយសារតែប្រព័ន្ធតុលាការនៅក្នុងស្រុកមានចំណុចខ្សោយនិងខ្វះខាតច្រើន នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រីទីមួយសម្តេចព្រះនរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន បានផ្ញើលិខិតមួយច្បាប់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិស្នើសុំជំនួយពីអន្តរជាតិក្នុងការបង្កើតតុលាការ ។ ក៏ប៉ុន្តែមេដឹកនាំខ្មែរក្រហមភាគច្រើនបានចុះចូលនឹងរដ្ឋាភិបាលកម្ពុជា ហើយលោកនាយករដ្ឋមន្ត្រីក៏បានផ្លាស់ប្តូរគំនិត ដោយថ្លែងថាទាស់ថា ប្រជាពលរដ្ឋខ្មែរគួរតែ «កប់អតីតកាលទាំងឡាយ» ។ យ៉ាងណាក៏ដោយ ក្រោយពីមានការចរចាអស់រយៈពេល៧ឆ្នាំ រដ្ឋាភិបាលក៏បានយល់ព្រមក្នុងការបង្កើតតុលាការនេះ ។

បញ្ញវន្តចំនួនបានកត់សម្គាល់ថា ចំណុចខ្សោយនៅក្នុងតុលាការនេះប្រហែលជាមានន័យថា មិនមានការធានាយុត្តិធម៌នៅក្នុងរឿងក្តីខ្លះ ។ លោក ស្ទីវ ហេឌ័រ និងអ្នកដទៃទៀតបានបញ្ជាក់ពីការព្រួយបារម្ភរបស់ខ្លួនលើបញ្ហាអានុភាពនយោបាយដែលអាចជះឥទ្ធិពលដល់តុលាការនេះ ។ លោក ហេឌ័រ បានបញ្ជាក់ថា ការវិនិច្ឆ័យពីអតីតកាលរបស់តុលាការខ្មែរដែលការវិនិច្ឆ័យនេះត្រូវសម្រេចឡើងនៅមុនរឿងក្តីបើកសវនាការចង្អុលបង្ហាញថា នឹងមានភាពលម្អៀងនៅក្នុងតុលាការចម្រុះនេះដែរ ។ ការទាញហេតុផលបញ្ជាក់ពីតុលាការកូនកាត់នៅប្រទេសទីម័រខាងកើតនិងប្រទេសសៀរ៉ាឡេអូន លោក ឆាល ធីខល (Chales T. Call) បានលើកឡើងនូវសមត្ថភាពទន់ខ្សោយនិងឥទ្ធិពលនយោបាយនៅក្នុងតុលាការទាំងពីរនេះ ហើយគាត់បានបន្ថែមទៀតថាតុលាការកូនកាត់នៅកម្ពុជានេះនឹងមិនអាចស្វែងរកយុត្តិធម៌ពិតប្រាកដទេ ។

ប្រជាជនមួយចំនួននៅតែមានគំនិតសុទិដ្ឋិនិយមថា សវនាការនឹងមិនអាចកើតឡើងបានទេ ពីព្រោះរដ្ឋាភិបាលកម្ពុជាអាចនឹងរារាំងដំណើរប្រតិបត្តិការនេះឬក៏បញ្ឈប់កិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការសហប្រជាជាតិ ។

ក្នុងករណីផ្សេងៗទៀត វាអាចបញ្ជាក់ឲ្យឃើញច្បាស់ថា រដ្ឋាភិបាលកម្ពុជាបម្រុងនឹងកាត់ទោសតែមេដឹកនាំធំៗប៉ុណ្ណោះ ។ ដូច្នេះតើយើងអាចធ្វើអ្វីចំពោះកម្មាភិបាលដែលបានធ្វើទារុណកម្មនិងសម្លាប់ប្រជាជនក្រោមរបបនោះ?

គោលបំណងនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ គឺដើម្បីវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា

ការរំលោភទៅលើច្បាប់មនុស្សជាតិអន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ស៊ីវ ហេង៉រ បានបញ្ជាក់បន្ថែមទៀតថា ប្រហែលជាមានជន៦០រូបដែលត្រូវនាំយកមកកាត់សេចក្តីៈ ១០រូបជាមេដឹកនាំជាន់ខ្ពស់និង៥០រូបជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបនោះ ។ យ៉ាងណាក៏ដោយ អ្នកដែលនៅរស់រានមានជីវិតមានតិចជាង១០នាក់ដែលអាចចាត់ទុកជាក្រុមមេដឹកនាំជាន់ខ្ពស់បាន ហើយការកំណត់ប្រភេទអ្នកទទួលខុសត្រូវខ្ពស់បំផុតក៏ប្រហែលជាច្រើនពេកដែរ ។ ប្រហែលជាមានតែរឿងក្តី ១២ប៉ុណ្ណោះ ឬក៏តិចជាងនេះដែលនឹងត្រូវយកមកកាត់សេចក្តី ។

ចំណុចមួយដែលប្រាកដនោះគឺថា យុត្តាធិការតុលាការនេះនឹងមិនកាត់ទោសក្រុមកម្មាភិបាលថ្នាក់ទាបដែលសម្លាប់អ្នកដទៃនោះទេ ។ គំនិតនេះទៀតសោតបានបង្ហាញឲ្យឃើញពីគំនិតពីរប្រឆាំងគ្នា វាគ្រាន់តែអាស្រ័យលើថាតើអ្នកណាជាអ្នកមានយោបល់លើបញ្ហានោះ ក្រុមកម្មាភិបាលឬក៏ជនរងគ្រោះ ។ កម្មាភិបាលមួយចំនួនរស់នៅក្នុងភាពភ័យខ្លាចក្នុងអំឡុងរបបខ្មែរក្រហម ហើយអ្នកទាំងនេះខ្លាចក្រែងប្រសិនបើខ្លួនមិនគោរពឬក៏ធ្វើខុសនោះ ខ្លួននឹងត្រូវគេធ្វើទារុណកម្មឬក៏សម្លាប់មិនខាន ។ ទស្សនវិស័យនេះអាចនាំទៅដល់ការលើកកម្ពស់នូវអ្វីដែលហៅថា «ការស្តាបនាយុត្តិធម៌ឡើងវិញ» ដែលជាមូលដ្ឋានគ្រឹះជួយឲ្យប្រជាជនស្វែងយល់ថា កម្មាភិបាលទាំងនោះក៏ជាជនរងគ្រោះដែរ ហើយបានប្រព្រឹត្តអំពើនោះក៏ដោយសារតែអ្នកទាំងនោះត្រូវបានដុះខាត់ខួរក្បាលតាមរយៈការឃោសនា ឬក្នុងគោលបំណងមួយដើម្បីការពារជីវិតខ្លួនឯងប៉ុណ្ណោះ ។

ប៉ុន្តែបើក្រឡេកមើលបញ្ហាទាំងនោះចេញពីការគិតរបស់ជនរងគ្រោះវិញអាចនិយាយថា ជនបែបនោះតែងតែអះអាងថាខ្លួនធ្វើតាមបញ្ជាពីថ្នាក់លើដើម្បីគេចផុតពីការធ្វើទារុណកម្ម ។ ឧទាហរណ៍ជាក់ស្តែងអតីតឆ្មាំគុកមន្ទីរស-២១ ហ៊ឹម ហ៊ុយ បាននិយាយថា ប្រធានរបស់គាត់បានឲ្យគាត់សម្លាប់មនុស្សពីរ-បីនាក់ដើម្បីបង្ហាញថាគាត់ស្មោះត្រង់ ។ ហ៊ុយ បន្តថា ខ្លួនគ្មានជម្រើសទេចំពោះការសម្លាប់អ្នកទោសទាំងអស់នោះដើម្បីឲ្យគាត់អាចរក្សាជីវិតរបស់ខ្លួនបានរស់នៅតទៅទៀត ។

ការលើកកម្ពស់ការផ្សះផ្សាគឺជាវិធីមួយដើម្បីដោះស្រាយនូវសំណួរដ៏ស្មុគស្មាញបែបនេះ ។ សាសនាអាចជួយច្រើននៅក្នុងដំណើរការនេះ ។ ប្រជាជនខ្មែរភាគច្រើនគោរពប្រណិប័តន៍ពុទ្ធសាសនាបែបហីនយាន ដែលណែនាំឲ្យមានការលើកលែងទោស ការផ្សះផ្សា ការអត់ធ្មត់ និងសេចក្តីករុណា ។ ព្រះពុទ្ធសម្តែងថា «សេចក្តីស្អប់ មិនអាចបញ្ចប់សេចក្តីស្អប់ទេ ប៉ុន្តែមានតែសេចក្តីស្រឡាញ់ទេដែលអាចជួយឲ្យសះស្បើយបាន» ។ សង្គមបានបកស្រាយសម្តីនេះថាប្រជាជនគួរតែអត់ឱនឲ្យអ្នកដែលប្រព្រឹត្តខុស ហើយជួយអ្នកទាំងនោះឲ្យដើរតាមផ្លូវត្រូវវិញ ។ តាមដីការបស់ព្រះតេជគុណ យស់ ហុត ខេមចារោ ថា «ព្រះពុទ្ធប្រៀនប្រដៅមនុស្សឲ្យយកឈ្នះអំពីអាក្រក់ដោយប្រព្រឹត្តនូវអំពើល្អ ។ ដើម្បីយកឈ្នះការ ប្រណែនឈ្នានីស យើងមិនត្រូវប្រណែនឈ្នានីសទេ យើងត្រូវប្រកាន់យកសេចក្តីស្រឡាញ់ មេត្តានិងករុណា ។ ដើម្បីយកឈ្នះលោភៈ យើងត្រូវធ្វើចិត្តឲ្យទូលាយហើយដើម្បីយកឈ្នះការភូតកុហក យើងត្រូវនិយាយទៀងត្រង់» ។ សម្តេចសុគន្ធាធិបតី បួរ គ្រី សម្តេចសង្ឃធម្មយុត្តិកនិកាយបានពន្យល់ថា ការផ្សះផ្សាគឺអាចទទួលយកបាន ។ ព្រះអង្គបានលើឧទាហរណ៍ពីអង្គុលីមារ ដែលជាមនុស្សសាហាវនិងមានគោលដៅសម្លាប់មនុស្សឲ្យបាន១០០០នាក់ ។ អង្គុលីមារ បានសម្លាប់មនុស្ស៩៩៩នាក់ ហើយគាត់សម្រេចថា នឹងសម្លាប់ម្តាយរបស់គាត់ដើម្បីបង្គ្រប់ចំនួន ។ ព្រះពុទ្ធទ្រង់បានបញ្ឈប់សកម្មភាពរបស់អង្គុលីមារ ពីការប្រព្រឹត្តអំពើបាបនេះ ។ យោងតាមឧទាហរណ៍នេះ សម្តេចសង្ឃ បួរ គ្រី ជំរុញឲ្យមានការផ្សះផ្សាដោយមានដីកាថាប្រសិនបើខ្មែរក្រហមបានទទួលការអប់រំតាមផ្លូវត្រឹមត្រូវក្នុងសង្គមប្រជាជនអាចរស់នៅជួបជុំគ្នា ។ ព្រះអង្គស្វែងយល់ថា ការអប់រំមានន័យថា បង្រៀនមនុស្សឲ្យបោះបង់ចោលអំពើអាក្រក់និងប្រណិប័តន៍អំពើល្អ ។

អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់មួយចំនួនបានលើកឡើងនូវយន្តការមួយចំនួនដែលអាចជាស្ពានឆ្ពោះទៅរកយុត្តិធម៌អន្តរកាលដើម្បីជម្នះលើបញ្ហាផ្សះផ្សា ។ យន្តការទាំងនោះរួមមានគណៈ

កម្មការស្វែងរកការពិត សំណង ការព្យាបាល ការសាងសង់បូជនីយដ្ឋាននិងការប្រារព្ធពិធីតាមប្រពៃណី គម្រោងប្រវត្តិ-សាស្ត្រ ការនិពន្ធ សកម្មភាពផ្សេងៗនៅតាមសហគមន៍ ។

គណៈកម្មការស្វែងរកការពិតមានភារកិច្ចចាំបាច់សម្រាប់បំពេញបន្ថែមលើតុលាការឧក្រិដ្ឋកម្ម ជាពិសេសនៅក្នុងប្រទេសកម្ពុជាដែលប្រជាជនភាគច្រើននៅតែមិនទាន់យល់ដឹងច្រើនអំពីរបបនេះ ។ គណៈកម្មការស្វែងរកការពិតគឺជាមធ្យោបាយមួយលាតត្រដាងការពិតអំពីអ្វីដែលបានកើតឡើង ហើយការងារសំខាន់របស់គណៈកម្មការស្វែងរកការពិតនេះដែលអាចយកមកអនុវត្តនៅក្នុងប្រទេសកម្ពុជាដោយផ្តោតទៅលើការអប់រំ ដោយសារប្រជាជនជាច្រើនចង់ដឹងការពិត ។

ប្រជាជនជាច្រើនជឿជាក់ថា ការប្រារព្ធពិធីតាមប្រពៃណីគឺជាភាពចាំបាច់នៃដំណើរការផ្សះផ្សា ។ ការប្រារព្ធពិធីតាមវិធីបុណ្យបុរាណមានសារសំខាន់ណាស់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅក្នុងគ្រប់ប្រទេស ។ ពិធីទាំងអស់នេះមានសារសំខាន់ណាស់សម្រាប់ប្រទេសដែលរួចផុតពីជម្លោះ ហើយសម្រាប់ប្រើប្រាស់នៅក្នុងការដោះស្រាយជាមួយសោកនាដកម្មទាំងអស់នេះ ។ នៅក្នុងប្រទេសកម្ពុជាមានពិធីបុណ្យពីរ-បីសំខាន់ៗដែលអាចជួយផ្សះផ្សារបួសរបស់ប្រជាជននៅក្នុងសង្គម ។

ក្នុងចំណោមនោះមានពិធីបុណ្យភ្ជុំបិណ្ឌ ។ ក្នុងការប្រារព្ធពិធីបុណ្យសាសនាដ៏សំខាន់នេះ ប្រជាជនឧទ្ទិសកុសលជូនដល់ដូនតាដែលបានចែកឋានទៅ ។ ដោយសារតែប្រជាជនមានជំនឿថា ថ្វីបើដូនតារបស់ខ្លួនបានចែកឋានទៅហើយក្តី ក៏ប៉ុន្តែព្រលឹងគាត់នៅតែរស់នៅជាមួយក្រុមគ្រួសាររបស់ខ្លួនដើម្បីតាមជួយបញ្ចៀសនូវរឿងរ៉ាវអាក្រក់ទាំងឡាយដូចជាជំងឺសាហាវជាដើម ។ ក៏ប៉ុន្តែជួនកាលព្រលឹងទាំងនោះបានធ្វើទុក្ខម្នេញដល់គ្រួសារដែលនៅរស់ដោយសារអ្នកទាំងនោះមិនយកចិត្តទុកដាក់ចំពោះខ្លួន ។ ដូច្នេះហើយបានជាប្រជាជនប្រារព្ធពិធីបុណ្យនេះ ដើម្បីចៀសវាងការដាក់បណ្តាសា ។ កាលណាក្រុមគ្រួសារប្រារព្ធពិធីនោះ ខ្លួននឹងទទួលបានសំណាងល្អ ហើយព្រលឹងរបស់ដូនតានឹងធ្វើដំណើរទៅកាន់សុគតិភពនៅក្នុងវាលវដ្តសង្សារ ។ ដូច្នេះ ពិធីនេះអាចនាំឲ្យប្រជាជនស្ងប់ចិត្តដោយការផ្សះផ្សាខ្លួនឯង ។ ជំហានបន្ទាប់គឺគាត់នឹងផ្សះផ្សាជាមួយអ្នកជិតខាងក្នុងសហគមន៍ ហើយឆ្ពោះទៅរកការផ្សះផ្សាជាតិ ។

ជាក់ស្តែងពេលដែលខ្ញុំបានសួរអ្នកដែលនៅរស់រានមានជីវិតជាច្រើនដែលបានសះស្បើយបន្ទាប់ពីរបបខ្មែរក្រហមអ្នកទាំងនោះឆ្លើយថា គាត់តែងតែបន់ស្រន់ឲ្យសាច់ញាតិរបស់គាត់បានទៅកាន់សុគតិភព ។ សូម្បីតែប្រជាជនកម្ពុជាជាច្រើនដែលកំពុងរស់នៅក្រៅប្រទេសក៏បានផ្ញើថវិកាមកឲ្យសាច់ញាតិរបស់ខ្លួនដើម្បីធ្វើបុណ្យឧទ្ទិសដល់សមាជិកគ្រួសារដែលបាត់ខ្លួនដែរ ។

ពិធីបង្សុកូលគឺជាពិធីមួយផ្សេងទៀតដែលប្រជាជនប្រារព្ធឡើងដើម្បីឧទ្ទិសកុសលជូនព្រលឹងដូនតារបស់ខ្លួន ។ ប្រជាជនប្រគេនទេយ្យទានដល់ព្រះសង្ឃ បន្ទាប់មកព្រះសង្ឃសូត្រឧទ្ទិសបញ្ជូនកុសលទៅឲ្យព្រលឹងអ្នកស្លាប់ ។ ពិធីនេះមានសារសំខាន់សម្រាប់ប្រជាជនដែលមានសាច់ញាតិស្លាប់ក្នុងរបបខ្មែរក្រហម និងសម្រាប់អ្នកដែលបានស្លាប់ទៅដោយមិនបានធ្វើបុណ្យ ។ ប្រជាជនជឿថាបើមិនមានពិធីបុណ្យសពត្រឹមត្រូវទេ ព្រលឹងខ្មោចទាំងនោះនឹងក្លាយទៅជាខ្មោចតៃហោង ។ ដូច្នេះពិធីនេះគឺជាជម្រើសដ៏ល្អបំផុតសម្រាប់ប្រជាជនកម្ពុជាក្នុងការធ្វើឲ្យព្រលឹងស្ងប់ស្ងាត់និងចៀសវាងកុំឲ្យព្រលឹងតាមយាយីជីវិតខ្លួននៅតាមសហគមន៍ ។

និយាយពីសំណង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងរាជរដ្ឋាភិបាលមិនបានគូសបញ្ជាក់ថា ជនរងគ្រោះអាចទទួលបានសំណងជារូបិយវត្ថុទេ ។ ប៉ុន្តែសំណងជាសាច់ប្រាក់នេះត្រូវបានស្វាគមន៍ពីជនរងគ្រោះដែលមានជីវភាពក្រីក្រនិងត្រូវការសំណងបែបនេះ ។ ដូចសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងសម្តេចហ៊ុន សែន និយាយថា តម្រូវការសេដ្ឋកិច្ចគឺជាកត្តាសំខាន់បំផុតសម្រាប់ប្រជាជនកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនអាចធ្វើទៅបានទេក្នុងការផ្តល់សំណងជាប្រាក់ក្នុងករណីប្រទេសកម្ពុជាព្រោះថានៅក្នុងគ្រួសារនីមួយៗយ៉ាងហោចណាស់មានបាត់បង់សមាជិកជាទីស្រឡាញ់ម្នាក់ឬច្រើនជាងនេះ ។ ដូច្នេះសំណងជារួមដូចជាការអប់រំ សុខភាព និងហេដ្ឋារចនាសម្ព័ន្ធ អាចជាការជួយលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ។

**ព្រុំ ផល្លា**

# សេចក្តីស្រលាញ់និងអាពាហ៍ពិពាហ៍

របបខ្មែរក្រហមបានគ្រប់គ្រងប្រទេសតាមបែបផែនព្រៃផ្សៃចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ នៅក្រោមរដ្ឋកម្ពុជាប្រជាធិបតេយ្យដែលមិនគោរពតាមលទ្ធិប្រជាធិបតេយ្យ ។ ការគ្រប់គ្រងរបស់របបនេះបាននាំឲ្យប្រជាជនប្រមាណមួយភាគបួនស្លាប់ដោយសារគ្រោះទុរ្ភិក្ស ការងារហួសកម្លាំង ជំងឺនិងការសម្លាប់តាមបែបប្រព័ន្ធ ។ របបនេះហាមប្រាមមិនឲ្យមានស្ថាប័នសេដ្ឋកិច្ច សាសនា និងសង្គមឡើយ ហើយគ្រប់គ្រងស្ថាប័នមួយចំនួនតូចដែលនៅសេសសល់យ៉ាងតឹងរ៉ឹង ។ សេចក្តីស្រលាញ់និងការរៀបការ ស្ថិតនៅក្នុងចំណោមការគ្រប់គ្រងយ៉ាងរឹតត្បិតរបស់របបនេះ ។ ការសម្តែងចេញនូវសេចក្តីស្រឡាញ់ត្រូវមានទោសពីបទខុសសីលធម៌ ហើយការរៀបការត្រូវអង្គការជាអ្នករៀបចំ ។ នេះមានន័យថា អង្គការជាអ្នកជ្រើសរើសថាតើអ្នកណា ដែលអ្នកត្រូវរៀបការជាមួយ ។ អង្គការមិនខ្វល់ថាតើអ្នកចូលចិត្ត ឬធ្លាប់ជួបជាមួយអ្នកនោះដែរឬអត់នោះទេ ។

មានទស្សនៈផ្ទុយគ្នាពីរទាក់ទងទៅនឹងការរៀបការនៅក្នុងរបបខ្មែរក្រហម ។ អ្នកខ្លះយល់ថា ប្រជាជនត្រូវបានបង្ខំឲ្យរៀបការ ចំណែកអ្នកមួយចំនួនតូចនោះវិញចាត់ទុកការរៀបការថាជាភ័ព្វព្រេងសំណាងរបស់ខ្លួន ។ បើផ្អែកទៅលើទស្សនៈជាប្រពៃណីស្តីពី«គូព្រេង»វិញ មតិចំនួនតូចមានជំនឿថា វាជាភ័ព្វវាសនារបស់ខ្លួនដែលបានរៀបការជាមួយគ្រួសាររបស់ខ្លួន បើទោះជាការរៀបការនោះបានផ្សំផ្គុំឡើងដោយកម្មាភិបាលខ្មែរក្រហមក៏ដោយ ។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅពិធីរៀបមង្គលការនៅក្នុងសម័យខ្មែរក្រហមមិនមែនជាឱកាសប្រកបដោយសុភមង្គលនិងរីករាយនោះទេ ។ ស្ថិតក្នុងសម្លៀកបំពាក់ពណ៌ខ្មៅធម្មតាដែលដូចជាសម្លៀកបំពាក់ពេលយប់ កូនក្រមុំ កូនកម្លោះ ត្រូវបានរៀបការជាក្រុមដោយមិនប្រព្រឹត្តទៅតាមប្រពៃណីនិងទំនៀមទម្លាប់របស់ខ្មែរឡើយ ។

បន្ទាប់ពីបានបើករថយន្តកាត់តាមផ្លូវក្រាលគ្រួសក្រហម



អ្នកភូមិកំពូលមាសនៅក្នុងកម្មវិធីបញ្ចាំងភាពយន្តឯកសារ

ហុយទ្រលោម ក្រុមបញ្ចាំងកុននិងការិយាល័យព័ត៌មានសាធារណៈ បានធ្វើដំណើរទៅដល់ផ្ទះប្រធានភូមិម្នាក់នៅក្នុងស្រុកកំពង់ត្រាច ខេត្តកំពត ។ គោលបំណងរបស់ក្រុមនេះគឺបញ្ចាំងភាពយន្តឯកសារចំនួនពីរដែលផលិតដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្សែភាពយន្តទីមួយផលិតក្នុងឆ្នាំ២០០៤មានចំណងជើងថា «វាលស្រែខ្មែរក្រហមៈប្រវត្តិរឿងរ៉ាវជនរងគ្រោះដោយការរំលោភនៅក្នុងរបបខ្មែរក្រហម» និងទីពីរផលិតក្នុងឆ្នាំ២០០៧ មានចំណងជើងថា «នៅគៀនជញ្ជាំងស-២១ៈប្រវត្តិសាស្ត្រផ្ទាល់មាត់ពីគុកទួលស្លែង» ។

អន្ទុយ នៅក្រោមម្លប់ដើមឫស្សីនិងកៅស៊ូតង់ពណ៌ខៀវ ប្រធានភូមិកំពូលមាសនិងភូមិស្នាមគោ បានស្វាគមន៍បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីមកសំណេះសំណាលជាមួយអ្នកភូមិប្រមាណជា១៦០នាក់ ។ បុគ្គលិកតំណាងមជ្ឈមណ្ឌលបាននិយាយត្រួសៗប្រាប់អ្នកភូមិអំពីការងារនិងកម្មវិធីនានារបស់មជ្ឈមណ្ឌល ព្រមទាំងនិយាយអំពីសារសំខាន់នៃការបញ្ចាំងខ្សែភាពយន្តដើម្បីលើកទឹកចិត្តឲ្យអ្នកភូមិនិយាយអំពីបញ្ហា «ខុសសីលធម៌» និងបញ្ហាពាក់ព័ន្ធនានាដែលកើតមានឡើងនៅក្នុងជំនាន់ខ្មែរក្រហម ។

ក្រុមការិយាល័យព័ត៌មានសាធារណៈបានញ៉ាំខ្សែភាពយន្ត «វាលស្រែខ្មែរក្រហមៈប្រវត្តិរឿងរ៉ាវជនរងគ្រោះដោយការរំលោភនៅក្នុងរបបខ្មែរក្រហម» ទូទាំងប្រទេសកម្ពុជាក្នុងរយៈពេលពីរ-បីឆ្នាំចុងក្រោយនេះ ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផលិតខ្សែភាពយន្តឯកសារថ្មីមួយទៀតហើយចាប់ផ្តើមបញ្ចាំងខ្សែភាពយន្តទាំងពីរនេះតែម្តង ក្នុងគោលបំណងចង់បង្កើតនូវការពិភាក្សាស្តីពីប្រធានបទស្រួចស្រាល់មួយចំនួនទាក់ទងនឹងទំនាក់ទំនងរវាងបុរសនិងស្ត្រីក្នុងអំឡុងរបបខ្មែរក្រហម និងជាពិសេសរឿងរ៉ាវស្តីពីអំពើហិង្សាខាងផ្លូវភេទ ដូចជាករណីរំលោភជាដើម ។ រឿងរ៉ាវស្តីអំពីការរៀបការនិងអ្វីដែលខ្មែរក្រហមចាត់ទុកថា ជាអំពើ «ខុសសីលធម៌» ដែលចេញមកពីការពិភាក្សាបន្ទាប់ការបញ្ចាំងខ្សែភាពយន្តនិងបទសម្ភាសន៍ដោយកញ្ញា ស៊ិន សុធីតា និង កញ្ញា ហ៊ិន សុធានី ។

គីម ហួន អាយុ៦៥ឆ្នាំ បាននិយាយថា គាត់មិនដែលបានឮអំពីអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងពេលដែលគាត់រស់នៅក្នុងរបបខ្មែរក្រហមនោះទេ ។ ប៉ុន្តែគាត់ទទួលស្គាល់ថា អំពើខុសសីលធម៌បានកើតឡើងនៅក្នុងសហករណ៍របស់គាត់ ។ គាត់បានរំឭកថា បុរសម្នាក់ឈ្មោះ ពីង និងស្ត្រីឈ្មោះ ស៊ិន ត្រូវបានរកឃើញថាមានកំហុសពីបទមានទំនាក់ទំនងស្នេហាដោយគ្មានការយល់ស្របពីអង្គការ ។ ដោយដឹងច្បាស់ថា ខ្លួននឹងប្រឈមមុខទៅនឹងទោសសម្លាប់ចោលអ្នកទាំងពីរបានភៀសខ្លួនចូលទៅក្នុងប្រទេសវៀត-ណាម ។

គង់ ហួន អាយុ៥៩ឆ្នាំ បានលាតត្រដាងថា បងប្អូនប្រុសរបស់គាត់ឈ្មោះ គង់ មួយ ត្រូវបានយកទៅសម្លាប់ដោយចោទប្រកាន់ថា បានប្រព្រឹត្តខុសសីលធម៌ជាមួយស្ត្រី១៧មេសាម្នាក់ដែលធ្វើការនៅរោងបាយ ។ ហួន សោកស្តាយដែលថាអង្គការមិនបានរៀបការឲ្យបងប្អូនប្រុសរបស់គាត់មុនពេលដែលមាន «អំពើខុសសីលធម៌»បានកើតឡើង ។

ច្បាស់ណាស់ថា ពាក្យ «ខុសសីលធម៌»ក្នុងរបបខ្មែរក្រហមជាពាក្យសម្រាលចេញពីពាក្យ «ការរំលោភផ្លូវភេទ» ដែលជាអំពើឧក្រិដ្ឋកម្មទទួលទោសប្រហារជីវិតនៅក្រោមគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ ។ ជុំ មាស អាយុ៥២ឆ្នាំ បានពន្យល់អំពីអ្វីដែលត្រូវបានចាត់ទុកថាជាអំពើខុសសីលធម៌ ។ បទល្មើសនេះអាចបណ្តាលមកពីសកម្មភាពធម្មតាមួយចំនួនដូចជាការមានទំនាក់ទំនងជាមិត្តភាពរវាងបុរសនិងស្ត្រី ។ នៅក្នុងករណីប្រព្រឹត្ត «ខុសសីលធម៌ផ្លូវភេទ» លទ្ធផលនឹងត្រូវទទួលទណ្ឌកម្មធ្ងន់ធ្ងរ ។

អ្នកភូមិមួយចំនួនក៏បានដឹងអំពីឧទាហរណ៍មួយចំនួនអំពីអាពាហ៍ពិពាហ៍ដោយបង្ខំដែរ ។ បែន ខ្យង អាយុ៨០ឆ្នាំ បានអះអាងថា អង្គការគ្រប់គ្រងទាំងអស់ ថាតើនរណាត្រូវរៀបការជាមួយនរណា ។ គូស្វាមីដែលបានរៀបចំឲ្យនោះមិនអាចបដិសេធទៅអង្គការវិញឡើយ បើធ្វើដូច្នោះអ្នកទាំងនោះត្រូវយកទៅសម្លាប់ចោល ។ ប៉ាង ហួន អាយុ៥០ឆ្នាំ ដែលជាអតីតទាហានបានគូសបញ្ជាក់បន្ថែមទៀតថាការបដិសេធមានន័យស្មើនឹងការស្លាប់ដូចក្នុងករណីប្អូនប្រុសរបស់មិត្តភក្តិគាត់ដែលត្រូវបានសម្លាប់ដោយសារតែការជំទាស់មិនព្រមរៀបការ ។ ហួន ខ្លួនឯងត្រូវបានកម្មា-ភិបាលខ្មែរក្រហមរៀបចំគ្រួសារឲ្យគាត់ចំនួនប្រាំពីរដង ។ នៅយប់មួយនីរសាក្មេងម្នាក់បានមកប្រាប់គាត់ឲ្យទៅរោងបាយសហករណ៍

ដើម្បីទៅមើលនារីចុងភៅម្នាក់ ។ នៅពេលនោះ ប្រធានកងក៏បានសួរគាត់ថាតើគាត់ព្រមរៀបការជាមួយចុងភៅនោះដែរឬទេ? ការឆ្លើយតបរបស់ ហួន គឺ «ស្រេចតែបង(ប្រធានកង)» ។

ចាន់ សុខ អាយុ៧១ឆ្នាំ ក៏បាននិយាយអំពីការរៀបការជាក្រុមដោយអង្គការដែរ ។ កម្មាភិបាលខ្មែរក្រហមបាននិយាយទៅកាន់គូស្វាមីភរិយាថ្មីថា អ្នកទាំងអស់គ្នាត្រូវដឹងគុណអង្គការដោយសារតែអ្នកទាំងអស់គ្នាបានរៀបការដោយមិនចាំបាច់ចំណាយលុយកាក់ឡើយ ។ បន្ទាប់មក គូស្វាមីភរិយាថ្មីត្រូវក្រោកឈរហើយនិយាយនៅចំពោះមុខអង្គការថា *«ខ្ញុំស្ម័គ្រចិត្តទទួលយកគាត់ជាដៃគូរហូត»* ។

ចាន់ សុខ បានជំទាស់ចំពោះអាពាហ៍ពិពាហ៍ដែលរៀបចំដោយអង្គការ ។ គាត់បានបញ្ជាក់ថា តាមប្រពៃណីរៀបអាពាហ៍ពិពាហ៍របស់ខ្មែរ គូស្វាមីភរិយាថ្មីត្រូវផ្តល់ការគោរពចំពោះជីដូនជីតារបស់ខ្លួន ហើយភ្ញៀវកិត្តិយសត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅនៅក្នុងការពិសាភោជនាអាហារ ។ ផ្ទុយទៅវិញខ្មែរក្រហមបាននាំយកគូស្វាមីភរិយាថ្មីដែលមិនស្រឡាញ់គ្នា ឬមិនស្គាល់គ្នាផង ហើយឲ្យរៀបការដោយមិនអនុវត្តទៅតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ។ អាពាហ៍ពិពាហ៍ដោយបង្ខំបានបង្កឲ្យមានការមិនសប្បាយចិត្តជាច្រើនដោយសារអ្នកខ្លះបានព្យាយាមគេចវេសពីការរៀបចំបែបនោះ ។ យិន កប អាយុ៦៨ឆ្នាំ បានកត់សម្គាល់ថា *«ក្នុងអំឡុងរបបខ្មែរក្រហម យុវជនខ្លះបានជ្រើសរើសយកការចូលបម្រើក្នុងជួរកងទ័ពជាជាងគោរពតាមបញ្ជារបស់អង្គការឲ្យរៀបការជាមួយស្ត្រីដែលខ្លួនមិនចូលចិត្ត»* ។

ច្បាស់ណាស់ថា អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានចាត់ទុកថាមិនអាចទទួលយកបានទេ ក៏ប៉ុន្តែគូស្វាមីភរិយាខ្លះបន្តរស់នៅជាមួយគ្នាសុខសាន្តក្រោយរបបខ្មែរក្រហម ។ ប៉ាំង ហួន ដែលជាអតីតទាហាន បានលាតត្រដាងប្រវត្តិរឿងរ៉ាវផ្ទាល់ខ្លួននិងទស្សនៈជុំវិញពាក្យថា «គូកម្ម» (ដែលមានន័យថា ជាគូដែលបង្កឲ្យអ្នកជួបនូវការឈឺចាប់ឬភាពលំបាកលំបិន) *«...នៅក្នុងឆ្នាំ១៩៧៩ បន្ទាប់ពីវៀតណាមបានផ្តួលរំលំរបបប៉ុលពតទាំងស្រុងនៅក្នុងខេត្តកំពត ខ្ញុំបានសុំប្រពន្ធខ្ញុំលះលែងជាច្រើនសា ។ ក៏ប៉ុន្តែប្រពន្ធខ្ញុំបដិសេធដោយសុំឲ្យខ្ញុំបន្តរស់នៅជាមួយគ្នាជាគ្រួសារ ។ ដោយសារតែសេចក្តីស្រលាញ់និងភាពស្មោះត្រង់របស់ប្រពន្ធខ្ញុំ ខ្ញុំបានព្រមរស់នៅជាមួយគ្នារហូតមកដល់សព្វថ្ងៃ ។ ខ្ញុំជឿថាប្រពន្ធខ្ញុំគឺជាគូកម្មរបស់ខ្ញុំ ។ ខ្ញុំព្រមទទួលយកគូកម្មនេះ»* ។

**លី សុខឃាង**



*ភូមិស្នាមគោ នៅក្នុងកម្មវិធីបញ្ចាំងភាពយន្តឯកសារ*

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC) គឺជាតុលាការចម្រុះជាតិដែលបង្កើតឡើងដើម្បីជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់ដែលនៅរស់រានមានជីវិតនៃរបបកម្ពុជាប្រជាធិបតេយ្យនិងអ្នកទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាមធ្ងន់ធ្ងរនិងឧក្រិដ្ឋកម្មក្រោមច្បាប់កម្ពុជាមួយចំនួនទៀតដែលបានកើតឡើងក្នុងសម័យប៉ុល ពត (ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩) ។ តាមការប៉ាន់ស្មានមានប្រជាជនកម្ពុជា ប្រហែល ១,៧លាននាក់ត្រូវបានសម្លាប់ក្នុងអំឡុងពេលនោះ និងប្រជាជនរាប់លាននាក់ទៀតជាជនរងគ្រោះ ។ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើងនៅឆ្នាំ២០០១ ហើយដែលត្រូវធ្វើវិសោធនកម្មនៅឆ្នាំ២០០៤ និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០០៤ ទាក់ទងទៅនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជាទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា) បានរួមគ្នាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការពិសេសនៅក្នុងប្រទេសកម្ពុជាដែលតម្រូវឲ្យមានការចូលរួមពីចៅក្រម ព្រះរាជអាជ្ញា និងអ្នករដ្ឋបាលអន្តរជាតិរួមជាមួយនឹងសមភាគីកម្ពុជា ។*

*ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចំណាយពេល (ចាប់តាំងពីឆ្នាំ១៩៩៧ដល់ឆ្នាំ២០០៧) យូរជាងតុលាការឧក្រិដ្ឋកម្មអន្តរជាតិឬតុលាការចម្រុះដែលធ្លាប់បានបង្កើតឡើងនៅក្នុងអំឡុងសង្គ្រាមត្រជាក់ទៅទៀត ។ លទ្ធផលចុងក្រោយទទួលបាននូវស្ថាប័នមួយគួរឲ្យទុកចិត្តបានដែលឆ្លើយតបទៅនឹងការប្រកាន់ខ្ជាប់នូវបទដ្ឋានអន្តរជាតិ បើទោះបីជាមានត្រឹមតែលាយលក្ខណ៍អក្សរក៏ដោយ ហើយក៏ប្រហែលជាមានក្នុងពេលអនុវត្តដែរ ។ ខ្ញុំមានអភ័យឯកសិទ្ធិក្នុងការដើរតួនាទីដ៏មានសារសំខាន់គួរសមដែរក្នុងដំណើរការអស់មួយទសវត្សរ៍ដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដែលជាដំបូងក្នុងនាមជាអគ្គឯករាជទូតអាមេរិកទទួលបន្ទុកចំពោះបទឧក្រិដ្ឋសង្គ្រាម(១៩៩៧-២០០១) បន្ទាប់មក*




*សាលសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ*

ជាមន្ត្រីនៅក្នុងអង្គការក្រៅរដ្ឋាភិបាលនិងចាប់តាំងពីឆ្នាំ២០០៣ បានក្លាយជាសាស្ត្រាចារ្យផ្នែកច្បាប់ ។ បទពិសោធន៍ទាំងនោះជាពិសេសចេញពីចក្ខុវិស័យរបស់អាមេរិកបង្ហាញឲ្យឃើញអំពីស្ថិតិផ្នែកខាងប្រវត្តិសាស្ត្រនិងរដ្ឋធម្មនុញ្ញនៃអង្គជំនុំជម្រះវិសាមញ្ញនេះ ។

ផ្នែកទីមួយនៃអត្ថបទនេះនឹងពិនិត្យមើលពីប្រវត្តិសាស្ត្រនៃការចរចាដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញចាប់តាំងពីជំហានដំបូងរហូតដល់សកម្មភាពចុងក្រោយ ដោយមានការអនុម័តនូវវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងខែមិថុនា ឆ្នាំ ២០០៧ ។ ផ្នែកទីពីរគឺបានពន្យល់បង្ហាញបែបផែននៃអង្គជំនុំជម្រះវិសាមញ្ញដែលដោះស្រាយបញ្ហាយុត្តាធិការ ការតែងតាំងនិងការគ្រប់គ្រង ការសម្រេចចិត្ត ការអភ័យទោសនិងការលើកលែងទោស រាល់សិទ្ធិដែលត្រូវមាននៅក្នុងសាលាក្តី ការដកចេញនូវកិច្ចសហប្រតិបត្តិការ និងសិទ្ធិរបស់ជនរងគ្រោះ ។

## ផ្នែកទីមួយៈ ប្រវត្តិនៃការចរចា

### ឆ្នាំ១៩៩៧

នៅដើមខែមិថុនា ឆ្នាំ១៩៩៧ ការប្រឹងប្រែងរបស់អាមេរិកបានចាប់ផ្តើមស្នើសុំរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតគណៈកម្មការការស៊ើបអង្កេតឬគណៈកម្មការការពិតដែលជាជំហានដំបូងអាចនាំទៅដល់សាលាក្តីឧក្រិដ្ឋកម្មមួយដែលពិនិត្យមើលសកម្មភាពរបស់របបដែលមាន ប៉ុល ពត ជាអ្នកដឹកនាំនៅក្នុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ការចាប់ខ្លួន ប៉ុល ពត ភ្លាមៗ បានធ្វើឲ្យមានការជឿជាក់ច្រើន និងនៅចុងខែមិថុនា ឆ្នាំ១៩៩៧ ចំណាប់អារម្មណ៍ក្នុងការស្វែងរកឬបង្កើតសាលាក្តីដែលមានយុត្តាធិការកាត់សេចក្តីប៉ុលពតប្រកបដោយសមត្ថកិច្ចខ្ពស់និងគួរឲ្យទុកចិត្តបាន ។ ក្នុងពេលជាមួយគ្នានេះដែរ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ នាយករដ្ឋមន្ត្រីទីមួយរបស់កម្ពុជាព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ និងនាយករដ្ឋមន្ត្រីទីពីរ សម្តេច ហ៊ុន សែន បានចុះហត្ថលេខាលើលិខិតមួយច្បាប់ផ្ញើទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ដោយបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិក្នុងការកាត់សេចក្តីជនទាំងឡាយដែលទទួលខុសត្រូវពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងអំឡុងរបបគ្រប់គ្រងរបស់ខ្មែរក្រហមឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ការចុះហត្ថលេខារួមគ្នាលើសំបុត្រនេះគឺជាជំហានសំខាន់មួយសម្រាប់រដ្ឋាភិបាលកម្ពុជានិងជាការបង្កើតនូវលទ្ធផលយូរអង្វែងមួយសម្រាប់ការចូលរួមរបស់អន្តរជាតិដើម្បីទទួលបាននូវការទទួលខុសត្រូវ ។ ប៉ុន្តែសំណាងអាក្រក់នៅក្នុងអំឡុងពេលរដ្ឋប្រហាររបស់សម្តេច ហ៊ុន សែន នៅខែកក្កដា ឆ្នាំ ១៩៩៧ ស្របពេលដែលព្រះអង្គម្ចាស់ រណឫទ្ធិ ត្រូវបានបណ្តេញចេញពីរាជរដ្ឋាភិបាល បានធ្វើឲ្យការចរចារវាងប្រទេសកម្ពុជានិងអង្គការសហប្រជាជាតិត្រូវបរាជ័យ ។ យ៉ាងណាក៏ដោយ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧ សម្តេច ហ៊ុន សែន និងលោក អ៊ឹង ហួត ជានាយករដ្ឋមន្ត្រីទីមួយនិងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានផ្ញើលិខិតទៅប្រធានាធិបតីអាមេរិក លោក ប៊ីល ក្លីនតុន ដែលមានខ្លឹមសារថា «រាជរដ្ឋាភិបាលកម្ពុជា សូមដឹងគុណរដ្ឋាភិបាលអាមេរិកយ៉ាងជ្រាលជ្រៅ ប្រសិនបើមានការផ្តល់ជំនួយទៅតាមច្បាប់អាមេរិកដើម្បីបង្កើតនូវសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិមួយនិងកាត់សេចក្តីមេដឹកនាំខ្មែរក្រហមក្នុងពេលដែលអ្នកទាំងនោះនៅរស់រានមានជីវិតនៅឡើយ» ។

### ឆ្នាំ១៩៩៨

រដ្ឋាភិបាលអាមេរិកបានកំណត់ថា គ្មានច្បាប់ជាក់លាក់ណាមួយមានអំណាចនៅក្រោមច្បាប់អាមេរិកដែលអាចយកមកអនុវត្តបាននៅក្នុងអំឡុងរបបខ្មែរក្រហមដើម្បីកាត់សេចក្តី ប៉ុល ពត និងមេដឹកនាំខ្មែរក្រហមដទៃទៀតដោយជោគជ័យនោះទេ ប្រសិនបើអ្នកទាំងនោះស្ថិតនៅក្រោមការឃុំឃាំងនៅក្នុងទឹកដីអាមេរិកនោះ ។ ប៉ុន្តែមានសេចក្តីទុកចិត្តគ្រប់គ្រាន់ដែរប្រសិនបើជនសង្ស័យណាម្នាក់ត្រូវបានឃុំខ្លួនក្រោមការឃុំឃាំងរបស់អាមេរិកឬប្រទេសដទៃទៀតនៅលើទឹកដីបរទេសដោយមានការរៀបចំពីរដ្ឋាភិបាលដទៃទៀតនិងដោយការពេញចិត្តពីរដ្ឋាភិបាលកម្ពុជា ហើយពេលនោះសហរដ្ឋអាមេរិកក៏អាចចូលរួមក្នុងការឃុំឃាំងនិងយុទ្ធសាស្ត្រនៃការឃុំឃាំងនោះ ។

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៨ បេសកជនរបស់អង្គការសហប្រជាជាតិបានបញ្ជូនអត្ថបទធម្មនុញ្ញអង្គការសហប្រជាជាតិ

ជំពូកទី៧សំដៅបង្កើតសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសកម្ពុជា (ICTC) ដែលមានតួនាទីបន្ទាប់បន្សំពីក្រុមប្រឹក្សាសន្តិសុខនៅក្នុងប្រទេសហូឡង់ ។ ទន្សឹករណ៍ចម្បងក្នុងការបង្កើតសាលាក្តីនេះគឺត្រូវធានាថានៅពេលដែលមេដឹកនាំខ្មែរក្រហមត្រូវបានចាប់ខ្លួន ឬក៏សុខចិត្តចុះចូល ហើយយ៉ាងហោចណាស់សាលាជំនុំជម្រះក្តីមានសិទ្ធិអំណាចដែលផ្តល់ដោយក្រុមប្រឹក្សាសន្តិសុខដើម្បីកាត់ទោសឲ្យបានយ៉ាងឆាប់រហ័ស ដែលបន្តដំណើរការដោយការស៊ើបអង្កេតនិងដីកាដែលធ្វើឡើងដោយព្រះរាជអាជ្ញារបស់សាលាក្តីនេះ ។ អ្នកខ្លះជាពិសេសប្រទេសចិន បានជឿជាក់ថានឹងគ្មានការគំរាមកំហែងទៀតឡើយទៅលើសន្តិភាពនិងសន្តិសុខអន្តរជាតិនៅក្នុងប្រទេសកម្ពុជា ដូច្នេះហើយទើបក្រុមប្រឹក្សាសន្តិសុខគ្មានសិទ្ធិអំណាចផ្លូវច្បាប់ដើម្បីបង្កើតស្ថាប័នតុលាការក្នុងការអនុវត្តទៅលើបុគ្គល មិនមែនយោធានោះទេ ។

សំណើរបស់អាមេរិកត្រូវបានពន្យារពេល ខណៈដែលនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបានចេញសេចក្តីប្រកាសថា ប៉ុល ពត បានស្លាប់ ហើយនេះបានបញ្ឈក់ពីចេតនាកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ដោយបានតាំងចិត្តថានឹងធ្វើការបោះឆ្នោតបែបសេរី ត្រឹមត្រូវ និងប្រជាធិបតេយ្យនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ និងស្នើសុំបង្កើតតុលាការជាតិឬអន្តរជាតិបន្ទាប់ពីការបោះឆ្នោតសាកលនៅប្រទេសកម្ពុជានៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ។ សមាជិកនៃក្រុមប្រឹក្សាអង្គការសហប្រជាជាតិកម្ពុជាក៏ចង់ពន្យារពេលចំពោះការពិចារណាលើសំណើរបស់សហរដ្ឋអាមេរិកដែរបន្ទាប់ពីការបោះឆ្នោតនោះ ។ ទំនោរទៅរកការស្នើសុំពន្យារពេលបានទទួលការគាំទ្រពីអ្នកតំណាងពិសេសអង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា លោក ថូម៉ាស់ ហាំម៉ាប៊ឺក ដែលលោកបានជ្រើសរើសអ្នកជំនាញជាន់ខ្ពស់បីរូបដើម្បីពិនិត្យទៅលើការទទួលខុសត្រូវសម្រាប់ប្រទេសកម្ពុជានិងបញ្ជូននូវអនុសាសន៍នៅក្នុងខែមេសា ឆ្នាំ១៩៩៨ ។ នេះជាលក្ខណៈអនុវត្តទូទៅរបស់អង្គការសហប្រជាជាតិ នៅពេលដែលក្រុមជំនាញឬគណៈកម្មការស៊ើបអង្កេតត្រូវបានបង្កើតឡើងដើម្បីពិនិត្យទៅលើបញ្ហាចម្រូងចម្រាស់រួចហើយ សមាជិកនៃក្រុមប្រឹក្សាសន្តិសុខបានរង់ចាំរបាយការណ៍បញ្ចប់និងបញ្ជូនរបាយការណ៍នោះទៅអង្គការសហប្រជាជាតិនៅមុនពេលចាត់វិធានការបន្តទៀត ។

នេះបង្ហាញយ៉ាងច្បាស់នូវអ្វីដែលបានកើតឡើងនៅឯអង្គការសហប្រជាជាតិទាក់ទងទៅនឹងក្រុមជំនាញលើបញ្ហារបាយការណ៍អំពីប្រទេសកម្ពុជាដែលមិនបានបញ្ជូនទៅសមាជិកអង្គការសហប្រជាជាតិរហូតដល់ខែមីនា ឆ្នាំ១៩៩៩ ។

## ឆ្នាំ១៩៩៩

នៅក្នុងអំឡុងថ្ងៃចុងក្រោយក្នុងឆ្នាំ១៩៩៨ មេដឹកនាំខ្មែរក្រហមធំៗពីររូប ខៀវ សំផន (ដៃស្តាំ ប៉ុល ពត) និង នួន ជា (បងធំទី២បន្ទាប់ពី ប៉ុល ពត) បានចុះចូលជាមួយអាជ្ញាធរកម្ពុជា និងធ្វើសមាហរណកម្មកងទ័ពរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។

ការចាប់អារម្មណ៍ពីសាធារណជននៅពេលនោះគឺថា ការលើកលែងទោសឲ្យអ្នកទាំងនោះត្រូវបានធ្វើឡើងដើម្បីធ្វើឲ្យមានអព្យាក្រឹតភាពដល់មេដឹកនាំខ្មែរក្រហមនិងនាំអ្នកទាំងអស់នោះឲ្យចេញពីព្រៃ ។

ទោះជាយ៉ាងណាក៏ដោយ សេចក្តីថ្លែងការណ៍ដែលធ្វើឡើងនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៩ សម្តេច ហ៊ុន សែន បានច្រានចោលបញ្ហានេះ ។ សហរដ្ឋអាមេរិកជាប្រទេសទីមួយដែលបានអធិប្បាយជាសាធារណៈនិងគ្មានមន្ទិលសង្ស័យស្តីពីតម្រូវការឲ្យមានការទទួលខុសត្រូវ ។

ខ្ញុំធ្លាប់បានទស្សនាប្រទេសកម្ពុជា ថៃ ចិន បារាំងនិងហូឡង់ នៅពាក់កណ្តាលខែមករា ១៩៩៩ ដើម្បីជំរុញឲ្យកាន់តែមានការទទួលខុសត្រូវនិងស្វែងរកវិធីសាស្ត្រមួយចំនួនទៀត ដោយរាប់បញ្ចូលទាំងសាលាជំនុំជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិដែលអាចនឹងបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនៅក្រោមធម្មនុញ្ញអង្គការសហប្រជាជាតិជំពូកទី៦តាមការស្នើសុំពីរដ្ឋាភិបាលកម្ពុជានិងដោយមានកិច្ចសហប្រតិបត្តិការពេញលេញ ។ ទោះបីជាគំនិតរបស់ខ្ញុំបានលើកឡើងនៅក្រោមតួនាទីរបស់អាមេរិកនៅជំពូកទី៧របស់សាលាជំនុំជម្រះក្តីដែលជាសាលាកាត់ក្តីស័ក្តិសមបំផុត ។ សាលាក្តីនេះនៅតែបើកទ្វារសម្រាប់ប្រើងប្រែងបន្តបន្ទាប់ទៀតក្នុងការស្វែងរកនូវជម្រើសផ្សេងៗ ក្រៅពីជម្រើសជំពូកទី៧ដែលមិនមានការជឿនលឿនទៅមុខសោះនៅក្នុងក្រុមប្រឹក្សា

សន្តិសុខ ។ ក្រុមជំនាញរបស់អង្គការសហប្រជាជាតិមកកាន់ប្រទេសកម្ពុជាបានសន្និដ្ឋានតាមរយៈរបាយការណ៍នៅខែមីនា១៩៩៩ថា វិធីដ៏ប្រសើបំផុតសម្រាប់ការទទួលខុសត្រូវនៅកម្ពុជាគឺតាមរយៈក្រុមប្រឹក្សាសន្តិសុខដើម្បីបង្កើតសាលាជំនុំជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិនៅក្រោមជំពូកទី៧ ដែលយកគំរូតាមសាលាកាត់ក្តីឧក្រិដ្ឋកម្មអន្តរជាតិរបស់ប្រទេសយូហ្គោស្លាវី និងសាលាកាត់ក្តីឧក្រិដ្ឋកម្មអន្តរជាតិរបស់ប្រទេសរ៉្វាន់ដា ។ នៅក្នុងទស្សនៈនេះ មានតែសាលាកាត់ក្តីអន្តរជាតិទេដែលអាចធានាបាននូវយុត្តិធម៌ស្តង់ដារអន្តរជាតិខាងផ្នែកយុត្តិធម៌ត្រឹមត្រូវ និងដំណើរការស្របតាមច្បាប់ ។ ប៉ុន្តែរបាយការណ៍របស់ក្រុមជំនាញនៃអង្គការសហប្រជាជាតិសម្រាប់ប្រទេសកម្ពុជាមិនបានពិភាក្សាឲ្យស៊ីជម្រៅជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានគូសបញ្ជាក់នៅក្នុងសំបុត្រផ្ញើទៅលោក កូហ្វី អាណាន់ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិថាឱសានវាទរបស់សម្តេច ហ៊ុន សែន និងការវិភាគទៅលើថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៩ ដែលស្វែងរកយុត្តិធម៌ឲ្យបានកាន់តែទូលំទូលាយសម្រាប់ប្រទេសនិងប្រជាជនកម្ពុជា ហើយសំបុត្រនោះស្នើសុំឲ្យមានការស៊ើបអង្កេតពេញលេញទៅលើបទឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងចាប់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៩៨ ។

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ តាម៉ុក ដែលជាមេបញ្ជាការមួយរូបក្នុងចំណោមពីររូបដែលមានតួនាទីជាអ្នក «សម្រេច» នៅក្នុងគណៈកម្មាធិការមជ្ឈមក្នុងរបបខ្មែរក្រហម ត្រូវបានកងទ័ពរដ្ឋាភិបាលកម្ពុជាចាប់ខ្លួន ។ ភារកិច្ចក្នុងការកាត់សេចក្តីឥស្សរជនសំខាន់ៗរបស់របបនេះ បានក្លាយទៅជាការពិតភ្លាមៗនោះដែរ ។ យ៉ាងណាមិញ លោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេសបានបដិសេធចោលនូវអនុសាសន៍របស់ក្រុមជំនាញនៃអង្គការសហប្រជាជាតិនោះ ថែមទាំងជំទាស់ការបង្កើតសាលាជំនុំជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិ ហើយថែមទាំងបាននិយាយថាប្រទេសកម្ពុជាអាចកាត់សេចក្តីមេដឹកនាំខ្មែរក្រហមដោយតុលាការខ្លួនឯងបាន ។

នៅថ្ងៃទី២៨ មេសា ១៩៩៩ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ញើលិខិតទៅលោក អាណាន់ ដោយបញ្ជាក់ថា នឹងមានការជំនុំជម្រះក្តី តាម៉ុក ដោយតុលាការនៅក្នុងស្រុក «ជាមួយនឹងជំនួយពីបរទេសដែលមានចៅក្រមនិងព្រះរាជអាជ្ញាបរទេសអនុញ្ញាតឲ្យចូលរួមដើម្បីធានាឲ្យប្រាកដថាការកាត់សេចក្តីនឹងប្រព្រឹត្តទៅតាមបទដ្ឋានច្បាប់អន្តរជាតិត្រឹមត្រូវ» ។

នៅខែមិថុនា ឆ្នាំ១៩៩៩ ការចរចានៅក្នុងទីក្រុងវ៉ាស៊ីន-តោន បានឈានដល់ទីបញ្ចប់ ដែលកន្លងមកមានវិវាទរវាងការបង្កើតនូវសាលាជំនុំជម្រះក្តីចម្រុះពីសំណាក់ក្រុមប្រឹក្សាសន្តិសុខនិងរាជរដ្ឋាភិបាលកម្ពុជា ។

តួនាទីថ្មីរបស់សហរដ្ឋអាមេរិកដែលបានសង្ខេបត្រួសៗទៅសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅកក្កដា ឆ្នាំ១៩៩៩បានស្នើឡើងថា «សាលាជំនុំជម្រះក្តីពិសេស» នឹងត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាសន្តិសុខ ក្រោមសេចក្តីសម្រេចដែលអាចដំណើរការបាន (នៅក្រៅជំពូកទី៧ ដូច្នេះហើយទើបវាឆ្លុះបញ្ចាំងនូវគំនិតទាំងអស់នោះនៅដើមឆ្នាំ១៩៩៩) ។ រដ្ឋាភិបាលកម្ពុជាអាចនឹងយល់ព្រមនូវគោលការណ៍សំខាន់ៗរបស់អង្គការសហប្រជាជាតិក្នុងការគ្រប់គ្រងសាលាជំនុំជម្រះក្តីចម្រុះនៅលើទឹកដីកម្ពុជា ។

នៅថ្ងៃទី៣០ កក្កដា ឆ្នាំ១៩៩៩ ជំនួយការអគ្គលេខាធិការរបស់អង្គការសហប្រជាជាតិពីររូបគឺ លោក អាល់វ៉ារ៉ូ ដឺ សូតូ (ផ្នែកការងារនយោបាយ) និង លោក រាលហ្វ៍ បានធ្វើសេចក្តីស្នើសុំដែលជាការចាកចេញយ៉ាងរហ័សសម្រាប់របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា កិច្ចព្រមព្រៀង ហើយបោះបង់ចោលនូវការចូលរួមរបស់ក្រុមប្រឹក្សាសន្តិសុខនៅក្រោមជំពូកទី៦និងទី៧ឬក្រោមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ។

បន្ទាប់មកនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩ សម្តេច ហ៊ុន សែន បានបដិសេធយ៉ាងអហង្កានូវគម្រោងរបស់អង្គការសហប្រជាជាតិដែលបានលេចឮដល់បណ្តាញសារព័ត៌មាននៅក្នុងរបាយការណ៍នោះបានបង្ហាញនូវពាក្យសម្តីដូចដែលបានរាយការណ៍នៅពេលនោះថាៈ «ហ៊ុនសែនបានចាត់ទុករបាយការណ៍នោះជាបញ្ហាថាតើកម្ពុជាគួរតែសហប្រតិបត្តិការជាមួយនឹងអង្គការសហប្រជាជាតិឬអង្គការសហប្រជាជាតិគួរសហប្រតិបត្តិការជាមួយកម្ពុជា?»

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងឯកឧត្តម សុខ អាន

(ប្រធានទីស្តីការគណៈរដ្ឋមន្ត្រីនិងទីប្រឹក្សាជាន់ខ្ពស់របស់សម្តេច ហ៊ុន សែន ទទួលខុសត្រូវលើការងារកាត់ទោសខ្មែរក្រហម) បាន ជួបជាមួយអនុរដ្ឋមន្ត្រីក្រសួងការបរទេស ផ្នែកការងារនយោបាយ លោក ថម ភីកឃ័ររីង រួមទាំងខ្ញុំផង ។ នៅខែកញ្ញា ឆ្នាំ១៩៩៩ ភីកឃ័ររីង បានជំរុញឲ្យសម្តេច ហ៊ុន សែន បោះបង់ចោលនូវ ជម្រើសទាំង៣ ដែលសម្តេចទើបតែបានដាក់ជូនទៅលោក អាណាន់ នៅទីក្រុង ញ៉ូវយ៉ក ហើយជំនួសដោយការយល់ព្រមនូវការ បង្កើត «អង្គជំនុំជម្រះពិសេសមួយ» ឬ«អង្គប្រជុំពិសេសមួយ» នៅ ក្នុងសាលាក្តីកម្ពុជាដែលមានចៅក្រមអន្តរជាតិភាគច្រើនចូលរួម ។

តាមការអញ្ជើញរបស់សម្តេច ហ៊ុន សែន ខ្ញុំធ្លាប់បាន ទស្សនាប្រទេសកម្ពុជានៅចុងខែតុលា ឆ្នាំ១៩៩៩ និងត្រៀម រៀបចំសេចក្តីព្រាង«ច្បាប់ស្តីពីការបង្កើតសម័យប្រជុំវិសាមញ្ញ ក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសនូវរាល់បទឧក្រិដ្ឋកម្មដែល ប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយភ្លាមៗនោះ ក៏បានផ្លាស់ប្តូរសំណើរបស់ខ្ញុំទៅជា«អង្គជំនុំជម្រះវិសាមញ្ញ» ដែលមិនមែនជា «អង្គប្រជុំវិសាមញ្ញ» ។ អង្គជំនុំជម្រះវិសាមញ្ញក៏ បានបញ្ចូលបញ្ញត្តិ non bis in idem ដើម្បីធានាឲ្យប្រាកដថា អង្គជំនុំជម្រះវិសាមញ្ញនឹងកំណត់ថាតើការកាត់ក្តីពីពេលមុនបាន ឆ្លើយតបតាមបទដ្ឋានយុត្តិធម៌អន្តរជាតិនិងដំណើរការសមស្រប ក្នុងពេលកាត់សេចក្តីដែរឬទេ ។ សេចក្តីព្រាងច្បាប់នេះក៏បានស្នើ ឲ្យសហព្រះរាជអាជ្ញាពីររូបម្នាក់ជាកម្ពុជានិងម្នាក់ទៀតជាជនជាតិ បរទេសដែលរួមគ្នាស៊ើបអង្កេត រៀបចំដីការចោទប្រកាន់និងចោទ ប្រកាន់ ។ តម្រូវការសំឡេងឆ្នោតភាគច្រើនលើសលប់ត្រូវបាន ចែងលម្អិតនៅក្នុងសាលាក្តីនេះដែលមានការចូលរួមភាគច្រើនពី ចៅក្រមកម្ពុជា ។

មន្ត្រីកម្ពុជាបានឆ្លើយតបវិញជាវិជ្ជមាន ហើយបន្តការ រៀបចំឯកសារនិងបានបញ្ជូនសេចក្តីព្រាងច្បាប់ទៅមេធាវីអង្គការ សហប្រជាជាតិនៅចុងខែធ្នូ ឆ្នាំ១៩៩៩ ។ មេធាវីនោះបាន បញ្ចេញនូវប្រតិកម្មជាអវិជ្ជមាន ។ ការកែប្រែបន្ថែមទៅលើ សេចក្តីព្រាងច្បាប់នោះ អនុលោមតាមសំបុត្រចុះកាលបរិច្ឆេទនៅ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៩ ឯកឧត្តម សុខ អាន ក៏បានដាក់ជូន សេចក្តីព្រាងច្បាប់ឲ្យទៅលោក អាណាន់ ដើម្បីត្រួតពិនិត្យដោយ អង្គការសហប្រជាជាតិ ។

**ឆ្នាំ២០០០**

នៅដើមខែមករា ឆ្នាំ២០០០ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានយល់ព្រមតាមសំណើឲ្យមានសហចៅក្រមស៊ើប អង្កេតដែលមានម្នាក់ជាជនជាតិខ្មែរនិងម្នាក់ទៀតជាជនជាតិបរទេស ដែលត្រូវជ្រើសរើសដោយអគ្គលេខាធិការនៃអង្គការសហប្រជា ជាតិ ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានយល់ព្រម ដោះស្រាយរាល់បញ្ហាដែលនៅសេសសល់ រាប់បញ្ចូលទាំងការ ធានាអះអាងដែលលោក អៀង សារី (អតីតរដ្ឋមន្ត្រីក្រសួងការ បរទេសក្នុងរបប ប៉ុល ពត) នឹងមិនអាចត្រូវជាត់ចេញពីយុត្តិសាស្ត្រ របស់អង្គជំនុំជម្រះវិសាមញ្ញឡើយ ថ្វីបើមានការលើកលែងទោស ក្នុងស្រុកដែលបានព្រមព្រៀងជាមួយគាត់នៅឆ្នាំ១៩៩៦ ក៏ដោយ ។

លោក អាណាន់ បានជួបសម្តេច ហ៊ុន សែននៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០០ក្នុងទីក្រុងបាងកក ហើយបានសង្កត់ធ្ងន់ទៅ លើតម្រូវឲ្យមាន «កម្រិតស្តង់ដារអន្តរជាតិអប្បបរិមា» នៅក្នុង ពេលដែលមានការយល់ព្រមបញ្ជូនក្រុមចរចារបស់អង្គការសហ ប្រជាជាតិទៅទីក្រុងភ្នំពេញក្នុងខែមីនា ។ ភ្លាមៗនោះ មុនពេលដែល ក្រុមអង្គការសហប្រជាជាតិធ្វើដំណើរទៅប្រទេសកម្ពុជា សហរដ្ឋ អាមេរិកបានធ្វើអន្តរាគមន៍ចំពោះសំណើដែលថា គួរតែបង្កើតអង្គ បុរេជំនុំជម្រះ ដែលអាចជួបប្រជុំដើម្បីដោះស្រាយជម្លោះរវាង សហចៅក្រម ព្រះរាជអាជ្ញា និងជម្លោះរវាងសហចៅក្រមស៊ើប អង្កេត ។

នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០០ ឯកឧត្តម សុខ អាន បាន ជូនលិខិតមួយច្បាប់ទៅលោក កូរែល អគ្គលេខាធិការរងទទួល បន្ទុកផ្នែកកិច្ចការច្បាប់និងក្រុមប្រឹក្សាច្បាប់របស់អង្គការសហ-ប្រជាជាតិ ដោយបង្ហាញថារដ្ឋាភិបាលកម្ពុជានឹងមិនស្នើសុំឲ្យការ លើកលែងទោសទៀតទេ ។ ប៉ុន្តែនៅថ្ងៃទី២១ មីនា លោក កូរែល បានបដិសេធចោលនូវការសម្របសម្រួលនោះនៅក្នុងការចរចា ហើយភាគីទាំងពីរបានជាប់គាំង ។

នៅខែមេសា ឆ្នាំ២០០០មានន័យកំណត់ច្បាស់លាស់ ។ បន្ថែមទៅលើដំណើរទស្សនកិច្ចផ្ទាល់របស់ខ្ញុំជាមួយក្រុមអ្នកចរចា

កម្ពុជា សមាជិកសភាអាមេរិកលោក ចន ឃែរី បានចាប់ផ្តើមចូលរួមនិងប្រើឥទ្ធិពលគួរឲ្យកត់សម្គាល់ជាមួយលោក អាណាន់ លោក កូរែល និងសម្តេច ហ៊ុន សែន ដោយផ្ទាល់តាមរយៈទូរស័ព្ទ និងការសួរសុខទុក្ខដោយផ្ទាល់ ។

ក្រុមបេសកម្មរបស់អង្គការសហប្រជាជាតិបានចរចាលើសេចក្តីព្រាងស្តីពីអនុស្សារណៈយោគយល់ ដោយសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិនិងកម្ពុជាក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងការបង្កើតឡើងនូវកំណត់ត្រាច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញដើម្បីធានាឲ្យប្រាកដពីភាពស៊ីសង្វាក់គ្នានៃអនុស្សារណៈយោគយល់ ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក ឃែរី បានយល់ព្រមទៅលើពេលវេលាសម្រាប់ការអនុម័តច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅត្រឹមពាក់កណ្តាលខែធ្នូ ឆ្នាំ២០០០ ។ ខាងផ្នែកនិតិបញ្ញត្តិ រដ្ឋាភិបាលកម្ពុជាបានបោះជំហានទៅដល់ការតែងច្បាប់ព្រាងរបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ ច្បាប់នេះក៏បានអនុម័តដោយរដ្ឋសភាជាតិ ។

## ឆ្នាំ២០០១ដល់ឆ្នាំ២០០៧

នៅថ្ងៃទី១៥ មករា ២០០១ ព្រឹទ្ធសភាកម្ពុជាបានអនុម័តច្បាប់អង្គជំនុំជម្រះវិសាមញ្ញជាឯកច្ឆ័ន្ទ ។ ត្រឹមពាក់កណ្តាលរដូវប្រាំងក្នុងឆ្នាំ២០០១ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបញ្ចប់ និងឡាយព្រះហត្ថដោយសម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ។

បើពិនិត្យមើលរយៈពេលអន្តរការទៅកាន់រដ្ឋការលោក ប៊ូស នៅក្នុងសហរដ្ឋអាមេរិកនៅចុងខែមករា ឆ្នាំ២០០១ ជាមួយនឹងអាទិភាពផ្សេងៗពីគ្នា ព្រមទាំងការចាកចេញពីតំណែងរបស់ខ្ញុំនៅថ្ងៃចុងក្រោយនៃរដ្ឋការលោក គ្លីនតុន ចំណាប់អារម្មណ៍របស់សហអាមេរិកទៅលើដំណើរតុលាការក្នុងប្រទេសកម្ពុជាក៏បានធ្លាក់ចុះ ។ ក្រុមអង្គការសហប្រជាជាតិមានការសោកស្តាយដែលច្បាប់អង្គជំនុំជម្រះវិសាមញ្ញបានអនុម័តមុនពេលមានការធានាឲ្យមានភាពស៊ីសង្វាក់គ្នានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងកម្ពុជាទៅទៀត ។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ លោក កូរែល បានបញ្ជាក់ថា «អង្គការសហប្រជាជាតិបានឈានដល់សេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះវិសាមញ្ញនឹងមិនធានានូវឯករាជ្យភាព ភាពមិនលម្អៀង និងកក្តាសត្យានុម័តដែលសាលាក្តីត្រូវបានបង្កើតឡើងក្រោមការគាំទ្រពីអង្គការសហប្រជាជាតិ ដូច្នេះហើយទើបអង្គការសហប្រជាជាតិសម្រេចបញ្ចប់ការចូលរួមក្នុងដំណើរការនេះ» ។

ក្រុមស្នូលនៃរដ្ឋាភិបាលទាំងឡាយរួមមាន ជប៉ុន បារាំង អូស្ត្រាលី សហរដ្ឋអាមេរិក កាណាដា និងអង់គ្លេសបានចាប់ផ្តើមចោទសួរទៅលើការវិនិច្ឆ័យរបស់លោក កូរែល ដែលបានបញ្ឈប់ការចរចានោះ ។ ជម្រើសផ្សេងទៀតក៏បានរកឃើញ ហើយនៅខែកក្កដា ឆ្នាំ២០០២ សម្តេច ហ៊ុន សែន បានមានប្រសាសន៍ថាកម្ពុជាអាចនឹងធ្វើវិសោធនកម្មច្បាប់អង្គជំនុំជម្រះវិសាមញ្ញខ្លះៗដោយសារការបារម្ភរបស់អង្គការសហប្រជាជាតិ ។ ឱសានវាទប្រមែប្រមូលបាននៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិដើម្បីចូលរួមឡើងវិញ ទៅលើការជំរុញឲ្យមានការទទួលខុសត្រូវនៅកម្ពុជា ។ នៅទីបញ្ចប់ នៅក្នុងសេចក្តីសម្រេចចិត្តលេខ៥៧/២២៨ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០២ មហាសន្និបាតបានស្វាគមន៍ការអនុម័តច្បាប់អង្គជំនុំជម្រះវិសាមញ្ញ និងស្នើឲ្យលោក អាណាន់ បន្តការចរចាឡើងវិញដោយមិនបង្អែបង្អង់ឡើយ ។ ដូច្នេះដោយមានការណែនាំពីមហាសន្និបាត លោក អាណាន់ និង លោក កូរែល មានជម្រើសតិចតួចណាស់ក្រៅពីបន្តការចរចាជាមួយកម្ពុជា ។ ប៉ុន្តែកិច្ចប្រឹងប្រែងដំបូងដោយគ្មានក្រដាសស្នាមដែលមានតែកាលបរិច្ឆេទនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០០៣ បានត្រឡប់មករកបញ្ហាមួយចំនួនដែលបានដោះស្រាយនៅមុនខែកុម្ភៈ ឆ្នាំ២០០២ ក្នុងអំឡុងពេលមានការចរចារវាងលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។

ដោយមានការចរចាបន្ថែមទៀត នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ អត្ថបទទាំងអស់ត្រូវបានបញ្ចប់ ហើយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាត្រូវបានចុះហត្ថលេខាពីភាគីទាំងសងខាង ។ មហាសន្និបាតក៏លើកឡើងថា រាល់ការចំណាយរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងត្រូវផ្តល់ដោយវិភាគទានស្ម័គ្រចិត្តពីសហគមន៍អន្តរជាតិ ។

ទីបំផុត កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា

ត្រូវបានផ្តល់សច្ចាប័នពីរដ្ឋសភាកម្ពុជានៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ និងបានប្រកាសឲ្យប្រើជាផ្លូវការនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤ បន្ទាប់ពីធ្វើវិសោធនកម្មលើច្បាប់អង្គជំនុំជម្រះវិសាមញ្ញដើម្បីធានាឲ្យប្រាកដថា ឯកសារទាំងពីរនឹងមានភាពស៊ីសង្វាក់គ្នា ។ នៅខែមីនា ឆ្នាំ២០០៥ ការរួមវិភាគទានស្ម័គ្រចិត្តរបស់សហគមន៍អន្តរជាតិជាច្រើនលើថវិការយៈពេល៣ឆ្នាំសម្រាប់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានសន្យា ។ ចៅក្រម សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតកម្ពុជានិងអន្តរជាតិបានធ្វើពិធីសម្បថចូលកាន់មុខតំណែងនៅខែកក្កដា ឆ្នាំ២០០៦ ដែលនៅក្នុងពេលនោះសហព្រះរាជអាជ្ញាក៏បានចាប់ផ្តើមកិច្ចការស៊ើបអង្កេតបឋម ។ ក្រុមចៅក្រមដែលស្ថិតក្រោមការដឹកនាំរបស់សហចៅក្រមស៊ើបអង្កេត ម៉ាសែល ឡឺម៉ុង (ជនជាតិបារាំង) បានពិនិត្យមើលលើសេចក្តីព្រាងច្បាប់និងចរចាទៅលើវិធានផ្ទៃក្នុង (ជាពិសេសវិធាននិតិវិធីនិងភស្តុតាង) នៃអង្គជំនុំជម្រះវិសាមញ្ញ ។ រហូតដល់ខែមិថុនា ឆ្នាំ២០០៧ ដែលមានរយៈពេលជិត១ឆ្នាំគិតចាប់តាំងពីដែលសហព្រះរាជអាជ្ញាចាប់ផ្តើមដំណើរការទើបចៅក្រមក្នុងសម័យប្រជុំពេញអង្គអនុម័តវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

## ផ្នែកទីពីរ

## របនាសម្ព័ន្ធធម្មនុញ្ញរបស់អង្គជំនុំជម្រះវិសាមញ្ញ

នៅក្នុងទម្រង់ចុងក្រោយ អង្គជំនុំជម្រះវិសាមញ្ញមានរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញធំៗ៣ដែលអាចយល់បានក្នុងការពិនិត្យទៅលើកិច្ចការនៅក្នុងអង្គជំនុំជម្រះ ។ គោលធំៗទាំងបីនោះរួមមានៈ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា និងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ (ទាំងអស់នេះគឺជាឯកសារចាំបាច់របស់អង្គជំនុំជម្រះវិសាមញ្ញ) ។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបានចរចាដោយមានចេតនាជាក់លាក់ ដូចបានបញ្ជាក់នៅក្នុងច្បាប់និងសន្ធិសញ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលអង្គជំនុំជម្រះវិសាមញ្ញនឹងប្រើប្រាស់ច្បាប់នៅក្នុងប្រទេសកម្ពុជានិងអនុវត្តច្បាប់កម្ពុជា ។ ការងាកចេញពីច្បាប់សំខាន់នេះអាចនឹងធ្វើឲ្យអង្គការសហប្រជាជាតិមិនបន្តកិច្ចសហប្រតិបត្តិការអនុលោមតាមមាត្រា២៨នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ។

នៅក្នុងផ្នែកនេះ ខ្ញុំពិនិត្យមើលអំពីការដាក់បញ្ចូលគ្នានូវរាល់ឯកសារចាំបាច់របស់អង្គជំនុំជម្រះវិសាមញ្ញដែលមានផ្នែកសំខាន់ចំនួន៧សម្រាប់កិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការការតែងតាំងនិងការគ្រប់គ្រង ការធ្វើសេចក្តីសម្រេច ការអភ័យទោសនិងលើកលែងទោស សិទ្ធិទទួលបានការកាត់សេចក្តីត្រឹមត្រូវ ការដកថយពីកិច្ចសហប្រតិបត្តិការ និងសិទ្ធិរបស់ជនរងគ្រោះ ។

### យុត្តាធិការ

ការផ្តោតអារម្មណ៍របស់យើងនឹងមើលទៅលើយុត្តាធិការពេលវេលា យុត្តាធិការបុគ្គល យុត្តាធិការដែនដី និងបទល្មើស ។

### ក) យុត្តាធិការពេលវេលា

យុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញ ពោលគឺរយៈពេលដែលបទឧក្រិដ្ឋតាមការចោទប្រកាន់ដែលត្រូវអង្គជំនុំជម្រះស៊ើបអង្កេត ត្រូវកើតឡើងដោយគិតចាប់តាំងពីថ្ងៃចាប់ផ្តើមរហូតដល់ថ្ងៃបញ្ចប់របស់របប ប៉ុល ពត គឺពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ។ ដូចដែលធ្លាប់បានជួបប្រទះនៅក្នុងការចរចាបង្កើតតុលាការឧក្រិដ្ឋកម្មផ្សេងៗទៀតដែរ យុត្តាធិការពេលវេលាដ៏ចង្អៀតសម្រាប់អំពើឧក្រិដ្ឋកម្មដ៏ឃោរឃៅបែបនេះក៏ធ្លាប់កើតមាននៅក្នុងតុលាការជាច្រើន ។

### ខ) យុត្តាធិការបុគ្គល

បុគ្គលទាំងឡាយដែលអាចនឹងត្រូវស៊ើបអង្កេតនិងចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ មានតែអ្នកប្រព្រឹត្តបទឧក្រិដ្ឋកម្មមួយចំនួនតូចប៉ុណ្ណោះគឺ «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត» ចំពោះបទឧក្រិដ្ឋកម្មដែលមាននៅក្នុងយុត្តាធិការបទល្មើសរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ បុគ្គលមួយចំនួនតូចនេះឆ្លុះបញ្ចាំងពីគោលបំណងដើមដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញដែលនឹងស៊ើបអង្កេតនិងកាត់ទោសមេដឹកនាំកំពូលរបស់របប ប៉ុល ពត និងអ្នកប្រព្រឹត្តអំពើឃោរឃៅក្នុងអំឡុងពេលនោះ ។ ជាមួយគ្នានេះដែរ ទាំងអស់នេះក៏បានឆ្លុះបញ្ចាំងពីលទ្ធភាពនិងធនធានមានកម្រិតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការបើកការងារស៊ើបអង្កេតនិងជំនុំជម្រះក្តី ។

### គ) យុត្តាធិការសមត្ថកិច្ច

មិនមានយុត្តាធិការសមត្ថកិច្ចជាក់លាក់ណាមួយ នៅក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សាលាកាត់ឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉ាន់ដា និងសាលាក្តីពិសេសរបស់សេរ៉ាឡេអូន ។ ការពិតអង្គជំនុំជម្រះវិសាមញ្ញគឺជាសាលាក្តីជាតិរបស់ប្រទេសកម្ពុជា ។ ប្រការនេះអាចនឹងពន្យល់ប្រាប់ពីភាពខុសគ្នាទៅនឹងសាលាក្តីជាតិដទៃទៀត ចំពោះការកំណត់ដែនសមត្ថកិច្ចរបស់ប្រទេសដរាបណាមានមូលដ្ឋានយុត្តាធិការបន្ថែមសម្រាប់សាលាក្តីក្រៅត្រូវបានលើកឡើងដែលមិនទាន់មានសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។

## ឃ) យុត្តាធិការបទល្មើស

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានចែងនៅក្នុងមាត្រាទី៤នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញបានកំណត់និយមន័យជាក់លាក់ដោយយោងទៅតាមនិយមន័យរបស់អនុសញ្ញាស្តីពីការការពារនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍នៅក្នុងឆ្នាំ១៩៤៨ ។ និយមន័យនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់អង្គជំនុំជម្រះវិសាមញ្ញមានលក្ខណៈដូចនឹងនិយមន័យរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាដែរ ។ គោលការណ៍ពិតប្រាកដចំពោះភាពខុសប្លែកគ្នារវាងឯកសារទាំងពីរគឺថាកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងកម្ពុជាបានប្រកាន់យកនូវនិយមន័យបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលមិនកម្រិតនិយមន័យឲ្យនៅត្រឹមតែការវាយប្រហារសំដៅលើជនស៊ីវិលដោយឈរលើមូលដ្ឋានជនជាតិ នយោបាយ ជាតិពន្ធុ សញ្ជាតិ ឬសាសនាឡើយ ។ ទាំងនេះ ជាការកម្រិតសំខាន់ចំពោះមាត្រាទី៥នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានដកស្រង់ចេញពីមាត្រាទី៣នៃច្បាប់របស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិរ៉ាន់ដា ។

ប្រហែលជាបទឧក្រិដ្ឋកម្មមួយដែលទទួលការចោទប្រកាន់តិចតួចជាងគេនោះគឺបទឧក្រិដ្ឋកម្មសង្គ្រាម ដែលបានចែងនៅក្នុងមាត្រាទី៦នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញដែលច្បាប់នេះបានធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការទៅលើការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។ ដូចដែលបានធ្វើវិសោធនកម្មរួចហើយ មាត្រាទី៣នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញបានកំណត់បទឧក្រិដ្ឋបីផ្សេងៗគ្នានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ របស់កម្ពុជា គឺអំពើមនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា ។ បទឧក្រិដ្ឋកម្មនេះសុទ្ធតែបានបញ្ចូលទៅក្នុងយុត្តាធិការបទល្មើសដោយមានដែនអាជ្ញាយុកាលសម្រាប់រយៈពេល៣០ឆ្នាំបន្ថែមទៀត លើសពីការអនុវត្តន៍ធម្មតា ។ ការចោទប្រកាន់លើបទឧក្រិដ្ឋពិសេសទាំងនេះអាចនឹងមានប្រយោជន៍សម្រាប់ចុងចោទមួយចំនួន បន្ថែមទៅលើបទឧក្រិដ្ឋកម្មឃោរឃៅដូចដែលមាននៅក្នុងមាត្រា៤ មាត្រា៥ និងមាត្រា៦នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញ ហើយជាពិសេសប្រសិនតម្រូវការខ្ពស់ ព្រមទាំងចេតនាដែលតម្រូវឲ្យមានចំពោះបទឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងមាត្រាខាងលើនេះ នៅពេលក្រោយនឹងពិបាកក្នុងការបង្ហាញឲ្យឃើញច្បាស់ណាស់ ។

## ការតែងតាំងនិងការគ្រប់គ្រង

អង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានច្បាប់អង្គជំនុំជម្រះវិសាមញ្ញបង្កើតឡើងជាសាលាក្តីថ្មីនិងដាច់ដោយឡែកស្ថិតក្នុងប្រព័ន្ធតុលាការកម្ពុជា មានចៅក្រមសរុប១៧រូប នៅក្នុងអង្គជំនុំជម្រះទាំងបីថ្នាក់នេះ ។ នៅក្នុងអង្គជំនុំជម្រះនីមួយៗ ចៅក្រមភាគច្រើនជាជនជាតិខ្មែរដែលលទ្ធផលនេះជាការទាមទាពីសំណាក់អ្នកចរចាកម្ពុជានិងត្រូវបានជំទាស់ដោយក្រុមមេធាវីនៃអង្គការសហប្រជាជាតិ ។

នៅក្នុងការសម្របសម្រួលរវាងប្រពៃណីនៃច្បាប់ខមិនឡ (ច្បាប់ប៉ែកបស្ចិមប្រទេស)គឺព្រះរាជអាជ្ញាដែលពូកែ និងប្រពៃណីនៃប្រព័ន្ធច្បាប់ស៊ីវិលរបស់សហចៅក្រមស៊ើបអង្កេត រូបមន្តមួយត្រូវបានបង្កើតឡើងមុខនាទីទាំងពីរ ហើយលើសពីនេះទៀតជួយរំលែកទំនួលខុសត្រូវនៅក្នុងការិយាល័យនីមួយៗរវាងជនជាតិខ្មែរនិងជនជាតិបរទេស ។ ដូច្នេះនៅក្នុងសាលាក្តី មានសហចៅក្រមស៊ើបអង្កេតចំនួនពីររូប ដែលមានម្នាក់ជាប្រជាពលរដ្ឋខ្មែរនិងម្នាក់ទៀតជាជនជាតិបរទេសដែលត្រូវបានតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អ្នកទាំងពីរទទួលខុសត្រូវរួមគ្នាលើរាល់ដីកាចោទប្រកាន់និងការស៊ើបអង្កេត ។ លើសពីនេះទៅទៀតក៏នៅមានសហព្រះរាជអាជ្ញាពីររូបទៀតដែលម្នាក់ជាជនជាតិខ្មែរនិងម្នាក់ទៀតជាជនជាតិបរទេសដែលត្រូវតែងតាំងដោយ

អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ សហព្រះរាជអាជ្ញាទាំងពីរទទួលខុសត្រូវរាល់ការស្នើសុំសម្រាប់ការចេញដីកានិងការចោទប្រកាន់ ។ អង្គជំនុំជម្រះវិសាមញ្ញក៏មានរចនាសម្ព័ន្ធរដ្ឋបាលនិងមូលនិធិបំបែកជាពីរដែរ ដោយមានប្រធានកម្ពុជាជាអ្នកជ្រើសរើសនិងគ្រប់គ្រងបុគ្គលិកកម្ពុជានិងមានបុគ្គលិកបរទេសត្រូវបានជ្រើសរើសហើយគ្រប់គ្រងដោយតំណាងអនុប្រធានមួយរូបដែលតែងតាំងមកពីអង្គការសហប្រជាជាតិ ។ អនុប្រធានរូបនេះក៏នឹងជាអ្នកគ្រប់គ្រងនូវមូលនិធិស្ម័គ្រចិត្តអន្តរជាតិដែលផ្ញើទុកនៅក្នុងមូលនិធិជឿទុកចិត្តរបស់អង្គការសហប្រជាជាតិ ។ ភាសាផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញគឺភាសាខ្មែរ ប៉ុន្តែរាល់ការងារជាផ្លូវការមានភាសាខ្មែរ អង់គ្លេសនិងភាសាបារាំង ។ ក្រុមអ្នកចរចាកម្ពុជា បានស្វះស្វែងជាយូរមកហើយទទួលបានជោគជ័យក្នុងការបញ្ចូល ការបកប្រែភាសារុស្ស៊ីលើរាល់ឯកសារទូទៅ ព្រមទាំងការបកប្រែផ្ទាល់មាត់ក៏ប៉ុន្តែកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាបានទាមទារថា កិច្ចការទាំងនេះគួរតែជាឆន្ទានុសិទ្ធិនិងការចំណាយរបស់រដ្ឋាភិបាលកម្ពុជា ។ មេធាវីនិងចៅក្រមជាច្រើនសុទ្ធតែបានសិក្សានៅប្រទេសរុស្ស៊ី ។

## ការធ្វើសេចក្តីសម្រេចចិត្ត

រាល់ការវិនិច្ឆ័យដោយអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះឬអង្គជំនុំជម្រះតុលាការកំពូលតម្រូវឲ្យមានសំឡេងភាគច្រើនលើសលប់របស់ចៅក្រម (ភាគច្រើន+១) ។ នេះមានន័យថា រាល់ការសម្រេចចិត្តនិងការវិនិច្ឆ័យនឹងទាមទារនូវសំឡេងឆ្នោតវិជ្ជមានពីចៅក្រមកម្ពុជានិងចៅក្រមអន្តរជាតិ ទោះបីជាសំឡេងឆ្នោតចម្រុះនេះអាចមានភាពផ្សេងៗពីគ្នាក៏ដោយ ។ គោលដៅចរចាចម្បងបំផុតនៃសំឡេងឆ្នោតភាគច្រើនដាច់ខាតនេះគឺដើម្បីធានាឲ្យប្រាកដថានឹងគ្មានសំឡេងឆ្នោតមកតែពីចៅក្រមកម្ពុជាឡើយ ហើយក៏គ្មានសំឡេងមកពីតែចៅក្រមបរទេស ។ ទាក់ទងទៅនឹងសិទ្ធិទទួលបានដំណើរការសមស្រប គ្មានជនជាប់ចោទណាម្នាក់នឹងត្រូវកាត់ឲ្យជាប់ទោសដោយគ្មានសំឡេងយល់ព្រមយ៉ាងតិចណាស់ម្នាក់ពីសំណាក់ចៅក្រមបរទេសនោះទេ ។

វិធីតែមួយគត់ដែលខាងព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេតត្រូវបានបញ្ឈប់នោះលុះត្រាតែអង្គបុរេជំនុំជម្រះធ្វើសេចក្តីសម្រេចចិត្តតាមរយៈសំឡេងឆ្នោតភាគច្រើនលើសលប់ ។ ហេតុផលនៅពីក្រោយនិតិវិធីនេះគឺដើម្បីទប់ស្កាត់សហចៅក្រមស៊ើបអង្កេតម្នាក់ ឬសហចៅក្រមព្រះរាជអាជ្ញាម្នាក់កុំឲ្យរារាំងការស៊ើបអង្កេតឬចោទប្រកាន់ ដោយសារតែមិនអាចឈានដល់កិច្ចព្រមព្រៀងជាមួយសមភាគីរបស់ខ្លួន ឬធ្វើឲ្យបរាជ័យដល់ការស៊ើបអង្កេតឬការចោទប្រកាន់ដោយឥទ្ធិពលនយោបាយឬឥទ្ធិពលផ្សេងៗទៀត ។

ច្បាប់អង្គជំនុំជម្រះវិសាមញ្ញដើមដំបូងបង្អស់ ដែលបានចរចារហូតដល់ឆ្នាំ២០០០និងត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០១បានផ្តល់នូវអង្គជំនុំជម្រះសាលាឧទ្ធរណ៍មួយរវាងអង្គជំនុំជម្រះនិងតុលាការកំពូល ។ យ៉ាងណាក៏ដោយ ដោយឈរលើបញ្ហាថវិកាក្រុមអ្នកចរចាអង្គការសហប្រជាជាតិស្តីពីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាបានស្វះស្វែងធ្វើវិសោធនកម្មលើច្បាប់អង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០៤ ។ វិសោធនកម្មច្បាប់នេះ បានដកអង្គជំនុំជម្រះសាលាឧទ្ធរណ៍ចេញពីអង្គជំនុំជម្រះវិសាមញ្ញដែរ ។

## ការអភ័យទោសនិងការលើកលែងទោស

ទាំងក្រុមអ្នកចរចារបស់សហរដ្ឋអាមេរិកនិងអង្គការសហប្រជាជាតិបានស្វែងរកការអះអាងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាថាអភ័យទោស ឬការលើកលែងទោសអៀង សារី នៅឆ្នាំ១៩៩៦ នឹងមិនអាចការពារ អៀង សារី ឲ្យរួចផុតពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញឡើយ ។ លិខិតនៅចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០០ របស់ឯកឧត្តម សុខ អាន ដែលបានផ្ញើទៅលោក កូរែល បានបញ្ជាក់យ៉ាងច្បាស់អំពីអត្ថន័យដាច់ដោយឡែកមួយស្តីពីការអភ័យទោសឬលើកលែងទោសនេះ ។ ទោះបីជាយ៉ាងណាក៏ដោយវិសាលភាពនៃការអភ័យទោស ដែលប្រភពដើមចេញពីថាតើបទឧក្រិដ្ឋកម្មអ្វីខ្លះដែលនឹងត្រូវស៊ើបអង្កេតនឹងត្រូវទុកឲ្យចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញជាអ្នកសម្រេចដូចដែលបានចងក្រងនៅក្នុងច្បាប់អង្គជំនុំជម្រះវិសាមញ្ញនិងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា ។ ដូច្នេះបញ្ហានៃការលើកលែងទោសដែលនឹងត្រូវប្រឈមមុខនឹងអង្គជំនុំជម្រះវិសាមញ្ញនិងជាបញ្ហាតូចចង្អៀតមួយចំពោះករណីបុគ្គលម្នាក់ឈ្មោះ អៀង សារី នេះតែ

ប៉ុណ្ណោះ ប្រសិនបើគាត់នឹងត្រូវចោទប្រកាន់មែននោះ ។

ការលើកលែងទោសគ្រប់ដណ្ដប់តែទៅលើការចោទប្រកាន់នៅក្រោមច្បាប់មួយតែប៉ុណ្ណោះ គឺច្បាប់ឆ្នាំ១៩៩៤ដែលដាក់ក្រុម «កម្ពុជាប្រជាធិបតេយ្យ»នៅក្រៅច្បាប់ ហើយច្បាប់នេះកាត់ទោសបទឧក្រិដ្ឋកម្មទាំងឡាយណាដែលនៅខាងក្រៅយុត្តាធិការកាលបរិច្ឆេទនិងយុត្តាធិការលើបទល្មើសរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ទាក់ទងទៅនឹង«ការអភ័យទោសចំពោះការកាត់ទោសប្រហារជីវិតនិងរឹបអូសទ្រព្យសម្បត្តិ» នៅក្នុងការអភ័យទោសឬលើកលែងទោស អៀង សារី នៅឆ្នាំ១៩៩៦ ភាសាច្បាស់លាស់ស្ដីពីបញ្ហានេះបានធ្វើសេចក្ដីសន្និដ្ឋានដ៏សមស្របមួយថា ការអភ័យទោសបានសម្រាលទោស អៀង សារី ចំពោះការកាត់ទោសប្រហារជីវិតនិងការរឹបអូសយកទ្រព្យសម្បត្តិ ប៉ុន្តែការអភ័យទោសនេះមិនបានការពារ អៀង សារី ឲ្យរួចផុតពីការដាក់ឲ្យទទួលខុសត្រូវនោះទេ ប្រសិនបើរកឃើញថាមានកំហុសលើបទឧក្រិដ្ឋកម្មណាមួយដោយអង្គជំនុំជម្រះវិសាមញ្ញ ។

ចំពោះគោលការណ៍មិនឲ្យមានការកាត់សេចក្ដីលើបទល្មើសមួយលើសពីម្ដងអាចនឹងរារាំងអង្គជំនុំជម្រះវិសាមញ្ញមិនឲ្យចោទប្រកាន់ អៀង សារី នោះ ការពិនិត្យយ៉ាងហ្មត់ចត់នឹងត្រូវបានបើកចំហ ។ គោលការណ៍មិនឲ្យមានការកាត់សេចក្ដីលើបទល្មើសមួយលើសពីម្ដងនឹងមិនត្រូវប្រានចោលការចោទប្រកាន់បន្តបន្ទាប់គ្នាបានទេ ដែលដំណើរការជំនុំជម្រះដំបូងប្រឆាំងនឹងចុងចោទខ្វះខាតភាពស្របច្បាប់ឬមានកំហុសច្រើនហួសហេតុពេករហូតដល់ចុងចោទមិនអាចចាត់ទុកថា ជាការកាត់សេចក្ដីថ្នាក់ជាតិស្របច្បាប់ ។

## សិទ្ធិទទួលបានដំណើរការកាត់សេចក្ដីសមស្រប

ការចូលរួមរបស់ប្រទេសកម្ពុជានៅក្នុងកតិការសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយបានបង្ហាញថា ការទទួលយករបស់ប្រទេសមួយ (ចាប់តាំងពីឆ្នាំ១៩៩២ ក្នុងនាមជាភាគីរដ្ឋនិងចាប់តាំងពីឆ្នាំ១៩៨០ដល់ឆ្នាំ១៩៩២ក្នុងឋានៈជាហត្ថលេខី) នៃកិច្ចព្រមព្រៀងអន្តរជាតិដែលជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចព្រមព្រៀងក្នុងតំបន់ទាំងអស់ ហើយក៏ធ្វើជាសេចក្ដីយោងជាញឹកញាប់ចំពោះរឿងក្ដីឧក្រិដ្ឋកម្មអន្តរជាតិពាក់ព័ន្ធនានា ។ ក្នុងនាមជាភាគីរដ្ឋចំពោះសាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិកម្ពុជាបានយល់ព្រមទទួលយកនូវកាតព្វកិច្ចផ្លូវច្បាប់ដែលវិធាននិតិវិធីនិងភ័ស្តុតាងនៃសាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិនិងបទដ្ឋានអន្តរជាតិស្ដីពីដំណើរការមានចែងនៅក្នុងនោះ លក្ខន្តិកៈក្រុងរ៉ូមនឹងត្រូវយកមកអនុវត្តនៅក្នុងករណីដែលជនជាតិកម្ពុជាណាម្នាក់នឹងត្រូវចោទប្រកាន់នៅចំពោះមុខសាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិ ។

ដូចដែលសាលាក្ដីរបស់ព្រះរាជាណាចក្រកម្ពុជាបានបង្កើតឡើងដែរ អង្គជំនុំជម្រះវិសាមញ្ញនឹងយកមកអនុវត្តវិធាននីតិវិធីព្រហ្មទណ្ឌដែលមានចែងនៅក្នុងច្បាប់កម្ពុជា ដែលនាំឲ្យអង្គជំនុំជម្រះវិសាមញ្ញទទួលយកវិធានទាំងអស់នោះដែរ ។

សាលាក្ដីកម្ពុជាត្រូវបានទាមទារនៅក្នុងច្បាប់និតិវិធីព្រហ្មទណ្ឌនិងឯកសាររបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យគោរពទៅតាមបទដ្ឋានដែលមានចែងនៅក្នុងកតិការសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយចំពោះការកាត់សេចក្ដីបទឧក្រិដ្ឋកម្មលើបុគ្គលណាម្នាក់ដោយមិនគិតថា បទឧក្រិដ្ឋកម្មនោះបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាឡើយ ។

ទោះបីជាច្បាប់អង្គជំនុំជម្រះវិសាមញ្ញនិងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាបាននិយាយសំដៅតែទៅលើមាត្រាទី១៤និង១៥នៃកតិការសញ្ញាអន្តរជាតិស្ដីពិសិទ្ធិពលរដ្ឋនិងនយោបាយក៏ដោយ ក៏ប្រទេសកម្ពុជាដែលជាភាគីផ្ដល់សច្ចាប័នដល់កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយតម្រូវឲ្យគោរពបទបញ្ញតិទាំងអស់របស់កតិកាសញ្ញានេះ ។

## ការដកចេញនូវកិច្ចសហប្រតិបត្តិការ

នៅក្នុងវិធីសាស្ត្រដាច់ដោយឡែកពីគ្នា ក្រុមអ្នកចរចាអាមេរិកនិងអង្គការសហប្រជាជាតិបានប្រឹងប្រែងយ៉ាងខ្លាំងជាមួយនឹងសមភាគីកម្ពុជាក្នុងការពង្រឹងនូវសុក្រិតភាពនៃអង្គជំនុំជម្រះវិសាមញ្ញនិងបង្កលទ្ធភាពឲ្យចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិព្រមទាំងអង្គការសហប្រជាជាតិឲ្យដកថយចេញពីដំណើរការនេះ ប្រសិនបើដំណើរការនេះមានភាពប្រឡាក់ប្រឡូកណាមួយដែលមិនអាចកែតម្រូវឬជម្នះបាន ។

នេះគឺជាអានុភាពដ៏មានឥទ្ធិពលសមស្របមួយចំពោះកិច្ចការនៃអង្គជំនុំជម្រះវិសាមញ្ញ និងបង្ហាញឲ្យឃើញថាការទទូចរបស់សហគមន៍អន្តរជាតិឲ្យសាលាក្ដីឈានទៅដល់បទដ្ឋានអន្តរជាតិនៃ

ដំណើរការសមស្របនិងគ្មានការទទួលឥទ្ធិពលពីអំពើពុករលួយ ។

គ្មានមធ្យោបាយណាផ្សេងមានអណត្តិដូចគ្នាទៅនឹងសាលាក្ដីយុត្តិធម៌អន្តរជាតិ ក្នុងគ្រាដែលមានជម្លោះរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនៅក្រោមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជានោះទេ ។ ការពិតទៅវិញនោះ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាបានទុករាល់ជម្លោះដែលកើតមានទាំងអស់ឲ្យទៅជាការបកស្រាយឬការអនុវត្តន៍សន្ធិសញ្ញានៅក្នុងការចរចាឬក៏រាល់ការដោះស្រាយបញ្ហាដែលបានព្រមព្រៀងគ្នាទៅវិញទៅមក ។

## សិទ្ធិជនរងគ្រោះ

អង្គជំនុំជម្រះវិសាមញ្ញមិនត្រូវបានចាត់ទុកដោយអ្នកដែលចរចាបង្កើតឡើងថា ជាឧបករណ៍សម្រាប់បន្ធូរអារម្មណ៍ជនរងគ្រោះផ្ទាល់នោះទេ ទោះបីជាមានការការពារនិងប្រើប្រាស់ជនរងគ្រោះធ្វើជាសាក្សីនៅក្នុងការស៊ើបអង្កេតនិងជំនុំជម្រះក្ដីដែលត្រូវបានពិភាក្សាយ៉ាងលម្អិត ។ ចំនួនជនរងគ្រោះមានច្រើនសន្ធឹកសន្ធាប់ពេក ហើយអណត្តិនិងធនធានរបស់អង្គជំនុំជម្រះវិសាមញ្ញមានកម្រិតពេករហូតដល់មិនអាចដោះស្រាយសេចក្ដីត្រូវការរបស់បុគ្គលម្នាក់ៗបាន រួមទាំងការផ្ដល់សំណងជំងឺចិត្តដល់ជនរងគ្រោះដ៏ច្រើនបែបនេះ ។

គ្មានបទបញ្ញត្តិណាមួយនៅក្នុងច្បាប់អង្គជំនុំជម្រះវិសាមញ្ញ ឬក៏នៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាដែលដោះស្រាយសិទ្ធិនិងសេចក្ដីត្រូវការរបស់ជនរងគ្រោះ ក្រៅតែពីមាត្រាទី៣៦(ដែលបានធ្វើវិសោធនកម្មរួចហើយ) នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញដែលបានផ្ដល់សិទ្ធិប្ដឹងឧទ្ធរណ៍ឲ្យជនរងគ្រោះ ។ នៅក្នុងចំណាប់អារម្មណ៍ដំបូងបង្អស់ ប្រការនេះហាក់ដូចជាមានលក្ខណៈចម្លែក ព្រោះគ្មានសេចក្ដីបញ្ជាក់ណាមួយដែលជនរងគ្រោះមានសិទ្ធិចូលរួមក្នុងដំណើរការជំនុំជម្រះក្ដីទេ ។ វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញមិនសូវបានសង្កត់ធ្ងន់ទៅលើបញ្ហាច្បាប់ក្នុងការចូលរួមពីជនរងគ្រោះនៅក្នុងដំណើរការកាត់សេចក្ដីរបស់អង្គជំនុំជម្រះនោះទេ ។

## សេចក្ដីសន្និដ្ឋាន

នៅក្នុងជំពូកនេះ ខ្ញុំបានស្វះស្វែងផ្ដល់នូវការពិនិត្យទាំងទៅលើប្រវត្តិនៃការចរចានិងក្របខ័ណ្ឌធម្មនុញ្ញភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ មិនមានសំណួរចោទសួរថា សាលាក្ដីដ៏ឧត្ដុង្គឧត្ដមសម្រាប់ការស៊ើបអង្កេតនិងចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកផ្ដើមគំនិតដទៃទៀតនៃអំពើឃោរឃៅក្នុងរយៈកាលនៃរបបប៉ុលពត ដោយមានការស្ថាបនាពីធម្មនុញ្ញដ៏ទំនើបដែលផ្ដល់អណត្តិដល់ការចូលរួមពីអន្តរជាតិនិងការគោរពទាំងស្រុងទៅតាមបទដ្ឋានអន្តរជាតិនៃដំណើរការសមស្រប នឹងមិនបានសម្រេចមួយណាទេ ។ ប៉ុន្តែប្រវត្តិនៃការចរចាបានលាតត្រដាងឲ្យឃើញថាតើបានសម្រេចប៉ុនណា បើទោះបីជាមានឧបសគ្គធំធេងក៏ដោយ ហើយបើទោះជាមានការប្រែក្រឡាស់ដោតវាសនាជាច្រើនក៏ដោយ ។ អង្គជំនុំជម្រះវិសាមញ្ញ ជាពិសេសដោយមានការយល់ស្របទៅវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងខែមិថុនា ឆ្នាំ២០០៧ គួរតែបំពេញបានតាមបទដ្ឋានអន្តរជាតិជាអប្បបរមានៃដំណើការសមស្រប ប្រសិនបើឥទ្ធិពលពុករលួយ ជាហេតុផលមួយនៅក្នុងប្រទេសកម្ពុជាត្រូវតែទប់ស្កាត់មិនឲ្យមានតាមរយៈការត្រួតពិនិត្យនិងតុល្យភាព ហើយអង្គការសហប្រជាជាតិគួរតែត្រួតពិនិត្យមើលទៅលើសមត្ថភាពនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញខ្លួនឯង ។

ចំពោះការវិវត្តន៍នៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ អង្គជំនុំជម្រះវិសាមញ្ញជាកិច្ចសហការដ៏សំខាន់នៃប្រព័ន្ធនយោបាយនិងផ្លូវច្បាប់ជាតិជាមួយអង្គការសហប្រជាជាតិដែលនឹងត្រូវអភិវឌ្ឍន៍រចនាសម្ព័ន្ធ នីតិវិធី និងច្បាប់ព្រហ្មទណ្ឌ ។

ប្រសិនប្រវត្តិសាស្ត្រនៃការចរចាស្ដីពីអង្គជំនុំជម្រះវិសាមញ្ញគឺជាមាគ៌ាមួយ ការបរាជ័យដែលត្រូវដាក់បន្ទុកប្រតិបត្តិការអង្គជំនុំជម្រះវិសាមញ្ញនឹងត្រូវដោះស្រាយដោយភាពអត់ធ្មត់និងស៊ិតស្វាញ និងដោយទិសដៅសម្រេចបានយុត្តិធម៌ប្រកបដោយជឿទុកចិត្តសម្រាប់ជនរងគ្រោះជាច្រើនលាននាក់ក្នុងអំឡុងរបបប៉ុលពត ។ នៅទីបញ្ចប់ នេះជាការអនុវត្តន៍នូវការដាក់ទោស ហើយនោះគឺជាអ្វីដែលជនដែលសំខាន់ៗមួយចំនួនដែលត្រូវរកឃើញថា មានកំហុសនៅក្នុងការកាត់សេចក្ដីដ៏សមស្របមួយស័ក្ដិសមនឹងទទួលយកការកាត់សេចក្ដីនេះដោយឈរលើភាពជាមនុស្សម្នាក់ ។

**ដេវីដ សេហ្វ័រ, មេយ័រ, ប្រ៊ោន, រ៉ូរ៉េ និងរ៉ូប៊ីត ហេលមិន**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**លេខ: ០៧-០៩-០០១ អ.វ.ត.ក/អ.ប.ជ**

# សេចក្តីជូនដំណឹង

អនុលោមតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ប្រធានអង្គបុរេជំនុំជម្រះ**

សូមជម្រាបជូន

អង្គការនានា និង សាធារណៈជនអោយបានជ្រាបថា៖

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៧ វេលាម៉ោង ១៦.៤០ រសៀល អង្គបុរេជំនុំជម្រះបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ០០២ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ ពីការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលជនត្រូវចោទឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ប្តឹងឧទ្ធរណ៍ពីដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ របស់សហចៅក្រមស៊ើបអង្កេត ។

សេចក្តីនេះចាត់ទុកជាការផ្តល់ឱកាសជូនអង្គការនានា និង សាធារណៈជនដើម្បីធ្វើសារណាជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធនឹងបញ្ហាណាមួយក្នុងករណីខាងលើមិនអោយលើស៣០ ទំព័រ ប្រសិនបើមាន ហើយបញ្ជូនមកការិយាល័យក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះក្នុងរយៈពេល៣០ ថ្ងៃ គិតពីថ្ងៃជូនដំណឹងនេះតទៅ។

ភ្នំពេញ , ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៧
**ប្រធានអង្គបុរេជំនុំជម្រះ**
ហត្ថលេខា និង ត្រា

**ប្រាក់ គឹមសាន**

# ស្វែងយល់អំពីសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះ

ការវិវត្តន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅកាត់ថា សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមបានឈានដល់ចំណុចដ៏គួរចាប់អារម្មណ៍ ។ ជនរងគ្រោះនៃរបបខ្មែរក្រហមគ្រប់រូបនិងសាធារណជនទាំងអស់កំពុងរង់ចាំថ្ងៃបើកសវនាការពិតប្រាកដមួយដែលខ្លួនអាចនឹងចូលរួមឃ្លាំមើលនិងតាមដានស្តាប់ ។ កាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៧ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះ (សូមអាននៅទំព័រ៣៩) ។

សេចក្តីជូនដំណឹងនេះត្រូវបានចាត់ទុកថា ជាការវិវត្តន៍ចុងក្រោយ បន្ទាប់ពីសហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូងកាលពីថ្ងៃទី១៨ ខែកក្កដា ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី៣១ ខែកក្កដា ប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតប្រធានគុកទួលស្លែង និងការតែងតាំងមេធាវីពីររូបដើម្បីការពារសិទ្ធិរបស់ចុងចោទ ឌុច ។ សូមរកអាននៅក្នុងទស្សនាវដ្តី «ស្វែងរកការពិត» លេខខែសីហា ឆ្នាំ២០០៧ ដែលមានសរសេរអំពីព្រឹត្តិការណ៍ទាំងបីខាងលើនេះ ។

ខ្ញុំសូមធ្វើការអធិប្បាយទៅបីចំណុចដែលទាក់ទិននឹងសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះ ទី១) ទាក់ទិននឹងអង្គបុរេជំនុំជម្រះ ទី២) ទាក់ទិននឹងការអនុញ្ញាតឲ្យអង្គការនានានិងសាធារណជនធ្វើសារណាជាលាយលក្ខណ៍អក្សរជូនអង្គបុរេជំនុំជម្រះនិងទី៣) ភាពខ្វះចន្លោះ ។

## ១) អង្គបុរេជំនុំជម្រះ

អង្គបុរេជំនុំជម្រះសំដៅដល់អង្គជំនុំជម្រះមួយក្នុងចំណោមអង្គជំនុំជម្រះនៃសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ អង្គបុរេជំនុំជម្រះមានតួនាទីដោះស្រាយការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា (មាត្រា២០ថ្មី) និងសហចៅក្រមស៊ើបអង្កេត (មាត្រា២៣ថ្មី) នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ និងមានសិទ្ធិអំណាចបន្ថែមផ្សេងទៀតដូចមានចែងក្នុងវិធាន៧៣នៃវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចជាពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ពិនិត្យពាក្យសុំមោឃៈភាពនៃកិច្ចស៊ើបសួរណាមួយនិងពិនិត្យលើបណ្តឹងឧទ្ធរណ៍ផ្សេងៗទៀត ។ ទាំងអស់នេះគឺសុទ្ធតែជាអង្គហេតុនិងអង្គច្បាប់ដែលអាចកើតឡើងមុនពេលឈានដល់ដំណាក់កាលនៃការបើកសវនាកាជាសាធារណៈដើម្បីវិនិច្ឆ័យសេចក្តីលើមេដឹកនាំខ្មែរក្រហមដោយអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដូច្នេះបានជាអង្គជំនុំជម្រះមួយនេះត្រូវបានដាក់ឈ្មោះថា «អង្គបុរេជំនុំជម្រះ» ។ យោងតាមវិធានផ្ទៃក្នុងសម្រាប់សាលាក្តីនេះ ការដោះស្រាយរបស់អង្គបុរេជំនុំជម្រះត្រូវធ្វើឡើងតាមរយៈការបើកសវនាការដោយសម្ងាត់ ។ អង្គបុរេជំនុំជម្រះមានចៅក្រមខ្មែរ៣រូបដែលចៅក្រមខ្មែរម្នាក់ជាប្រធាន (ចៅក្រម ប្រាក់ គឹមសាន) និងចៅក្រមបរទេស២រូប ។ រាល់ការសម្រេចលុះត្រាតែរកឲ្យបានយ៉ាងហោច៤សំឡេងទើបយកជាការបាន ។ កន្លងមកមានការបញ្ជាក់ពីសំណាក់អង្គជំនុំជម្រះវិសាមញ្ញតាមបណ្តាញសារព័ត៌មានថា ការវិនិច្ឆ័យសេចក្តីលើបណ្តឹងឧទ្ធរណ៍ពីដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដែលប្រឆាំងនឹង ឌុច នឹងធ្វើឡើងជាសាធារណៈដែលមានន័យថា សាធារណជនអាចចូលរួមស្តាប់សវនាការបាន ។

## ២) សារណាជាលាយលក្ខណ៍អក្សរ

សារណាជាលាយលក្ខណ៍អក្សរត្រូវបានប្រើនៅក្នុងសេចក្តីជូនដំណឹងដដែលនេះជាភាសាអង់គ្លេសថា “written amicus curiae briefs” ។ ទាក់ទិននឹងពាក្យឡាតាំងពីរម៉ាត់នេះគឺ amicus curiae អានថា អឹមីខឹស ខ្យូរីអ៊ី មានន័យថា មិត្តភក្តិរបស់តុលាការ ។ នៅក្នុងវចនានុក្រមច្បាប់ (Black's Law Dictionary) បោះពុម្ពលើកទី៧ បានពន្យល់ពាក្យពីរម៉ាត់នេះថា «ជាបុគ្គលម្នាក់ដែលមិនមែនជាភាគីនៅក្នុងបណ្តឹង ក៏ប៉ុន្តែអាចដាក់ញត្តិទៅតុលាការបានបុ

ដោយតុលាការស្នើសុំឲ្យដាក់សារណាពាក់ព័ន្ធនឹងបណ្ដឹងដោយសារតែបុគ្គលនោះមានចំណាប់អារម្មណ៍ខ្លាំងលើរឿងក្ដីនោះ» ។

ក្នុងចំណាត់ការរឿងក្ដីកន្លងមក តុលាការក្នុងស្រុកហាក់ដូចជាពុំមានការអនុញ្ញាត ឬការស្នើសុំអ្វីបែបនេះឡើយ ។ អាចនិយាយបានម្យ៉ាងទៀតថា ការធ្វើបែបនេះពុំមាននៅក្នុងប្រព័ន្ធច្បាប់កម្ពុជាក៏អាចថាបាន ។ ចំណែកឯប្រព័ន្ធច្បាប់ ខមិនឡ វិញ ចៅក្រមស្នើសុំឲ្យដាក់ជាសារណាឬអាចកោះហៅជាបុគ្គលឲ្យមកជួយបំភ្លឺនៅក្នុងបន្ទប់សវនាការលើបញ្ហាអ្វីមួយដែលមានលក្ខណៈស្មុគស្មាញ លំបាកដើម្បីធ្វើការវិនិច្ឆ័យទោសឲ្យមានភាពត្រឹមត្រូវ ។ នៅតុលាការអន្តរជាតិផ្សេងៗទៀតដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា ព្រមទាំងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន សុទ្ធតែធ្លាប់បានទទួលយកសារណាបែបនេះទាំងអស់ ។

ដោយឡែកសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធាន៣៣នៃវិធានផ្ទៃក្នុងបាននិយាយយោងដល់ «សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី» ។ វិធាន៣៣នេះចែងសំដៅដល់ពាក្យ អីមីខឹស ខ្យូរីអ៊ី នេះ ។ ប្រធានអង្គបុរេជំនុំជម្រះបានទុករយៈពេលឲ្យអង្គការនានាឬសាធារណជនក្នុងអំឡុងពេល ៣០ថ្ងៃ ដោយគិតរាប់ពីថ្ងៃជូនដំណឹងដែលធ្វើឡើងនៅថ្ងៃទី៤ ខែកញ្ញានេះ ។ ដូច្នេះថ្ងៃកំណត់ក្នុងការបញ្ជូនសារណាទៅឲ្យអង្គបុរេជំនុំជម្រះគឺផុតកំណត់នៅថ្ងៃទី៤ ខែតុលាខាងមុខនេះ ។ បន្ទាប់ពីថ្ងៃផុតកំណត់ អង្គបុរេជំនុំជម្រះនឹងកំណត់ថ្ងៃសម្រាប់បើកសវនាការវិនិច្ឆ័យសេចក្ដីលើបណ្ដឹងឧទ្ធរណ៍ពីដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នប្រឆាំងនឹង ឌុច ។ ការបើកសវនាការទំនងជានឹងធ្វើឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ យ៉ាងលឿនបំផុត ។

## ៣) ភាពខ្វះចន្លោះ

ភាពខ្វះចន្លោះមួយដែលសំខាន់ទាក់ទិននឹងសេចក្ដីជូនដំណឹងនេះគឺថារហូតមកទល់ពេលនេះអង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញមិនទាន់ត្រូវបានដំណើរការនៅឡើយ ។ វាអាចជាការបាត់បង់ឱកាសចូលរួមយ៉ាងសំខាន់របស់ជនរងគ្រោះ ជាពិសេសជនរងគ្រោះផ្ទាល់ដោយសារឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងការទទួលខុសត្រូវរបស់ ឌុច តែម្ដង ពីព្រោះថា អង្គភាពជនរងគ្រោះមានភារៈជួយជនរងគ្រោះក្នុងការដាក់ពាក្យបណ្ដឹង ផ្ដល់ដល់ជនរងគ្រោះនៅពេលមានសំណើសុំណាមួយឬព័ត៌មានចាំបាច់ដើម្បីជួយសម្រួលឲ្យមានប្រសិទ្ធភាពដល់ការចូលរួមជួយសម្របសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះ ព្រមទាំងជួយដល់ផ្នែកកិច្ចការសាធារណៈក្នុងសកម្មភាពផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងជនរងគ្រោះជាដើម (វិធាន១២) ។

សូមបញ្ជាក់ថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបង្កើតឡើងដើម្បីផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហមរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ប្រសិនបើមានការអូសបន្លាយប្រតិបត្តិការរបស់អង្គភាពជនរងគ្រោះតទៅទៀតជនរងគ្រោះនឹងបាត់បង់ឱកាសសំខាន់ៗបែបនេះច្រើនតទៀតដែរ ហើយការងាររបស់អង្គជំនុំជម្រះវិសាមញ្ញដែលប្រឹងប្រែងធ្វើកន្លងមកនិងបន្តធ្វើតទៅទៀតនឹងត្រូវទទួលរងនូវការរិះគន់ថាផ្ទុយនឹងគោលបំណងដ៏ចម្បងរបស់ខ្លួន ។ **ម៉ាន់ថាន់ ពៅដារ៉ា**

## ស្ដាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្ដីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុFM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជារៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ល្ងាច ។
- វិទ្យុFM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្ដល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា និង តាត លក្ខិណា**

# ការបង្កើតឱ្យមានការចងចាំៈ "ក្រដាសប្រាក់ដែលរំឭកពីការចងចាំ" នៅក្នុងរង្វង់ដៃរបស់ប្រជាជនកម្ពុជា

ប្រជាជនកម្ពុជាទាំងអស់គួរតែមានឱកាសចូលរួមជាលក្ខណៈសហគមន៍ក្នុងការចងចាំនូវអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តដោយខ្មែរក្រហម ហើយនេះគឺជាការប្រឆាំងដោយផ្ទាល់ទៅនឹងគោលនយោបាយរបស់របបដែលព្យាយាមបំបែកទំនាក់ទំនងសង្គម ។ ការរំឭក ឬ (ក្នុងន័យទូលាយជាងនេះ) ការចងចាំផ្តល់ដល់ការទទួលស្គាល់ជាសាធារណៈថា ជាទម្រង់នៃការមើលរំលងក្នុងការសម្រេចបាននូវសំណងនិងការមិនទទួលស្គាល់ ។ យុត្តិធម៌តាមរបៀបសំណងខុសគ្នានឹងយុត្តិធម៌តាមរបៀបដាក់ទោសដែលអាចមើលឃើញតាមរយៈតុលាការ ។ យុត្តិធម៌តាមរបៀបសំណង ផ្តោតទៅលើការលើកកម្ពស់ស្ថានភាពរបស់ជនរងគ្រោះ ហើយយុត្តិធម៌របៀបដាក់ទោសគឺផ្តោតលើការដាក់ទណ្ឌកម្មទៅលើជនដៃដល់ ។ នៅពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(សាលាក្តីខ្មែរក្រហម) ត្រូវបានបង្កើតឡើងដើម្បីកាត់សេចក្តីជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើប្រល័យពូជសាសន៍ ការស្វែងរកយុត្តិធម៌ដែលលេចរូបរាងឡើងលើសពីការជំនុំជម្រះទោសវាមានសារសំខាន់ណាស់ ព្រោះថាប្រជាជនកម្ពុជាភាគច្រើនមិនបានដឹងច្រើនពីសាលាក្តីនេះទេ ។ ទោះបីអ្នកទាំងនោះត្រូវបានផ្តល់ការអប់រំចំពោះបញ្ហានេះដោយអង្គការក្រៅរដ្ឋាភិបាលជាច្រើនក៏ដោយ ក៏ចាំបាច់តម្រូវឲ្យមានការទទួលស្គាល់នូវអំពើសាហាវយោរយៅនេះ និងតម្រូវឲ្យមានការព្យាយាមរបស់រដ្ឋាភិបាលក្នុងការស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះដែរ ។




អង្គការសហប្រជាជាតិនិងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាទទួលស្គាល់ថា គ្រប់ជនរងគ្រោះនៃអំពើដ៏សាហាវយោរយៅដូចក្នុងករណីប្រជាជនកម្ពុជាមានសិទ្ធិទទួលបាននូវសំណង ។ យោងតាមគោលការណ៍គ្រឹះនិងសេចក្តីណែនាំលើប្រធានបទរបស់អង្គការសហប្រជាជាតិ សំណងត្រូវបានចែកចេញជា៥ទម្រង់គឺផ្តល់ឲ្យនូវអ្វីដែលបានបាត់បង់ទៅ សំណងជំងឺចិត្តការរស់នៅដោយគ្មានការភិតភ័យ ការបំពេញតាមតម្រូវការនិងការធានាថានឹងគ្មានអំពើបែបនេះកើតមានម្តងទៀត ។ ទោះបីជាឯកសាររបស់អង្គការសហប្រជាជាតិមួយនេះតម្រូវថា ជនរងគ្រោះគួរតែទទួលបាននូវសំណងដោយពេញបរិបូរណ៍ដើម្បីឲ្យសមាមាត្រទៅនឹងការរំលោភបំពានក៏វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់សំណងនេះឲ្យមានទម្រង់បែបសីលធម៌និងសហគមន៍ ។ ការកំណត់បែបនេះឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីឧបសគ្គដែលអង្គជំនុំជម្រះមានគឺពេលវេលាខ្លីពេក ថវិកាតិចពេក និងជនរងគ្រោះច្រើនពេក ។ សំណងជំងឺចិត្តដែលមានលក្ខណៈជាបុគ្គល គឺមិនងាយស្រួលសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហមឡើយ ។ ដូច្នេះទម្រង់ដែលត្រូវបានបង្កើតឡើងជាសំណងដល់ជនរងគ្រោះគួរតែត្រូវបានពិចារណា ។ សំណងដែលមានលក្ខណៈ

ថ្លៃប្រឌិតគួរតែលើកយកមកពិចារណាថា វាគួរតែអាចប្រព្រឹត្តទៅបាននិងមានអត្ថន័យសម្រាប់ជនរងគ្រោះ ។

សម្រាប់ទម្រង់នៃការរំឭកទាំងឡាយដែលបង្កើតនូវសំណងដែលមានតម្លៃសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម ចាំបាច់ណាស់ត្រូវតែមានអត្ថប្រយោជន៍ខ្ពស់សម្រាប់ជនរងគ្រោះ ហើយជនរងគ្រោះទាំងនោះត្រូវតែចូលរួមក្នុងកិច្ចការនេះដែរ ។ ដូច្នេះបូជនីយដ្ឋានជាទម្រង់ដែលទទួលបានគុណប្រយោជន៍ពីជនរងគ្រោះភាគច្រើនដែលអាចចូលរួមក្នុងកិច្ចការនេះ ។ ក្នុងន័យនេះ ខ្ញុំសូមស្នើជាយោបល់មួយស្តីពីបូជនីយដ្ឋានដែលបង្កប់ន័យសំណង គឺការដាក់បញ្ចូលរូបភាពដែលបញ្ជាក់ពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយដែលអាចឆ្លុះបញ្ចាំងពីការចងចាំចំពោះរបបនេះទៅក្នុងក្រដាសប្រាក់រៀល ។ ជាទូទៅ ក្រដាសប្រាក់រៀលមានរូបភាពបញ្ជាក់ពីវប្បធម៌កម្ពុជានៅមួយចំហៀង និងមួយចំហៀងទៀតបញ្ជាក់ពីសកម្មភាពសេដ្ឋកិច្ច ។ របបខ្មែរក្រហមបានអនុវត្តនូវគោលការណ៍ដែលផ្ទុយស្រឡះនឹងគំនិតនេះ ក្នុងគោលបំណងបំផ្លាញរចនាសម្ព័ន្ធវប្បធម៌និងសេដ្ឋកិច្ចកម្ពុជា ។ ប៉ុន្តែតាមរយៈនៃការបង្កើតរូបភាពនៅលើក្រដាសប្រាក់ដែលបង្កប់ន័យការចងចាំអំពីប្រវត្តិសាស្ត្រ វប្បធម៌ និងសេដ្ឋកិច្ចកម្ពុជាគឺទទួលបាននូវតម្លៃយ៉ាងធំធេងនៅក្នុងសង្គមបច្ចុប្បន្ន ។ តុលាការខ្មែរក្រហមខ្លួនឯងជាតំណាងឲ្យការទទួលខុសត្រូវ ហើយយុត្តិធម៌និងនីតិរដ្ឋគឺជាគន្លឹះដ៏សំខាន់ក្នុងការពង្រឹងសមត្ថភាពក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យស្របតាមបទដ្ឋានពាណិជ្ជកម្មអន្តរជាតិ ។

ដោយសារសំណងជនរងគ្រោះសំដៅលើការផ្តល់សំណងជាជំងឺចិត្ត ហើយក្នុងន័យដែលសំណងជំងឺចិត្តមិនអាចធ្វើទៅបានជាអត្តសញ្ញាណ ការដាក់រូបភាពបញ្ជាក់ពីការចងចាំនៅលើក្រដាសប្រាក់អាចឆ្លុះបញ្ចាំងពីឆន្ទៈក្នុងការ«សង»ត្រឡប់មកជនរងគ្រោះវិញ ។ ក្រដាសប្រាក់នោះគួរតែបំពេញនូវការកំណត់ផ្សេងៗសម្រាប់សំណងជនរងគ្រោះនិងសម្រេចបាននូវគោលដៅសំណងសម្រាប់ជនរងគ្រោះក្នុងពេលជាមួយគ្នា ។ គំនិតសំខាន់ក្នុងការដាក់បញ្ចូល «បូជនីយដ្ឋាន» ទៅក្នុងក្រដាសប្រាក់រួមមានៈ ១) ការចំណាយថវិកាតិចក្នុងការបោះពុម្ពក្រដាសប្រាក់ថ្មី ២) ក្រដាសប្រាក់មានរូបរាងបង្កប់នូវធម្មជាតិប្រមូលផ្តុំដែលអាចឲ្យប្រជាជនប្រើប្រាស់បានជាលក្ខណៈបុគ្គលដោយមិនមានការរើសអើង និង ៣) សញ្ញាបញ្ជាក់ពីតម្លៃសីលធម៌ដែលបង្ហាញយ៉ាងមុតមាំថារបបខ្មែរក្រហមមិនស្ថិតនៅលើគោលការណ៍យុត្តិធម៌និងច្បាប់ឡើយ ។ ការគាំទ្ររបស់រដ្ឋាភិបាលក្នុងការបង្កើតសំណងបែបនេះនឹងបង្កើតការទទួលស្គាល់តាមរយៈរដ្ឋាភិបាលចំពោះកំហុសដែលដឹកនាំដោយរបបខ្មែរក្រហមនៅក្នុងន័យថានេះជាមធ្យោបាយនាំយកយុត្តិធម៌តាមរូបភាពមួយសម្រាប់ជនរងគ្រោះ ។

ការបង្កើតក្រដាសប្រាក់ដែលបង្កប់នូវការរំឭកចំពោះជនរងគ្រោះ ជាវិធីសាស្ត្រមួយដែលរដ្ឋអាចបង្កើតនូវការទទួលស្គាល់ជាផ្លូវការចំពោះកំហុសឆ្គងរបស់របបខ្មែរក្រហមនិងការគាំទ្រជាលក្ខណៈជាតិសម្រាប់សំណងទៅជនរងគ្រោះ ។ នេះគឺស៊ីគ្នានឹងការរំពឹងទុកតាមគំនិតអន្តរជាតិ ព្រោះថា កម្ពុជាជាសមាជិករបស់អង្គការសហប្រជាជាតិ ហើយគោលការណ៍គ្រឹះនិងសេចក្តីណែនាំលើប្រធានបទដែលសង្ឃឹមថា រដ្ឋដែលជាសមាជិកនឹងសហការជួយផ្នែកសំណងជនរងគ្រោះនៅពេលដែលរដ្ឋជាសមាជិកមួយមិនមានលទ្ធភាពគ្រប់គ្រាន់ឬមិនមានឆន្ទៈផ្តល់សំណងនេះ ។ ដូច្នេះ ទោះបីជារដ្ឋាភិបាលបច្ចុប្បន្នមិនបានផ្តោតការយកចិត្តទុកដាក់ទៅលើរបបមុនក៏ដោយ ក៏នេះជាការទទួលខុសត្រូវមួយក្នុងការធានាថានឹងមានសំណងជនរងគ្រោះដ៏សមរម្យមួយ ។ នេះមានន័យថា ក្នុងករណីមិនមានមូលនិធិដែលប្រមូលបានពីជនដៃដល់តាមរយៈតុលាការគ្រប់គ្រាន់សម្រាប់សំណងនេះក៏ដោយ ក៏មានការរំពឹងទុកជាមុនចំពោះរដ្ឋាភិបាលថា ត្រូវតែធ្វើ ឬក៏បញ្ចេញសកម្មភាពអ្វីមួយចេញជាសំណងនេះឡើង ។ ឧទាហរណ៍ថា ក្រដាសប្រាក់ថ្មីត្រូវបានបោះពុម្ពក្នុងរូបភាពធម្មតា ក្រដាសប្រាក់ដែលបង្កប់នូវការរំឭកចំពោះជនរងគ្រោះនឹងក្លាយជាទម្រង់នៃបូជនីយ-ដ្ឋាន(ការចងចាំ) ដែលរដ្ឋាភិបាលមិនចាំបាច់ចំណាយប្រាក់ច្រើនពេកដើម្បីគាំទ្រ ហើយទង្វើនេះអាចបង្កើតនូវមាគ៌ាគតិយុត្តិសម្រាប់រដ្ឋាភិបាលក្នុងការឈានទៅរកបទដ្ឋានអន្តរជាតិនៃសិទ្ធិមនុស្ស ។

ការប្រើប្រាស់ក្រដាសប្រាក់ដើម្បីបញ្ជាក់ពីអត្ថន័យនៃសំណងនេះធានាបង្ហាញថា និមិត្តរូបនៃការចងចាំគឺត្រូវបានផ្សារភ្ជាប់ទៅនឹងវត្ថុបំណងរបស់មនុស្ស ហើយវត្ថុបំណងនេះគ្មានអ្វីដែលមិនសំខាន់ជាងតម្លៃនៃនិមិត្តរូបដែលមិនអាចបំបែកបាន

ឡើយ ។ ក្រដាសប្រាក់បម្រើដល់គោលបំណងសេដ្ឋកិច្ចដ៏មានប្រយោជន៍មួយ ហើយក៏សម្រាប់ការចាយវាយរបស់ប្រជាជនកម្ពុជាគ្រប់រូបនាពេលបច្ចុប្បន្ននេះដែរ ។ ក្រដាសប្រាក់រៀលគឺជាតម្រូវការសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ។ ដូច្នេះ វាមិនទំនងជាត្រូវប្រឈមមុខចំពោះបញ្ហាមិនស្មើភាពគ្នានៃបូជនីយដ្ឋានដែលកើតមាននាពេលថ្មីៗនេះដែលកំពុងតែមានប្រជាប្រិយភាពចំពោះភ្ញៀវទេសចរណ៍អន្តរជាតិជាងប្រជាជនក្នុងស្រុក ។ ការជ្រើសរើសយកទម្រង់បូជនីយដ្ឋានមួយដែលមានតម្លៃបំផុតសម្រាប់ប្រជាជនកម្ពុជាទូទៅមានន័យថា បូជនីយដ្ឋាននេះអាចត្រូវបានទទួលយកដោយប្រជាជនកម្ពុជាដែលជាអ្នកទទួចចង់បាននូវការរំឭកឡើងវិញអំពីអ្វីដែលខ្លួនត្រូវចងចាំនិងអ្វីដែលជាការផ្សះផ្សា ដែលកត្តានេះសំខាន់ណាស់សម្រាប់ការឈានទៅដល់ភាពយុត្តិធម៌ ។ ក្រដាសប្រាក់ដែលមានរូបបូជនីយដ្ឋានមួយសន្និកនឹងបញ្ជាក់ពីអត្ត-សញ្ញាណជនរងគ្រោះថាជាការប្រមូលផ្តុំ ឬមិនអាចបញ្ជាក់បានពីឧទា-ហរណ៍តែម្យ៉ាង ស្តីពីការឈឺចាប់ចំៗបានទេ ។ ក៏ប៉ុន្តែបូជនីយដ្ឋានដែលប្រមូលផ្តុំមិនអាចបំពេញតាមភាពខុសគ្នារបស់បុគ្គលម្នាក់ៗបានឡើយ ។ បូជនីយដ្ឋានដែលប្រមូលផ្តុំទាំងនោះអាចមានលទ្ធភាពនាំយកផលចំណេញដល់សហ-គមន៍ តាមរយៈការចែករំលែកទំនាក់ទំនងនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រដាសប្រាក់នេះមានលក្ខណៈពិសេសត្រង់ថា ផ្តល់នូវការចាប់អារម្មណ៍ជាបុគ្គល ជាក់ស្តែងដូចជាប្រជាជនកម្ពុជាអាចនឹងបានកាន់ក្រដាសប្រាក់នេះនិងចូលរួមថែរក្សានូវចំណែកតូចមួយនៃកិច្ចខំប្រឹងប្រែងជាផ្លូវការនេះសម្រាប់ភាពយុត្តិធម៌ ។ ដូច្នេះហើយការចងចាំនឹងលេចរូបរាងឡើងនៅក្នុងកណ្តាប់ដៃរបស់ជនរងគ្រោះនិងប្រជាជនកម្ពុជាគ្រប់ៗរូប ហើយនឹងត្រូវបានចែករំលែកបន្តពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។

ជាទីបញ្ចប់ ការផ្សព្វផ្សាយនិមិត្តសញ្ញាដែលផ្សារភ្ជាប់នឹងខ្លឹមសារថា ជនដែលជាប់ក្នុងអំពើឃោរឃៅនិងមិនត្រឹមត្រូវនឹងមានឥទ្ធិពលក្នុងការពង្រីកនិងផ្សព្វផ្សាយនូវសេចក្តីសម្រេចដែលនឹងត្រូវសម្រេចនៅក្នុងតុលាការ(ខ្មែរក្រហម) ។ នៅក្នុងអត្ថន័យនេះ វាអាចនឹងមានប្រយោជន៍ក្នុងការរចនាក្រដាសប្រាក់ដែលអាចឆ្លុះបញ្ចាំងពីលទ្ធផលរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីបញ្ជាក់ថា ការព្យាយាមជាដំបូងសម្រាប់អនាគតក្នុងនាមនៃការចងចាំអតីតកាល ។ ការសន្យាមួយដើម្បីឆ្ពោះទៅរកបទដ្ឋានអន្តរជាតិនៃភាពយុត្តិធម៌ សិទ្ធិមនុស្សនិងនីតិរដ្ឋនឹងត្រូវបានលេចជារូបរាងឡើងតាមរយៈ«ក្រដាសប្រាក់ដែលរំឭកពីការចងចាំ»នេះ ។ **ណាតាលី សេន**



បូជនីយដ្ឋានវាលពិឃាតជើងឯក

# ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់៖ កំណែទម្រង់គតិយុត្តិផ្នែកព្រហ្មទណ្ឌជាតិ និងការផ្តល់អំណាចក្នុងតំបន់

**(តពីលេខមុន)**

**១) សក្តានុពលរបស់តុលាការកូនកាត់ក្នុងការច្របាច់បញ្ចូល និងការជះឥទ្ធិពលដល់វប្បធម៌ក្នុងស្រុក**

១) ការជំរុញភាពជាម្ចាស់ និង ការកសាងទំនុកចិត្តរបស់ប្រព័ន្ធច្បាប់ក្នុងស្រុកឡើងវិញ

គេអាចយល់បានយ៉ាងងាយស្រួលចំពោះការចូលរួមរបស់ប្រជាជនក្នុងស្រុកនៅក្នុងដំណើរការរបស់តុលាការឧក្រិដ្ឋកម្មនៅក្រោយជម្លោះ នៅពេលដែលប្រជាជនមានអារម្មណ៍យល់ច្បាស់ និងមានភាពជាម្ចាស់ ។ ការសិក្សាបង្ហាញថា អ្នកសង្កេតការណ៍នៃដំណើរការតុលាការផ្តល់តម្លៃខ្ពស់ចំពោះគំនិតដែលថាសមាជិកសហគមន៍ទទួលបានការប្រព្រឹត្តចំពោះពួកគាត់ដោយយុត្តិធម៌ពីសំណាក់នរណាម្នាក់ដែលយល់ច្បាស់ពីអំណះអំណាងរបស់ពួកគាត់ ។ ការណ៍នេះពន្យល់ប្រាប់យើងខ្លះៗ «ថាហេតុអ្វីបានជាដំណើរការកាត់ទោសខ្លះ រួមទាំងទម្រង់នានានៃស្ថាប័នមជ្ឈត្តកម្ម (អាជ្ញាកណ្តាល) និងតុលាការយុត្តិធម៌អន្តរជាតិផងនោះ ផ្តល់នូវយន្តការសម្រាប់ឲ្យភាគីនៃជម្លោះតែងតាំងមជ្ឈត្តករ(មេធាវី) និងចៅក្រម» ។ វត្តមានចៅក្រមក្នុងស្រុកអាចជួយកែតម្រូវទស្សនៈក្នុងស្រុកអំពីតុលាការឧក្រិដ្ឋកម្មសង្គ្រាម និងភាពស្របច្បាប់របស់ចៅក្រមទាំងនេះ នៅពេលក្រោយមកទៀត ។ ដូច្នេះតុលាការកូនកាត់ដែលប្រើបុគ្គលិកក្នុងស្រុកមានសក្តានុពល ពិសេសសម្រាប់ធ្វើឲ្យមានភាពស្របច្បាប់ តាមរយៈការប្រមូលផ្តុំការគាំទ្ររបស់ប្រជាជន ។

សម្រាប់ប្រទេសជាច្រើនក្នុងដំណាក់កាលក្រោយជម្លោះ ការដែលយល់ឃើញថា ប្រព័ន្ធយុត្តិធម៌ក្នុងស្រុកយ៉ាងហោចណាស់ក៏អាចចូលរួមបានខ្លះនៅក្នុងការកាត់ទោសអាចជាកត្តាសំខាន់សម្រាប់ការធ្វើឲ្យមានជំនឿចំពោះតុលាការឡើងវិញ ។ លើសពីនេះ ការស្តារភាពស្របច្បាប់នៃប្រព័ន្ធច្បាប់ដែលវិនាសហិនហោច និងចំណងទាក់ទងក្នុងស្រុកជាមួយនឹងការកាត់ក្តីធំៗដែលមានដំណើរការល្អអាចនាំមកនូវជំនឿទុកចិត្តចំពោះរដ្ឋាភិបាលអន្តរកាល ។ នេះជារឿងសំខាន់ ព្រោះថារៀងរាល់ថ្ងៃប្រជាជនជាច្រើនពឹងផ្អែកលើការការពារ និងស្តេរភាពរបស់ច្បាប់ និងស្ថាប័នក្នុងប្រទេសរបស់ខ្លួនច្រើនជាងទៅលើច្បាប់អន្តរជាតិ ឬអង្គការសហប្រជាជាតិ ។ តុលាការកូនកាត់បង្ហាញឲ្យប្រជាជនក្នុងស្រុកឃើញថា តុលាការក្នុងស្រុកក៏អាចផ្តល់យុត្តិធម៌បានដែរ ។ ផ្ទុយមកវិញ ការមិនអើពើចំពោះស្ថាប័ននិងតួអង្គក្នុងស្រុកធ្វើឲ្យពួកគេបាត់បង់អំណាចនិងបង្ហាញពីការមិនជឿជាក់លើសមត្ថភាពរបស់ខ្លួន ។

២) ភាពងាយស្រួលផ្នែកវប្បធម៌ ទីតាំង និង ភាសា

សម្រាប់ហេតុផលវប្បធម៌ ចៅក្រមស៊ើបអង្កេត អ្នកដោះស្រាយជម្លោះ ចៅក្រម មន្ត្រីរដ្ឋបាល និងមន្ត្រីទំនាក់ទំនងសាធារណៈក្នុងប្រទេសមានភាពងាយស្រួលច្រើនក្នុងការស្វែងយល់អំពីវប្បធម៌ក្នុងស្រុក បកស្រាយការរិះគន់របស់ប្រជាជនក្នុងស្រុក និងធ្វើការឆ្លើយតបបានប្រសើរជាងសហការីជាជនជាតិបរទេស ។

ឧទាហរណ៍ ពេលដែលបុគ្គលិកបរទេសនៅប្រទេសសេរ៉ា-ឡេអូន កម្ពុជា ប៊ូស្នៀ ឬប្រទេសណាមួយផ្សេងទៀត មិនអាចរកឃើញចំណុចគួរឲ្យសង្ស័យឬមិនអាចយល់អំពីសេចក្តីថ្លែងការណ៍ ឬអាកប្បកិរិយាណាមួយថាមានលក្ខណៈវាយប្រហារឬបំភ័ន្តនោះ ពេលនោះបុគ្គលិក្នុងស្រុកអាចយល់ និង ធ្វើការឆ្លើយតបបាន ។

បុគ្គលិកតុលាការអន្តរជាតិដែលបំពេញការងារនៅឆ្ងាយទាំងផ្នែកអារម្មណ៍ និងវប្បធម៌ ពីទីតាំងដែលអំពើប្រល័យពូជសាសន៍ ឬអំពើឃោរឃៅបានកើតឡើង មានភាពងាយស្រួលក្នុងការបង្កើត «យុទ្ធសាស្ត្រសំខាន់ៗ» អាចជួយប្រជាជនក្នុងស្រុកបានច្រើន ។ បុគ្គលិកក្នុងស្រុកទំនងជាទទួលរងគ្រោះខាងផ្លូវចិត្តឬរងការប៉ះទង្គិចតាមរយៈមិត្តភក្តិនិងក្រុមគ្រួសារក្នុងពេលកំពុងធ្វើការកាត់

ទោសអំពើព្រៃផ្សៃនៅតុលាការកូនកាត់ ហើយក៏ងាយនឹងទទួលអារម្មណ៍គានតឹងមួយដែលថាខ្លួនត្រូវធ្វើអ្វីមួយដើម្បីជនរងគ្រោះនៃអំពើនោះ ។

នៅក្នុងតុលាការកូនកាត់ តាមរយៈអន្តរកម្មជាមួយគ្នា «បុគ្គលិកអន្តរជាតិមានឱកាសស្វែងយល់ពីបញ្ហាក្នុងស្រុក វប្បធម៌ក្នុងស្រុក និងការផ្តល់យុត្តិធម៌នៅក្នុងស្រុក ស្របពេលជាមួយគ្នាដែលបុគ្គលិកក្នុងស្រុកអាចរៀនសូត្រពីបុគ្គលិកអន្តរជាតិ ។ ផ្ទុយគ្នាទៅនឹងរូបភាពវិជ្ជមានទាំងនេះ ការពិនិត្យត្រួសៗទៅលើការបរាជ័យក្នុងការប្រាស្រ័យទាក់ទងគ្នានៅក្នុងតុលាការកូនកាត់មួយចំនួនដែលកំពុងប្រព្រឹត្តទៅ បញ្ជាក់យ៉ាងច្បាស់ថា តុលាការកូនកាត់មិនមែនជាដំណោះស្រាយស័ក្តិសិទ្ធិបំផុតនោះទេ ។ ការគ្រប់គ្រងមិនល្អអាចកាត់បន្ថយសក្តានុពលនៃតុលាការកូនកាត់ក្នុងការសម្របសម្រួលកែលម្អ ការយល់ដឹងពីវប្បធម៌ និងការផ្សព្វផ្សាយវប្បធម៌ ។ បច្ចុប្បន្ន នៅកូសូវ៉ូនិងទីម័រខាងកើត បញ្ហានយោបាយ កង្វះឆន្ទៈ និងបញ្ហាវិជ្ជាជីវៈ និងសម្ភារ (ដូចជាកង្វះអ្នកយកព័ត៌មាននៅតុលាការ អ្នកបកប្រែ អ្នកកត់ត្រា អ្នកបច្ចេកទេសវេបសាយ និងមន្ត្រីទំនាក់ទំនងសាធារណៈជាដើម) បានធ្វើឲ្យរាំងស្ទះទំនាក់ទំនងរវាងតុលាការជាមួយប្រជាជនក្នុងស្រុក ។ ការគ្រប់គ្រងចាត់ចែងល្អនៅតែជាកត្តាសំខាន់មិនអាចខ្វះបានសម្រាប់រាល់ស្ថាប័នផ្តល់យុត្តិធម៌ទាំងអស់ ។

ប្រសិនបើការទទួលបានការយល់ដឹងផ្នែកវប្បធម៌គឺជាគន្លឹះនោះ ការខិតចូលជិតផ្នែកទីតាំងក៏មានសារសំខាន់ណាស់ដែរ ។ បើទោះបីជាប្រទេសមួយមិនអាចកាត់សេចក្តីដោយខ្លួនឯង ឬមិនចូលរួមក្នុងដំណើរការកាត់ក្តីក៏ដោយ យ៉ាងហោចណាស់គេគួរតែព្យាយាមពិគ្រោះយោបល់ជាមួយប្រជាជននៃប្រទេសនោះ និងបន្តផ្តល់ព័ត៌មានដល់ប្រជាជនជាប្រចាំអំពីអ្វីដែលក្រុមការងារអន្តរ-ជាតិឬតុលាការអចិន្ត្រៃយ៍កំពុងធ្វើ ។

ការរស់នៅឆ្ងាយពីកន្លែងកាត់ទោស គឺជារបាំងមួយយ៉ាងខ្ពស់សម្រាប់ជនរងគ្រោះក្រីក្រដោយអំពើយង់ឃ្នងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលប្រាថ្នាចង់ឃើញការកាត់ទោសជនល្មើសឬគ្រាន់តែចង់ឃើញដំណើរការនៃការកាត់ទោស ។ ក្រុមគ្រួសារឬមិត្តភក្តិរបស់ជនរងគ្រោះ ឬសូម្បីតែពលរដ្ឋធម្មតាដែលមានប្រាក់ចំណូលទាបក៏អាចនឹងចូលរួមនៅក្នុងដំណើរការកាត់សេចក្តីដែរ ប្រសិនបើពួកគាត់គ្រាន់តែជិះរថយន្តក្រុងមួយរយៈពេលខ្លីដើម្បីទៅដល់ទីនោះ ជាជាងការចំណាយពេលជិះយន្តហោះ ។ លើសពីនេះទៀតៈ

ការដែលជនល្មើសជាប់ចោទពីបទប្រព្រឹត្តអំពើយង់ឃ្នងត្រូវបានបណ្តើរអាក្រោស មុនពេលចាប់ផ្តើមដំណើរការផ្លូវច្បាប់ ហើយត្រូវបានកាត់ទោសនៅក្នុងតុលាការក្នុងស្រុក ដោយប្រើភាសាមួយដែលពួកគេអាចយល់បានទៅតាមនីតិវិធីក្នុងស្រុក និងទទួលបានសាលក្រមមួយ ដែលស្របទៅនឹងអារម្មណ៍របស់ប្រជាជនក្នុងស្រុកដែរឬក៏អត់នោះអាចថា រួមទាំងទោសប្រហារជីវិតផងគឺជារឿងសំខាន់ខ្លាំងណាស់សម្រាប់សមាជិកក្រុមគ្រួសារជាច្រើននៃជនរងគ្រោះដោយសារអំពើប្រល័យពូជសាន៍នៅប្រទេសរ៉្វាន់ដា ។ រវាងជម្រើសយុត្តិធម៌ក្នុងស្រុកនិងយុត្តិធម៌ដោយតុលាការមួយដែល នឹងចាកចេញទៅបាត់បន្ទាប់ពីការកាត់សេចក្តីបញ្ចប់ទៅ (ដូចជាការកាត់ក្តីនៅ តង់ហ្សានី ដែលអនុវត្តនីតិវិធី និងមានចៅក្រមដែលគេមិនស្គាល់) វាមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលនោះទេប្រសិនបើភាគច្រើនបំផុតនៃអ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដា ហើយសូម្បីតែមន្ត្រីរដ្ឋាភិបាលរ៉្វាន់ដាក៏ចង់បានការកាត់ក្តីក្នុងស្រុក ឬព្រមព្រៀងឲ្យមានការសារភាពទោសក្នុងស្រុក ជាពិសេសពេលដែលនីតិវិធីក្នុងស្រុកអាចផ្តល់លទ្ធផលបានរហ័សជាងបើប្រៀបធៀបទៅនឹងនីតិវិធីអន្តរជាតិ ។

របាំងផ្នែកចិត្តសាស្ត្រដ៏ធំដែលមានស្រាប់របស់សាក្សីក្នុងការផ្តល់ជាកសិណសាក្សីនៅក្នុងតុលាការអន្តរជាតិ (ដូចជាភាពភ័យខ្លាចការសងសឹកក្នុងការចូលរួមក្នុងតុលាការភាពខ្វល់ខ្វាយអំពីការដកខ្លួនចេញពីជំងឺសតិអារម្មណ៍ពីអតីតកាល និងភាពអៀនខ្មាស ។ល ។) ត្រូវបានបំពេញបន្ថែមដោយឧបសគ្គផ្នែកភ័ស្តុភារដែលពួកគេជួបប្រទះនៅក្នុងតុលាការ ។ ឧបសគ្គទាំងនេះរួមមានការលំបាកក្នុងការចំណាយសោហ៊ុយធ្វើដំណើរ និងការសុំទិដ្ឋាការ និងការចំណាយពេលបំពេញការងារដើម្បីមកផ្តល់កសិណសាក្សី និងការទទួលខុសត្រូវចំពោះក្រុមគ្រួសារ ។

តាមធម្មតាការកំណត់ទីតាំងតុលាការនៅកន្លែងធំទូលាយមួយមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ គេត្រូវគិតដល់បញ្ហាសម្ភារឲ្យបានល្អិតល្អន់ផងដែរ ដើម្បីបង្កើនឲ្យបានជាអតិបរមានូវចំនួនមនុស្ស និងក្រុមអ្នកទទួលប្រយោជន៍ពីវត្តមានរបស់តុលាការក្នុងការកាត់ទោសជនល្មើស ។ ការគិតគូរពីកត្តាសន្តិសុខមិនត្រូវធ្វើឲ្យរាំងស្ទះដល់ទំនាក់ទំនងរបស់សាធារណជនជាមួយតុលាការ និងការរៀបចំកន្លែង និងការចូលរួមរបស់សាធារណជន ប្រកបដោយភាពកក់ក្ដៅឡើយ ។ ឧទាហរណ៍ ការដែលបុគ្គលិកតុលាការត្រូវបានការពារដោយរបាំងកញ្ចក់ដែលបាញ់មិនធ្លុះអាចជារឿងសំខាន់ ប៉ុន្ដែការដែលចៅក្រម រដ្ឋអាជ្ញា និងមេធាវីចុងចោទអាចស្ដាប់ឮក្នុងសវនាការនៅតុលាការ ហើយតុលាការអាចស្ដាប់ឮពួកគេវិញនោះក៏ជារឿងមួយដ៏សំខាន់ ។

អ្វីដែលអាចថាសំខាន់ជាងការដែលមានតុលាការមួយដែលនៅជិតនោះ គឺបញ្ហាភាសា ។ សារសំខាន់នៃបញ្ហានេះត្រូវបានបង្ហាញឲ្យឃើញតាមរយៈការដែលថា ការកាត់ទោសបុគ្គលណាម្នាក់ដោយប្រើភាសាមួយ ដែលបុគ្គលនោះមិនយល់អាចត្រូវបានពណ៌នាថា ជាការបំពានសិទ្ធិមនុស្សជាមូលដ្ឋានមួយ ។ ប្រសិនបើតុលាការមានទីតាំងនៅក្នុងស្រុកនោះ ប្រជាជនក្នុងស្រុកកាន់តែងាយស្រួលក្នុងការចូលរួម ។ វាជាការងាយស្រួលសម្រាប់អ្នកសារ-ព័ត៌មាន អ្នកសង្កេតការណ៍ សាធារណជនក្នុងស្រុក ក្នុងការយល់ក្នុងការរាយការណ៍ព័ត៌មាន ក្នុងការនិយាយអំពីការកាត់សេចក្ដី ហើយចុងក្រោយបង្អស់ងាយស្រួលក្នុងការវាយតម្លៃការកាត់ក្ដី ។

ដូចការកាត់ក្ដីនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅប្រទេសរ៉្វាន់ដាដែរ ការកាត់ក្ដីដែលប្រព្រឹត្តទៅដោយមានជំនួយពីអ្នកបកប្រែភាសា ហើយដែលមិនយល់ច្បាស់ពីវប្បធម៌និងនីតិវិធីក្នុងស្រុក នឹងនាំទៅរកការភ័ន្តច្រឡំនៅគ្រប់លំដាប់ថ្នាក់ ។ ដូចដែលសាលក្រមរបស់លោក ហ្កាគេអ៊ីស៊ូ បានទទួលស្គាល់ចៅក្រមតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅរ៉្វាន់ដានៅក្នុងរឿងក្ដីនោះ ប្រឈមនឹងភាពប៉ិនប្រសប់ក្នុងការសម្ដែងមតិរបស់ជនជាតិរ៉្វាន់ដាដែលធ្វើឲ្យពិបាកនឹងសន្និដ្ឋានថា តើសាក្សីពិតជាបានឃើញជនល្មើសប្រព្រឹត្តអំពើទាំងនោះដោយផ្ទាល់ ឬគ្រាន់តែរាយការណ៍ប្រាប់អំពីអ្វីដែលអ្នកដទៃបានឃើញ ហើយបានប្រាប់ទៅពួកគេ ។ ដូច្នេះវាមានការលំបាកនឹងដឹងថាតើចៅក្រមសម្រេចសេចក្ដីបានត្រឹមត្រូវដែរឬទេលើបញ្ហាវប្បធម៌នេះ ។


ទិដ្ឋភាពនៅក្នុងសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅពេលដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិ អាចឲ្យអ្នកបកប្រែភាសាធ្វើការងារតូចតាចបាន រចនាសម្ព័ន្ធរបស់តុលាការកូនកាត់អាចផ្តោតលើការយល់ដឹងពីតម្លៃនៃភាសានិងវប្បធម៌ក្នុងស្រុក ។ នៅក្នុងតុលាការកូនកាត់ ការបកប្រែនិងការសម្របសម្រួលផ្នែកវប្បធម៌ អាចជាផ្នែកសំខាន់មួយរបស់តុលាការ មិនមែនគ្រាន់តែជាការគិតឃើញ ឬការិយាធិបតេយ្យនោះទេ ។

ខុសគ្នាពីជនបរទេស ប្រជាជនក្នុងស្រុកមានអារម្មណ៍ជិតជាប់ទៅនឹងប្រទេសរបស់ខ្លួន ។ តួនាទីក្នុងការប្រាស្រ័យទាក់ទងនឹងធ្វើឲ្យជនជាតិភាគតិចមានជំនឿជឿជាក់អាចមានប្រសិទ្ធភាពជាងបើប្រៀបធៀបទៅនឹងដៃគូបរទេស ។ ដូចដែលលោក រីឆាត ហ្គោលស្តូន បាននិយាយថា វាជារឿងមួយដែលពិបាកនឹងនឹកស្មានដល់ណាស់ដែលថាជនជាតិប៊ូស្នៀម្នាក់និយាយថាតុលាការឧក្រិដ្ឋកម្មអន្តរជាតិរ៉្វាន់ដា មិនគួរចំណាយថវិកាបកប្រែភាសាបរទេសជាភាសាក្នុងស្រុកច្រើនពេកទេ ពីព្រោះថាមានឯកសារច្រើនដែលត្រូវបកប្រែ ហើយស្មុគ្រស្មាញទៀតផង ។ ស្រដៀងគ្នានេះដែរ ប្រជាជនក្នុងស្រុកអាចកត់សម្គាល់ថាជម្រើស ភាសាអង់គ្លេស ឬភាសាបារាំង ធ្វើជាភាសាប្រើប្រាស់ផ្លូវការ នៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិរ៉្វាន់ដា ស្របគ្នាជាមួយនឹងការអនុវត្តន៍របស់អង្គការសហប្រជាជាតិ ប៉ុន្តែទាស់ត្រង់ថា មិនសូវមានអ្នកប្រើភាសាបារាំងច្រើននៅក្នុងអតីតប្រទេសយូហ្គោស្លាវី ។ មានការចំណាយលើសលប់នៅក្នុងការបកប្រែឯកសារជាភាសាបារាំង នៅពេលដែលឯកសារជាភាសាក្នុងស្រុកមានតិចតួច ។

តុលាការអាចធ្វើកិច្ចការមួយចំនួនដើម្បីបង្កើនសក្តានុពលផ្នែកភាសារបស់តុលាការកូនកាត់ ។ ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលនៃតុលាការកូនកាត់ អាចតម្រូវឲ្យបុគ្គលិកបរទេសថ្នាក់ទាបចុះឈ្មោះចូលរៀនវគ្គសិក្សាភាសាក្នុងស្រុករយៈពេល១ខែដោយឥតបង់ថ្លៃ មុនពេលអ្នកទាំងនេះចាប់ផ្តើមការងារ ហើយផ្តល់ការបណ្តុះបណ្តាលភាសាពេញម៉ោងដោយឥតគិតថ្លៃដល់បុគ្គលិកទាំងអស់បើមានការស្នើសុំ ។ លើសពីនេះទៅទៀត ការជ្រើសរើសឲ្យចូលធ្វើការដោយផ្អែកលើចំណេះដឹងខាងភាសាបរទេសនិងជំនាញដែលជាកត្តាវិជ្ជមានសម្រាប់អ្នកចេះច្រើនភាសាអាចជួយបំបែករបាំងផ្នែកភាសាបានដែរ ។

ដំណើរទាក់ទងគ្នានៃវប្បធម៌ ទីតាំងនិងភាសារបស់តុលាការកូនកាត់ទៅនឹងនិយាមក្នុងស្រុក មានឥទ្ធិពលទទួលបានយោបល់កែលម្អសំខាន់បំផុតត្រង់ថា យោបល់ទាំងនេះធ្វើឲ្យតុលាការកូនកាត់មានលក្ខណៈងាយយល់ជាងមុនសម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ។ អ្នកយកព័ត៌មានក្នុងស្រុកដែលតែងជួបប្រទះកង្វះខាតថវិកា នៅពេលខ្លួនបម្រើការងារឲ្យសារព័ត៌មានឬស្ថានីយវិទ្យុតូចតាចមិនអាចមានលទ្ធភាពធ្វើដំណើរឆ្លងប្រទេសជាប្រចាំដើម្បីយកព័ត៌មានបានទេ ។ ការកាត់ផ្តាច់លទ្ធភាពរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកក្នុងការផ្សព្វផ្សាយអាចនាំមកនូវភាពស្មុគស្មាញច្រើនដល់ប្រជាជនទូទៅដែលពឹងផ្អែកទាំងស្រុងទៅលើប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ដោយសារតែបញ្ហាមិនចេះភាសា ។ មនុស្សភាគច្រើនបំផុតនៅក្នុងពិភពលោកពឹងផ្អែកលើព័ត៌មានក្នុងស្រុក បើទោះបីជាអ្នកមានចំណេះដឹងដែលចេះភាសាបរទេសអាចអានសារព័ត៌មាន ស្តាប់វិទ្យុ មើលទូរទស្សន៍បរទេសបានធ្វើដំណើរទៅកាន់ទីក្រុងឡាអេ ឬកន្លែងផ្សេងទៀតដើម្បីមើលការកាត់ក្តីដោយផ្ទាល់ក៏ដោយ ។ ជាការពិត ប្រជាជនងាយរងគ្រោះដែលទទួលរងគ្រោះខ្លាំងក្នុងពេលសង្គ្រាម ច្រើនតែជាអ្នកដែលមានកម្រិតការសិក្សាទាប អាស្រ័យហេតុនេះ អ្នកទាំងនោះមិនងាយនឹងយល់ឬទទួលបានផលប្រយោជន៍ពីសេចក្តីរាយការណ៍របស់សារព័ត៌មានអន្តរជាតិអំពីការកាត់ក្តីឧក្រិដ្ឋកម្មសង្គ្រាមទេ ។

ការរៀបចំដំណើរការកាត់ក្តីនៅក្នុងបណ្តាប្រទេសដែលមានអំពើឃោរឃៅកើតឡើង នឹងកាត់បន្ថយឧបសគ្គផ្នែកហិរញ្ញវត្ថុនិងសម្ភារដែលអ្នកយកព័ត៌មានជួបប្រទះ ហើយបង្កឲ្យមានលក្ខណៈងាយស្រួលជាងមុនក្នុងការផ្តល់ព័ត៌មានអំពីការកាត់ក្តីនិងជួយឲ្យការកាត់ក្តីក្លាយជាផ្នែកមួយនៃជីវភាពរបស់ប្រជាជនក្នុងស្រុក ។

ទន្ទឹមនឹងការទទួលស្គាល់ថា ប្រព័ន្ធផ្សព្វផ្សាយអាចដើរតួនាទីជាឧបករណ៍វិជ្ជមានមួយសម្រាប់ការផ្សព្វផ្សាយព័ត៌មាន គេក៏ត្រូវគិតពិចារណាដល់ហេតុផលមិនសមស្របក្នុងការអនុញ្ញាតឲ្យមានការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែរ ។ តួនាទីរបស់វិទ្យុ សារព័ត៌មាន និងទូរទស្សន៍នៅក្នុងការញុះញង់ឲ្យមានជម្លោះ

ឬផ្សព្វផ្សាយអំពីការឃោសនា ដុតបញ្ឆេះបំបែកបំបាក់ជាតិសាសន៍ ត្រូវបានដឹងឮសុសសាយនៅក្នុងករណីជាច្រើន ។ នៅពេលដែលវិទ្យុ មីលខូល្លីន នៅតែមានឈ្មោះអាក្រក់ជាងគេ សារព័ត៌មានក្នុងស្រុកនៅអតីតប្រទេសយូហ្គោស្លាវី ក៏បានផ្ដល់ឧទាហរណ៍ដែលថា ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកញុះញង់ឲ្យមានអំពើហិង្សា និងបង្កើនភាពតានតឹងដ៏គ្រោះថ្នាក់ផងដែរ ។ វិជ្ជាជីវៈសារព័ត៌មានដែលគ្មានការទទួលខុសត្រូវ អុជអាល និងញុះញង់ នៅតែមានវត្តមាននៅក្នុងប្រទេសជាច្រើនដែលស្ថិតក្នុងដំណាក់កាលក្រោយអំពើយង់ឃ្នង ។ នេះធ្វើឲ្យការបញ្ចូលប្រព័ន្ធផ្សព្វផ្សាយនៅក្នុងតុលាការឧក្រិដ្ឋកម្មសង្គ្រាម ជាកត្តាមួយសំខាន់សម្រាប់អប់រំអ្នកសារព័ត៌មាន និងផ្ដល់ភាពងាយស្រួលក្នុងការប្រមូលព័ត៌មានដែលមិនងាយនឹងបំភ្លៃបានដល់តំណាងសារព័ត៌មានក្នុងស្រុក ។

ជាធម្មតា ការដែលគ្រាន់តែសង្ឃឹមថា តាមរយៈការខិតចូលជិតគ្នាផ្នែកវប្បធម៌តុលាការកូនកាត់នឹងផ្ដល់ព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានប្រសើរជាងមុននោះ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ តុលាការកូនកាត់អាចមានប្រៀបជាងតុលាការអន្តរជាតិ នៅពេលប្រាស្រ័យទាក់ទងនឹងសារព័ត៌មានក្នុងស្រុក ប៉ុន្តែតុលាការទាំងនេះនៅតែតម្រូវឲ្យមានការចាត់ចែងមួយឲ្យបានល្អប្រសើរ ។ តុលាការទាំងនេះគួរមានបញ្ចូលផ្នែកទទួលបន្ទុកផ្ដល់ព័ត៌មានដែលផ្ដោតតែលើសារព័ត៌មាន វិទ្យុ និងទូរទស្សន៍ក្នុងស្រុក ។

## ៣) ការកសាងសមត្ថភាព និង ការកែសម្រួលហេដ្ឋារចនាសម្ព័ន្ធ

នៅពេលប្រៀបធៀបគ្នាអំពីសក្ដានុពលក្នុងការច្របាច់បញ្ចូលគ្នានឹងជះឥទ្ធិពលដល់វប្បធម៌ក្នុងស្រុកជាមួយនឹងតុលាការអន្តរជាតិ តុលាការកូនកាត់លេចធ្លោឡើងជាជម្រើសមួយដែលគួរឲ្យទទួលយក ។ តុលាការនេះអាចត្រូវបានបង្កើតឡើងដើម្បីជះឥទ្ធិពលដល់យុទ្ធសាស្ត្រតុលាការក្នុងស្រុកនិងប្រព័ន្ធយុត្តិធម៌ជាតិតាមរបៀបមួយដែលតុលាការអន្តរជាតិមិនអាចធ្វើបាន ។

និយាយដោយសាមញ្ញ នីតិវិធីជ្រើសរើសបុគ្គលិករបស់តុលាការកូនកាត់អាចជះឥទ្ធិពលធំធេងទៅលើកំណែទម្រង់យុត្តិធម៌ក្នុងស្រុក ។ ដោយសារថា បុគ្គលិកមួយផ្នែកធំនៃតុលាការកូនកាត់ត្រូវបានជ្រើសរើសចេញពីក្នុងចំណោមអ្នកមានសមត្ថភាពក្នុង


ក្រុមដូនជីទស្សនាមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ស្រុក តុលាការកូនកាត់បង្កើតឲ្យមានឱកាសដ៏មានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់អ្នកកាត់ក្តី និងចៅក្រមក្នុងស្រុកដែលមានសមត្ថភាពខ្ពស់បំផុត ឲ្យទទួលបានជំនាញអន្តរជាតិ និងតម្លៃសិទ្ធិមនុស្សអន្តរជាតិជាមូលដ្ឋាន ។ «ដំណើរការនៃតុលាការកូនកាត់ផ្តល់នូវអត្ថប្រយោជន៍ផ្នែកកសាងសមត្ថភាព... ។ ការរៀបចំឲ្យមានការបំពេញការងារប្រកៀកស្មាគ្នា ផ្តល់លទ្ធភាពឲ្យមានវគ្គបណ្តុះបណ្តាលសមត្ថភាពក្នុងពេលបំពេញការងារដែលអាចនឹងមានប្រសិទ្ធភាពជាងការពិភាក្សាតែនៅក្នុងថ្នាក់រៀនអំពីវិធាន និងគោលការណ៍ច្បាប់ផ្លូវការ ។ «បើគ្មានបទពិសោធន៍ទេ អ្នកមានវិជ្ជាជីវៈច្បាប់ក្នុងស្រុកមានឱកាសតិចតួចដើម្បីទទួលអនុវត្តរិះគន់ និងអភិវឌ្ឍន៍ និយាមអន្តរជាតិដែលខ្ញុំមិនយល់ កុំថាឡើយដល់ទៅសាធារណជនទូទៅនោះ» ។

បុគ្គលិករបស់យុត្តាធិការក្នុងស្រុកដែលបម្រើការងារនៅក្នុងតុលាការកូនកាត់ មិនត្រឹមតែទទួលបានផលប្រយោជន៍ពីបទពិសោធន៍របស់ខ្លួននោះទេ ។ អ្នកទាំងនោះរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសមាជិកយុត្តាធិការក្នុងស្រុកបានប្រសើរជាងបុគ្គលិកអន្តរជាតិ ដោយសារតែធ្លាប់មានចំណងមិត្តភាពនិងពាណិជ្ជកម្មតាមផ្លូវច្បាប់ ។ សង្ខេបសេចក្តីមក វត្តមាននៃតុលាការអន្តរជាតិមិនបង្កើតឲ្យមានយន្តការដើម្បីយកយុត្តិសាស្ត្ររបស់តុលាការនេះមកប្រើប្រាស់និងអភិវឌ្ឍន៍ឬសូម្បីតែគោរពនិងយល់នៅក្នុងកម្រិតជាតិនោះទេ ។

ដោយគិតពីបញ្ហានេះ យើងត្រូវតែកត់សម្គាល់ថា ការគ្រាន់តែផ្តល់ឲ្យបុគ្គលិកអន្តរជាតិនិងបុគ្គលិកក្នុងស្រុកទៅធ្វើការក្នុងអគារតុលាការនោះមិនមែនផ្តល់ជាឱសថទិព្វក្នុងការកសាងបញ្ហាសមត្ថភាពនោះទេ ។ «ដូចដែលរបាយការណ៍ថ្មីៗរបស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិនិងមជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌អន្តរកាលមានចំណងជើងថា «មរតកនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូនបានកត់សម្គាល់ថា មរតកវិជ្ជមានមិនមែនជាការព្យាករណ៍ដែលក្លាយជាការពិតដោយខ្លួនឯងនោះទេប៉ុន្តែយើងត្រូវតែរៀបចំនិងបង្កើតឲ្យបានល្អិតល្អន់ ។

នៅក្នុងអត្ថបទអំពីតុលាការកូនកាត់នៅទីម័រខាងកើត លោកស្រី ស៊ូហ្សាន កាហ្សិនស្តេន បានបង្ហាញបង្ហាញអំពីកំហុសនៃការសន្មតថា ការដែលត្រឹមតែមានវត្តមាននៅទីនោះ ចៅក្រមអន្តរជាតិនៃក្រុមជំនុំជម្រះពិសេសអាចដើរតួនាទីជាគ្រូបង្គោលផ្ទាល់នៅនឹងកន្លែងតែម្តងសម្រាប់ដៃគូក្នុងស្រុករបស់ពួកគាត់... ។ គ្រូបង្គោលជារឿយៗច្រើនតែបែកអារម្មណ៍ ឬប្រមូលយកការងារទាំងអស់ ដូចជាការសរសេរគំនិតនានាដែលធ្វើឲ្យខូចគោលបំណងនៃការបណ្តុះបណ្តាល ។ ជាពិសេសនៅពេលបុគ្គលិកមានការងារច្រើន ជួបភាពតានតឹងដោយសារមានពេលវេលាតិចតួច និងខ្វះខាតនីតិបង្រៀន ឬបទពិសោធន៍ក្នុងការបង្រៀននិងការកសាងសមត្ថភាពតុលាការចម្រុះមានដំណើរការរដិបរដុប ។ ការចាត់ចែងការងារមិនបានល្អអាចបំផ្លាញដល់រចនាសម្ព័ន្ធដែលមានរៀបចំផែនការទុកមុនបានយ៉ាងល្អ ។

នៅពេលពិនិត្យមើលទៅលើកម្មវិធីកសាងសមត្ថភាពដែលហួសពីកម្រិតដែលមានពណ៌នានៅក្នុងឯកសារនេះ អាចផ្តល់យោបល់ទូទៅមួយចំនួនដើម្បីកែលម្អផែនការបង្កើតតុលាការកូនកាត់នាពេលអនាគត ដោយធ្វើការពន្យារអាណត្តិរបស់តុលាការក្នុងការធានាថា តុលាការកូនកាត់ដើរតួនាទីជាអ្នកជួយសម្រួលឲ្យមានកំណែទម្រង់យុត្តាធិការក្នុងស្រុក ។

ដើម្បីពង្រឹងយុត្តាធិការក្នុងស្រុក តុលាការកូនកាត់ចាំបាច់ត្រូវមានចំណាត់ការឲ្យបានប្រសើរទៅលើចលនាអំណាចពិតប្រាកដនៅក្នុងតុលាការកូនកាត់ដោយផ្តោតទៅលើសមភាពរវាងបុគ្គលិកក្នុងស្រុកនិងអន្តរជាតិ និងដោយមានបញ្ចូលវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកតុលាការក្នុងស្រុក ក្នុងអំឡុងអាណត្តិរបស់តុលាការ ។ ភាពជាដៃគូក្នុងការផ្តល់យោបល់និងកម្មវិធីត្រួតពិនិត្យត្រូវតែពង្រឹងឲ្យបានជាប្រចាំ ដោយផ្តោតទៅលើការដឹកនាំនិងការគ្រប់គ្រងចាត់ចែងល្អប្រសើរ ។ គេអាចជំរុញឲ្យមានការកសាងសមត្ថភាពស្ថាប័នដោយផ្តល់ឱកាសធ្វើកិច្ចការក្នុងស្រុកដល់បុគ្គលិកជាន់ខ្ពស់អន្តរជាតិ ហើយម្យ៉ាងទៀតផ្តល់ឱកាសស្មើគ្នាឲ្យបុគ្គលិកក្នុងស្រុកដូចគ្នានឹងបុគ្គលិកអន្តរជាតិដែរ ។ នៅក្នុងករណីទី១ ដោយអនុវត្តតាមការណែនាំរបស់គ្រូបង្គោលនិងដោយទទួលបានយោបល់កែលម្អនិងមតិរិះគន់ស្ថាបនាជាប្រចាំ បុគ្គលិកក្នុងស្រុកដែលធ្វើការ

ក្រោមបង្គាប់បុគ្គលិកអន្តរជាតិ អាចនឹងទទួលបាននិយាមនិងវិធីសាស្ត្រនានាដើម្បីកែលម្អការងាររបស់ខ្លួនក្នុងនាមជាចៅក្រមរដ្ឋអាជ្ញា អ្នកការពារក្ដី នៅពេលក្រោយមកទៀត ។ នៅក្នុងសេណារីយ៉ូទី២ បុគ្គលិកអន្តរជាតិដែលធ្វើការក្រោមបង្គាប់ចៅក្រមនិងមេធាវីជាន់ខ្ពស់ក្នុងស្រុកអាចជួយដើរតួនាទីជាស្ពានចម្លងផ្នែកវប្បធម៌និងភាសាទៅឲ្យប្រធានរបស់ខ្លួន និងយកជំនាញផ្នែករដ្ឋបាលនិងច្បាប់មកប្រើនៅក្នុងការបំពេញការងារ ។ ផ្ទុយមកវិញ សមត្ថភាពនេះក៏ត្រឹមត្រូវផងដែរ ដោយថាបុគ្គលិកអន្តរជាតិរៀនសូត្រដកស្រង់យកបទពិសោធន៍ដ៏មានតម្លៃពីគ្រូបង្វឹកនិងអនុប្រធានក្នុងស្រុករបស់ខ្លួន ។ ការផ្លាស់ប្ដូរបទពិសោធន៍គ្នាទៅវិញទៅមកអាចផ្ដល់នូវផ្លែផ្កាជាវប្បធម៌ចម្រុះ ការកសាងសមត្ថភាពនិងការរៀនសូត្រពីគ្នាទៅវិញទៅមកដរាបណាបុគ្គលិកអន្តរជាតិយល់ច្បាស់ពីយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនិងការគ្រប់គ្រងចាត់ចែងការងារតុលាការជាទូទៅ (ដែលនេះមិនមែនជារឿងដែលតែងតែកើតឡើងនៅក្នុងគ្រប់តុលាការកូនកាត់ ដែលត្រូវបានបង្កើតឡើងកន្លងមកនោះទេ) ។ លើសពីនេះ គេអាចបង្កើនកម្រិតវប្បធម៌ចម្រុះ ដោយកំណត់អាណត្តិកិច្ចប្រជុំជាយុទ្ធសាស្ត្រ និងបទខុទ្ទេសនាមផ្ដល់ព័ត៌មានជាប្រចាំដែលតាមរយៈការធ្វើបែបនេះ បុគ្គលិកក្នុងស្រុកនិងអន្តរជាតិអាចនឹងត្រូវតម្រូវឲ្យពន្យល់ការងារគ្នា និងផ្ដល់យោបល់កែលម្អ និងគាំទ្រគ្នាទៅវិញទៅមក ។

តុលាការចម្រុះគួរតែដាក់បញ្ចូលការអប់រំផ្នែកច្បាប់ជាបន្តឲ្យដល់ចៅក្រម រដ្ឋអាជ្ញា មេធាវីចុងចោទ និងបុគ្គលិកតុលាការ ។ ធាតុផ្សំនៃការបណ្ដុះបណ្ដាលផ្នែកច្បាប់បន្តរហូតអាចនឹងបន្តទៅមុខទៀត ដោយដាក់បញ្ចូលទ្រឹស្ដី និងការអនុវត្តន៍ជាក់ស្ដែងក្នុងលក្ខណៈអាចបត់បែនបាន ហើយនៅពេលណាមួយសមស្របដាក់ឲ្យអនុវត្តរួមគ្នាជាមួយកម្មវិធីបណ្ដុះបណ្ដាលអន្តរជាតិដទៃទៀត ដើម្បីផ្ដល់ជំនួយបណ្ដុះបណ្ដាលបន្ថែមទៅឲ្យការកាត់ក្ដីក្នុងស្រុក ។ ប្រសិនបើតុលាការកូនកាត់ត្រូវបានផ្សារភ្ជាប់ទៅនឹងអង្គភាពដូចជាកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) ជាដើម ដែលផ្ដោតសំខាន់ទៅលើកំណែទម្រង់ច្បាប់និងការកសាងសមត្ថភាពស្ថាប័ននោះ តុលាការកូនកាត់អាចជំរុញឲ្យមានកំណែទម្រង់ក្នុងស្រុកបានច្រើន មិនមែនសម្រាប់តែបុគ្គលិកតុលាការកូនកាត់ប៉ុណ្ណោះទេ ។

កម្មវិធីអ្នកសង្កេតការណ៍ដំណើរការកាត់ក្ដី ក៏អាចត្រូវបានដាក់បញ្ចូលផងដែរ ដើម្បីផ្ដល់លទ្ធភាពឲ្យអ្នកសង្កេតការណ៍តុលាការក្នុងស្រុកអាចចូលរួមនិងសង្កេតការណ៍នៅក្នុងគ្រប់ដំណើរការកាត់ក្ដីទាំងអស់ ឬតម្រូវឲ្យពិនិត្យ និងវាយតម្លៃការកាត់ក្ដីខក្រិដ្ឋកម្មសង្គ្រាមដោយតុលាការកូនកាត់ ។ កម្មវិធីអ្នកសង្កេតការណ៍ដំណើរការកាត់ក្ដីសម្ញឹងឃើញភាពជាដៃគូដែលតាមរយៈនេះ បុគ្គលិកកម្មវិធីនឹងត្រូវផ្សារភ្ជាប់ទៅនឹងបុគ្គលិកយុត្តាធិការក្នុងស្រុកខ្លះដើម្បីធ្វើការត្រួតពិនិត្យនិងវាយតម្លៃដំណើរការកាត់ក្ដីរបស់តុលាការក្នុងស្រុកដោយផ្អែកលើមូលដ្ឋានប្រសិទ្ធភាពដំណើរការបានទាន់ពេលវេលា យុត្តាធិការនិងលក្ខណៈសមស្រប ។ ក្រោយពេលបញ្ចប់ការកាត់ក្ដីនីមួយៗ អ្នកសង្កេតការណ៍តុលាការដែលជាសមាជិកកម្មវិធី អាចជួបជាឯកជនជាមួយបុគ្គលិកយុត្តាធិការក្នុងស្រុកដែលពាក់ព័ន្ធដើម្បីពិនិត្យមើលការកាត់ក្ដីនិងផ្ដល់អនុសាសន៍សម្រាប់ការកែលម្អ ។ ជាមួយគ្នានេះដែរ កម្មវិធីហ្វឹកហាត់ពិសេសសម្រាប់និស្សិតច្បាប់ក្នុងស្រុកអាចត្រូវបានរៀបចំឲ្យមានរួមជាមួយនឹងការប្រគល់សិទ្ធិជាប្រចាំទៅក្រុមផ្សេងៗគ្នាឲ្យសង្កេតការណ៍ដំណើរការកាត់ក្ដី (មេដឹកនាំសាសនា អ៊ីម៉ាំ ព្រះសង្ឃ ជនពិការ សមាគមស្ត្រីមេម៉ាយ អតីតយុទ្ធជននិងសិស្ស ។ល ។) ។

ហេដ្ឋារចនាសម្ព័ន្ធរបស់តុលាការកូនកាត់ ទោះបីវាជាគម្រោងសាងសង់សំណង់ធំរឹងមាំសម្រាប់តុលាការនិងមន្ទីរឃុំឃាំងក៏ដោយ ឬបន្ទប់តូចៗដូចជាបន្ទប់រក្សាទុកម៉ាញ៉េនិងមីក្រូហ្វូនជាដើម អាចត្រូវបានយកមកដាក់នៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក ក្រោយពេលតុលាការកូនកាត់ចប់អាណត្តិរបស់ខ្លួន ។ ការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់តុលាការកូនកាត់អាចនឹងមានប្រយោជន៍ដល់យុត្តាធិការក្នុងស្រុកដរាបណា យុត្តាធិការនេះអាចដើរតួនាទីគំរូ ហើយការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់តុលាការកូនកាត់នេះ ដែលអាចបណ្ដុះបណ្ដាលបុគ្គលិក ដើម្បីបម្រើឲ្យប្រព័ន្ធយុត្តាធិការក្នុងស្រុកដែលនៅក្រោមបង្គាប់បានប្រសើរជាងមុន ។ នៅក្នុងបណ្ដាប្រទេសដែលហេដ្ឋារចនាសម្ព័ន្ធតុលាការត្រូវបានបំផ្លិចបំផ្លាញ

ដោយសន្ត្រាម ហើយមិនមានលក្ខណៈសម្បត្តិល្អគ្រប់គ្រាន់ដើម្បីចាប់ផ្តើមធ្វើការងារ ការកសាងហេដ្ឋារចនាសម្ព័ន្ធនេះមិនមែនជារឿងដែលយើងត្រូវមើលស្រាលនោះទេ ។ ប្រសិនបើលើកផែនការបានល្អិតល្អន់ ត្រឹមត្រូវ អគារតុលាការកូនកាត់អាចធ្វើជាទីតាំងតុលាការក្នុងស្រុកនាពេលអនាគតដោយផ្តល់នូវអគារតុលាការដែលរឹងមាំ បន្ទប់ធ្វើការសម្ភាសន៍សម្រាប់បម្រើការងារបកប្រែភាសាប្រកបដោយប្រសិទ្ធភាពនិងការចាត់ចែងរឿងក្តីនិងបណ្ណាល័យ ។ ជាពិសេស ប្រសិនបើការសាងសង់ដោយមានផែនការល្អិតល្អន់បែបនេះ តុលាការកូនកាត់អាចរួមចំណែកយ៉ាងធំនិងជានិមិត្តរូបនៃយុត្តិធម៌ក្នុងស្រុក ។ អំណះអំណាងជំទាស់ទៅនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធនេះ គឺថាអាចជារង្វាន់មួយដែលមានថ្នាំពុលសម្រាប់យុត្តាធិការក្នុងស្រុកដែលក្រពេក រហូតដល់គ្មានលទ្ធភាពថែរក្សាអគារ ឬមរតកផ្សេងៗទៀតឲ្យបានសមស្រប ។

**៤) ការទទួលស្គាល់សារសំខាន់នៃការពង្រឹងអំណាចក្នុងស្រុកតាមរយៈអ្នកសម្រេចចិត្តសំខាន់ៗ**

បុគ្គលិកជាច្រើននៃអង្គការសិទ្ធិមនុស្សនិងសហគមន៍ច្បាប់អន្តរជាតិបានបង្ហាញពីការមិនយល់ស្របទៅនឹងអន្តរជាតូបនីយ-កម្ម ការកាត់ក្តីឧក្រិដ្ឋកម្មសន្ត្រាម ឬយ៉ាងហោចណាស់ក៏ទទួលស្គាល់តម្លៃនៃការពង្រឹងអំណាចក្នុងស្រុកនិងផ្សារភ្ជាប់ទៅនឹងប្រជាជនក្នុងស្រុកដែរ ។ ជាការពិតអ្នកខ្លះជ្រុលរហូតដល់ទៅគិតតែពីទាមទារឲ្យមានការកាត់ក្តីនៅក្នុងស្រុក ដូចជាលោក ថេអូឌ័រ មេរេន ប្រធានតុលាការឧក្រិដ្ឋកម្មសន្ត្រាមនៅយូហ្គោស្លាវី បានធ្វើការកត់សម្គាល់ថា «ការកាត់ក្តីឧក្រិដ្ឋកម្មសន្ត្រាមនៅកន្លែងដែលអំពើឧក្រិដ្ឋកម្មបានកើតឡើងមានលក្ខណៈសមហេតុផលបំផុត ព្រោះការកាត់ក្តីទាំងនោះប្រព្រឹត្តទៅនៅក្បែរជនរងគ្រោះ ប្រជាជនក្នុងស្រុកមិនមែននៅឆ្ងាយរាប់ពាន់គីឡូម៉ែត្រនោះទេ ។» ដូចគ្នានេះដែរ អតីតប្រធានរដ្ឋអាជ្ញាតុលាការរ៉្វាន់ដាដែលកាន់រឿងក្តីដំបូងបំផុត លោក ព្យែរ រីឆាត ប្រូសភ័រ ដែលបច្ចុប្បន្នជាឯកអគ្គរដ្ឋទូតគោចររបស់សហរដ្ឋអាមេរិកផ្នែកឧក្រិដ្ឋកម្មសន្ត្រាម បានមានប្រសាសន៍ថា បទពិសោធន៍បានបង្ហាញថា តុលាការឧក្រិដ្ឋកម្មសន្ត្រាមយូហ្គោស្លាវី មានទីតាំងស្ថិតនៅឆ្ងាយពេកពីកន្លែងដែលបទឧក្រិដ្ឋបានកើតឡើង ។

សូម្បីតែអង្គការសិទ្ធិមនុស្សអន្តរជាតិល្បីៗ ដែលត្រូវបានចោទប្រកាន់ថាជាពួកជ្រុលនិយម ដោយសារតែអ្នកទាំងនោះគាំទ្រដាច់អហង្ការឲ្យមានវត្តមានតុលាការអន្តរជាតិក៏ដោយ ក៏នៅតែទទួលស្គាល់តម្លៃនៃភាពជាម្ចាស់និងការចូលរួមរបស់អ្នកស្រុកនៅក្នុងយន្តការរកយុត្តិធម៌ នៅក្រោយពេលមានជម្លោះដែរ ។ ឧទាហរណ៍ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានប្រកាសថា «នៅពេលណាដែលល័ក្ខខ័ណ្ឌចម្បងនានានៃយុត្តិធម៌ និងភាពស្មើភាពត្រូវបានបំពេញនៅពេលនោះវាគឺជាទំនួលខុសត្រូវក្នុងស្រុកក្នុងការកាត់ទោសឧក្រិដ្ឋកម្មសិទ្ធិមនុស្ស ។

លោក ប៊ូត្រូស ប៊ូត្រូស ហ្កាលី អតីតអគ្គលេខាអង្គការសហប្រជាជាតិបាននិយាយដោយបង្កប់នូវអត្ថន័យថា យន្តការអនុវត្តច្បាប់ប្រឆាំងឧក្រិដ្ឋកម្មក្នុងតំបន់អាចបង្កើតឲ្យមានការទទួលយកពីសំណាក់សហគមន៍ រងគ្រោះនៅពេលសហគមន៍ទាំងនោះមានអ្នកតំណាងដោយផ្ទាល់នៅក្នុងតុលាការថ្នាក់តំបន់ ។ ដូចដែល លោក ប៊ូត្រូស ប៊ូត្រូស ហ្កាលី បានលើកឡើង សកម្មភាពតំបន់រួមចំណែកឲ្យមានការចូលរួម ការឯកភាពគ្នា និងប្រជាធិប-តេយ្យភាវូបនីយកម្មស៊ីជម្រៅជាងមុននៅក្នុងកិច្ចការអន្តរជាតិ ។

ដូចគ្នានេះដែរ អ្នកសម្រេចចិត្តនិងអ្នកចេះដឹងនៅក្នុងប្រទេសដែលអំពើយង់ឃ្នងកើតមានឡើង គាំទ្រការចូលរួមរបស់ប្រជាជនក្នុងស្រុក ។ ឧទាហរណ៍ ប្រធានាធិបតីចូលកាន់តំណែងរបស់ប្រទេសសេរ៉ាឡេអូន លោក អាមេដ ថេហ្សាន់ កាបា បានជំទាស់ទៅនឹងវត្តមានតុលាការអន្តរជាតិសុទ្ធសាធ ព្រោះគាត់គិតថាការចូលរួមនិងភាពជាម្ចាស់របស់ប្រជាជនសេរ៉ាឡេអូននៅក្នុងដំណើរការកាត់ក្តីគឺជារឿងសំខាន់ ។ ស្រដៀងគ្នានេះដែរ ក្រោយពេលមានអំពើប្រល័យពូជសាសន៍ រដ្ឋាភិបាលរ៉្វាន់ដាចង់បានជំនួយអន្តរជាតិផ្នែកហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលដើម្បីកសាងសមត្ថភាពយុត្តាធិការដែលខ្ទេចខ្ទាំឡើងវិញ ហើយមានភាពស្ទាក់ស្ទើរក្នុងការយល់ព្រមឲ្យមានតុលាការអន្តជាតិសុទ្ធសាធមួយដើម្បីកាត់ទោសឧក្រិដ្ឋជនប្រល័យពូជសាសន៍ ។ ***(នៅមានត)***

**អេរ៉ែល ហ៊ីហ្គូនេត**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្តល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ ៖** នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែ្សតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ ៖** មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ ៖** ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង លី សុខឃាង តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



ដុំ សែម មកសាកសួរព័ត៌មានកូននៅការិយាល័យព័ត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា


មន្ថា និងប្អូនប្រុស សាមឿន នៅជំរុំខាវអ៊ីដាង

# ការលំបាកដែលខ្ញុំបានជួប

*(តចប់)*

***កម្មករសិប្បកម្មបារីនិងសាប៊ូ***

*ខ្ញុំមករស់នៅជាមួយឪពុកក្មេកនៅភូមិកំពង់ចន្ទុះលិច ឃុំពាមជីលាំង បានតែមួយថ្ងៃ ខ្ញុំក៏បានចូលបម្រើការងារជាកម្មករនៅសិប្បកម្មបារីនិងសាប៊ូ ។ ចំណែកប្រពន្ធខ្ញុំធ្វើការងារនៅផ្ទះជាមួយក្រុមគ្រួសារ ។ ព្រឹកមួយពេលព្រលឹមស្រាងៗនាដើមឆ្នាំ ១៩៧៥ ខ្ញុំបានឃើញកងទ័ពរំដោះធ្វើដំណើរទាំងប្រញាប់ប្រញាល់តាមដងផ្លូវពីពាមជីលាំងចុះទៅឃុំបឹងព្រួល ។ បន្ទាប់មកក៏ឃើញយន្តហោះធុន គេ-២៨ ទម្លាក់គ្រាប់បែកពូសួរគ្រាំៗនៅក្នុងព្រៃក្រោយឃុំបឹងព្រួល និងដឹងដំណឹងថាមានទាហាន លន់ នល់ជ្រៀតចូលក្នុងតំបន់នេះ ក្នុងនោះមានជនជាតិចាមផងបានលបឆ្លក់ចូលពីបឹមទន្លេបិទតាមបឹងអន្លោងដល់ភូមិបាតដីក្រោមនៃឃុំបឹងព្រួល ហើយកៀរជនជាតិចាមទៅកាន់ក្រុងកំពង់ចាម ដោយមានកាំភ្លើងធំ កងម៉ារីន និងយន្តហោះទម្លាក់គ្រាប់បែកគាំទ្រផង ។ ប៉ុន្តែប្រតិបត្តិការនេះត្រូវបរាជ័យទាំងស្រុងដោយកងកម្លាំងឆ្នក់ទាំងអស់ត្រូវទទួលរងការវាយប្រហារពីកងទ័ពរំដោះ ។ ទោះបីបែបនេះក៏ដោយ ក៏ការងាររបស់ខ្ញុំនៅដំណើរការដដែល ។ ខ្ញុំបានស្នាក់នៅនិងហូបចុកជាសមូហភាពនៅក្នុងសិប្បកម្មដែលមានទីតាំងនៅផ្ទះជយភណ្ឌសង់ពីឈើប្រក់ក្បឿង និងសង់រោងស្នាក់នៅលើទីទួលពីរនៅក្នុងភូមិពាម ឃុំពាមជីលាំង ។ ចម មានភាពឈ្លាសវៃក្នុងការធ្វើសេដ្ឋកិច្ចពាណិជ្ជកម្ម ព្រោះគាត់ជាអតីតនិស្សិតឆ្នាំទី២នៃសាកលវិទ្យាល័យកំពង់ចាម ដោយស្នាដៃរបស់គាត់បានធ្វើឲ្យស្រុកពាមជីលាំងមានកាណូត១០គ្រឿង រថយន្តពីរគ្រឿង ក្រដាសពុម្ព ទឹកបេក ស្ករទឹកឃ្មុំ និងវត្ថុធាតុដើមសម្រាប់ផលិតសម្ភារៈព្រមទាំងបានដោះស្រាយស្បៀង សម្លៀកបំពាក់ សម្ភារៈដល់កងទ័ពស្រុកនិងអង្គភាពជុំវិញបានគ្រប់គ្រាន់ ។*

*ធ្វើនៅសិប្បកម្មដំបូង ខ្ញុំជាអ្នកបោះពុម្ពកញ្ចប់បារីដែលមានរូបភាពព្រះអាទិត្យក្រហមនិងមានអក្សរថា «រស្មីរំដោះ» ។ ខ្ញុំខិតខំយកចិត្តទុកដាក់ធ្វើការងារយ៉ាងផ្ចិតផ្ចង់រហូតដល់ខ្ញុំទទួលបានជំនាញសំលៀងកាំបិតឲ្យមុតសម្រាប់ហាន់ថ្នាំនិងជំនាញបញ្ជាម៉ាស៊ីនហាន់ថ្នាំ ។ ក្រៅពីការងារស្នូលទាំងនេះ ខ្ញុំធ្វើកិច្ចការផ្ទះជាច្រើន និងធ្វើការផ្សេងៗទៀតសម្រាប់អង្គភាព ។ ទាំងអស់នេះធ្វើឲ្យថ្នាក់ដឹកនាំអង្គភាពនិងបុគ្គលិកកម្មករទាំងអស់ស្រឡាញ់រាប់អានខ្ញុំគ្រប់ៗគ្នា ។ ប្រធានសិប្បកម្មឈ្មោះ ឃាន អនុប្រធានឈ្មោះ ឡុង និងនារីឈ្មោះ ថន មកពីរកាខ្នុរ អ្នកទាំងពីរយកចិត្តទុកដាក់មកលើរូបខ្ញុំដែរ ហើយបានឲ្យខ្ញុំទទួលខុសត្រូវដឹកនាំការងារហាន់ថ្នាំ ធ្វើរបាយការណ៍ចំណូលចំណាយនិងកាន់ឃ្លាំងសម្ភារៈទៀតផង ។*

*ចាប់ពីដើមឆ្នាំ១៩៧៥ នៅស្រុកពាមជីលាំងមិនមានការចាយលុយទៀតឡើយ ការផ្លាស់ប្តូរទំនិញគឺធ្វើឡើងតាមរយៈយកមាស នាឡិកាដៃ ដូរយកអំបិល ស្ករ ស្រូវ អង្ករ ពោត និងសណ្តែកជាដើម ។ នៅតាមភូមិប្រជាជនមានបដាពាក្យស្លោកជាច្រើនធ្វើជាខ្លោងទ្វារអំពីឈើលាបពណ៌ក្រហម ដែលមានអត្ថន័យថា «ជយោ! កងទ័ពប្រជាជនបដិវត្តន៍កម្ពុជា» «ជយោ! ប្រជាជនកម្ពុជាដ៏មហិមា» «សមរភូមិក្រោយប្តេជ្ញាខបត្តម្ភសមរភូមិមុខ» «ប្តេជ្ញាវាយកម្ទេចចារកម្ម សន្តិសម្ព័ន្ធឲ្យអស់ពីក្នុងជួរប្រជាជន» ។ ជារឿយៗ ខ្ញុំបានឃើញក្បួនដំណើររបស់ប្រជាជនវៀតណាមជាច្រើនគ្រួសារដោយមិនដឹងថាចេញពីតំបន់ណាទេ ឆ្លងកាត់ត្រង់ផ្សារពាមជីលាំង តាមផ្លូវក្អិតឆ្ពោះទៅកាន់ប្រទេសវៀតណាមវិញ ។ ក្បួនដំណើរនេះខ្លះមានរទេះរុញ ខ្លះរែកខ្លះទូល ខ្លះជួយគ្រាហ៍មនុស្សចាស់ជរា ខ្លះពកេ្មងតូចៗ និងដាក់ទ្រព្យសម្បត្តិតាមខ្លួនតែបន្តិចបន្តួចប៉ុណ្ណោះ ។ ជនជាតិចិនខ្លះដោយមិនអាចទ្រាំទ្រនឹងការលំបាកនិងគ្មានសេរីភាពក្នុងការធ្វើជំនួញដោយសារត្រូវរដ្ឋអំណាចកៀបសង្កត់ឲ្យដឹកព្រែកប្រឡាយ ធ្វើស្រែចម្ការ ដឹកជញ្ជូនស្បៀងទៅសមរភូមិក៏សម្រេចចិត្តចូលរួមជាមួយក្បួនអាណិកជនវៀតណាមទៅរស់នៅប្រទេសវៀតណាមដែរ ។*

***ជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥***

*ប្រជាជនទូទៅក្នុងស្រុកពាមជីលាំង ក៏ដូចជារូបខ្ញុំដែរបាន*

សម្តែងនូវភាពសប្បាយរីករាយចំពោះជ័យជម្នះទៅលើរបបលន់ នល់ ដោយខ្លះស្រែកហ៊ោកញ្ជ្រៀវ ទះដៃអបអរសាទរ វាយស្គរ គោះប៉ោត លោតកញ្ឆេង សម្តែងមនោសញ្ចេតនាសប្បាយរីករាយ រួចនាំគ្នាចោមរោមស្តាប់វិទ្យុរណសិរ្សដែលផ្សាយចេញពីភ្នំពេញ ។ ដើម្បីអបអរសាទរចំពោះជ័យជម្នះនេះ គ្រប់អង្គភាពបានរៀបចំកម្មវិធីជួបជុំសំណេះសំណាលពីសមិទ្ធផលនៃជ័យជម្នះនេះ ។ ចំណែកខ្ញុំក៏បានទៅចូលរួមក្នុងកម្មវិធីជួបជុំកម្មាភិបាល បុគ្គលិក កម្មករ អង្គភាពសេដ្ឋកិច្ច ស្រុកពាមជីលាំង នៅជិតវិហារ អ៊ីស្លាម ឃុំកំពង់ទ្រាសនេះដែរ ។

ប្រធានអង្គភាពសិប្បកម្មបារីនិងសាប៊ូ បានធ្វើការប្រជុំកម្មាភិបាលបុគ្គលិក កម្មករ ឲ្យខិតខំពង្រឹងទាំងនយោបាយសតិអារម្មណ៍ ចាត់តាំងបន្តវាយសម្រុកតាមគោលការណ៍របស់បក្ស និងត្រូវគោរពអង្គការវិន័យចាត់តាំងរបស់បក្សឲ្យបានដាច់ខាតដូចជាចូលរួមការងារពលកម្ម ទាំងពលកម្មសង្គមនិយម (ពលកម្មក្រៅម៉ោងដែលចាប់ផ្តើមពីម៉ោង៨ទៀបភ្លឺរហូតដល់ភ្លឺ និងក្រោយពេលបាយថ្ងៃត្រង់និងនៅពេលយប់) និងពលកម្មតាមការចាត់តាំង (ការងារពលកម្មស្នូលជាការងារដែលអង្គការបានប្រគល់ឲ្យធ្វើអ្វីត្រូវតែបំពេញការងារនោះឲ្យបានពេញម៉ោង) ។ ជាមួយគ្នានេះប្រធានសិប្បកម្មក៏បានផ្តាំផ្ញើថាកុំឲ្យមានទំនាក់ទំនងជាមួយប្រជាជនថ្មីដែលទើបជម្លៀសមកពីទីក្រុងភ្នំពេញ និងតាមខេត្តនានា ពីព្រោះអ្នកទាំងអស់នោះជាប់ពាក់ព័ន្ធនឹងរបប លន់ នល់ ។

ប្រាំថ្ងៃក្រោយថ្ងៃជ័យជម្នះ១៧ មេសា ឆ្នាំ១៩៧៥ រដ្ឋអំណាចឃុំស្រុក បានអនុញ្ញាតឲ្យប្រជាជនខ្លះដែលជម្លៀសមកតាំងពីឆ្នាំ១៩៧៣ វិលទៅស្រុកកំណើតវិញ ក្នុងនោះក្រុមគ្រួសាររបស់ខ្ញុំ និងអ្នក១៧ មេសា ត្រូវអង្គការអនុញ្ញាតឲ្យវិលត្រឡប់ទៅរស់នៅស្រុកកំណើតភូមិកំពង់ឫស្សី ឃុំជីរោទិ៍១ ស្រុកពាមជីលាំងវិញ ។ ពេលទៅដល់ អង្គការស្រុកបានចាត់តាំងឲ្យប្រជាជនមូលដ្ឋានធ្វើជម្រកស្នាក់នៅសម្រាប់អ្នកជម្លៀសនៅភូមិគកនិងភូមិពើក ឃុំថ្មពេជ្រ ដោយសង់ខ្ទមជាជួរៗប្រក់ដំបូលស្បូវទំហំ៣ម៉ែត្រគុណ៤ម៉ែត្រ ។ បន្ទាប់មកអង្គការ ក៏បានលើកទិសប្រមូលអ្នកជម្លៀសពីគ្រប់មូលដ្ឋានទាំងអស់ឲ្យទៅរស់នៅភូមិទាំងពីរនេះ ។

មិត្ត ចម បានត្រូវអង្គការផ្លាស់ឲ្យទៅធ្វើជាអនុប្រធានស្រុកក្រូចឆ្មារ ហើយអនុប្រធានស្រុកក្រូចឆ្មារ ឈ្មោះ កែវ ស៊ីថាន ផ្លាស់មកធ្វើជាអនុប្រធានស្រុកពាមជីលាំងវិញ ។ ខ្ញុំបានសុំ



កងទ័ពខ្មែរក្រហមចូលក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥

សំបុត្រធ្វើដំណើរពីអនុប្រធានស្រុកដើម្បីទៅសាកសួរសុខទុក្ខប្អូនថ្លៃឈ្មោះ តង នៅភូមិដំនីក ស្រុកក្រូចឆ្មារ ដែលអង្គការបានបញ្ឈប់ពីការងារជាប្រធានសិប្បកម្មចម្រុះរដ្ឋភូមិភាគបូព៌ានៅប៉ើសទៅជាប្រជាជនសាមញ្ញ ។ ពេលធ្វើដំណើរមកវិញ ខ្ញុំឆ្លៀតឱកាសប្រើប្រាស់សំបុត្រធ្វើដំណើរនេះ ឆៀងចូលទៅសួរសុខទុក្ខបងខ្ញុំដែលរស់នៅភូមិគក ឃុំថ្មពេជ្រទៀត ព្រោះស្ថានភាពតាមដងផ្លូវឈ្លបបានឃាត់និងសួររកសំបុត្រធ្វើដំណើរ ។ ក្រោយពីពិនិត្យរួចរាល់ ខ្ញុំក៏បានជួបនឹងបងថ្លៃរបស់ខ្ញុំ ។ គាត់ស្វាគមន៍ខ្ញុំដោយទឹកភ្នែករលីងរលោង ដែលធ្វើឲ្យខ្ញុំរំជួលចិត្តនឹកគិតថា ប្រហែលជាមានហេតុការណ៍មិនល្អកើតឡើងហើយ ។ ភ្លាមនោះគាត់ប្រាប់ខ្ញុំថាបងរបស់ខ្ញុំត្រូវបានឈ្លបមកនាំយកទៅរៀនសូត្រហើយ ដោយប្រាប់ថាមិនចាំបាច់យករបស់របរអ្វីទៅជាមួយខ្លួនទេ ព្រោះរៀននៅជិតនេះ ។ បងថ្លៃខ្ញុំរៀបរាប់ទៀតថា ឈ្លបបានមកហៅទៅរៀនសូត្រ គឺបន្ទាប់ពីគាត់មកនៅភូមិជម្លៀសបានបីថ្ងៃ ។ ខ្ញុំគ្រាន់តែស្តាប់ពាក្យថា អង្គការយកបងខ្ញុំទៅរៀនសូត្រ ខ្ញុំញ័រមាត់រកហាស្តីមិនកើតចាំស្តាប់តែបងថ្លៃខ្ញុំរៀបរាប់ប៉ុណ្ណោះ ។ ក្រោយមកខ្ញុំបានលាបងថ្លៃខ្ញុំត្រឡប់មកផ្ទះវិញ ។

ព្រឹកឡើងខ្ញុំចូលធ្វើការនៅក្នុងអង្គភាពវិញ ហើយមិនហ៊ាននិយាយពីការបាត់បងរបស់ខ្ញុំប្រាប់អ្នកណាឡើយសូម្បីតែឪពុកម្តាយបងប្អូនបង្កើតរបស់ខ្ញុំក៏ដោយ ។ ជារៀងរាល់ថ្ងៃ ខ្ញុំខិតខំបង្កើនការងាររបស់ខ្ញុំទ្វេដង មិនឲ្យអ្នកណាម្នាក់ចាប់អារម្មណ៍មកលើខ្ញុំឡើយ ។

អង្គភាពសិប្បកម្មរបស់ខ្ញុំមានភារកិច្ចធ្វើស្រែនិងដាំបន្លែបង្ការសម្រាប់ផ្គត់ផ្គង់អង្គភាព ។ រដូវវស្សាឆ្នាំ១៩៧៥ បានឈានចូលមកដល់ បុគ្គលិកកម្មករអង្គភាពខ្ញុំកំពុងត្រួសត្រាយដីស្រែប្រដេញទឹកនៅក្រោយភូមិពាមក្នុង ។ ដោយសារការភ័យខ្លាចអង្គការយកទៅសម្លាប់ ខ្ញុំបានខិតខំធ្វើការងារគ្មានឈប់ឈរដោយមិនគិតពីការនឿយហត់ឡើយ ។

បង ថន ដែលជាស្រីមេម៉ាយ (ស្វាមីធ្វើពេទ្យស្លាប់ក្នុងសមរភូមិ) ជាអនុប្រធានសិប្បកម្មរបស់ខ្ញុំ ។ គាត់ពេញចិត្តការងាររបស់ខ្ញុំណាស់ ហើយគាត់តែងតែមកអង្គុយនិងជជែកលេងនៅរោងសម្រាករបស់ពួកខ្ញុំស្ទើរតែរាល់យប់ ។ ថ្នាក់ដឹកនាំសិប្បកម្មទាំងអស់តែងតែប្រើខ្ញុំឲ្យធ្វើលេខាកត់ត្រាធ្វើរបាយការណ៍ផ្សេងៗតាមដែលត្រូវការ ដូចជា បង ថន គាត់មិនចេះអក្សរ ហើយប្រើខ្ញុំឲ្យសរសេរសំបុត្រទៅប្រធានមន្ទីរពេទ្យ-៣១ នៅរកាខ្នុរដើម្បីសុំថ្នាំពេទ្យ ។ ពេលដែលប្រធានមន្ទីរពេទ្យ-៣១ នៅរកាខ្នុរផ្ញើថ្នាំមកឲ្យគាត់ៗតែងចែករំលែកថ្នាំពេទ្យទាំងនោះឲ្យក្រុមគ្រួសារខ្ញុំប្រើមិនដែលខានឡើយ ។ ក្រៅពីនេះ បង ថន បានលួចលាក់ទុកបាយកកត្រីសាច់ បន្ថែម សម្រាប់ផ្គត់ផ្គង់ខ្ញុំទៀត ពីព្រោះគាត់មានទំនាក់ទំនង



ជិតស្និទ្ធជាមួយ តង និង ចម ។

## សកម្មភាពការងារនៅសិប្បកម្មក្រោយក្រោយថ្ងៃរំដោះ

ក្រោយពីបានបញ្ចប់វគ្គច្រូតកាត់បោកបែនស្រូវទុកដាក់ក្នុងជង្រុករួចរាល់ នៅរដូវប្រាំងដើមឆ្នាំ១៩៧៦ អង្គការបានផ្សព្វផ្សាយឲ្យអនុវត្តតាំងពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋានអំពីគោលនយោបាយលើកប្រព័ន្ធភ្លឺស្រែនិងប្រឡាយអាងទឹក ។ អង្គភាពខ្ញុំត្រូវបញ្ជូនបុគ្គលិកកម្មករឲ្យទៅធ្វើការងារតាមការដ្ឋាន

នានារបស់អង្គភាពស្រុក នៅសល់តែប្រធានដែលគាត់ប្រើពេលវេលាភាគច្រើននៅតាមការដ្ឋានមកជួយមើលការខុសត្រូវការងារសិប្បកម្មមួយថ្ងៃឬពីរថ្ងៃក្នុងមួយសប្តាហ៍ ។ ក្រៅពីនេះនៅសល់បងថន និងបុគ្គលិកនារីពីរ-បីនាក់ ព្រមទាំងខ្ញុំម្នាក់ផង ។ មូលហេតុដែលអង្គការទុកខ្ញុំឲ្យនៅសិប្បកម្មព្រោះខ្ញុំអាចធ្វើការងារបានច្រើនមុខ ។ ពេលធ្វើការនៅទីនេះ ខ្ញុំអាចមានពេលវេលាមកមើលថែកូនស្រីច្បងនិងកូនប្រុសបន្ទាប់របស់ខ្ញុំដែលកើតជំងឺអុតនិង



កញ្ជ្រឹលបន្តបន្ទាប់ ។ ប៉ុន្តែពេលខ្លះសំណើសុំរបស់ខ្ញុំក៏ត្រូវបានបដិសេធដែរ ប្រសិនបើនៅសិប្បកម្មមានការងារច្រើន ។ ស្ថានភាពពេលនោះ ប្រពន្ធខ្ញុំបានយកកូនទៅព្យាបាលនៅពេទ្យឃុំផងនិងពេទ្យស្រុកផង ។ ដោយសារកូនទាំងពីររាកមួលនៅតែមិនជាសះស្បើយ ខ្ញុំបាននាំកូនទាំងពីរទៅមកផ្ទះវិញ ។ ទីបំផុតកូនទាំងពីររបស់ខ្ញុំបានជាសះស្បើយដោយសារស្ត្រីចំណាស់ម្នាក់នៅភូមិពាមជួយអុជធូបបន់ស្រន់ ។

ពេលក្រោយមកទៀត ខ្ញុំត្រូវបានអនុប្រធានស្រុកពាមជីលាំងឈ្មោះ កែវ ស៊ីថាន ចាប់អារម្មណ៍ និងចង់ស្នើខ្ញុំធ្វើជាប្រធានមន្ទីរសេដ្ឋកិច្ចជំនួសតំណែងមិត្ត ណាង ។ ក៏ប៉ុន្តែខ្ញុំត្រូវ ណាងរាយការណ៍ទៅវិញថា ខ្ញុំជាប្រជាជនជម្លៀសឆ្នាំ១៩៧៣ទេ មិនសមស្របតាមលក្ខខណ្ឌសម្រិតសម្រាំងរបស់អង្គការឡើយ ។

នៅដើមឆ្នាំ១៩៧៧ អ៊ុក ប៊ុនឈឿន ជាអនុប្រធានតំបន់ ២១ បានចុះមកបើកវគ្គសិក្សានយោបាយនៅស្រុកពាមជីលាំង ដោយយកទីតាំងវត្តពាមជាមន្ទីរពេទ្យស្រុកនិងព្រះវិហារធ្វើជាសាលារៀន ។ កម្មាភិបាលដែលត្រូវចូលរៀនវគ្គនេះមានកម្មាភិបាលសំខាន់ៗថ្នាក់ស្រុក កម្មាភិបាលថ្នាក់ឃុំ (ប្រធានអនុប្រធានឃុំនិងប្រធានកងតូច) ។ ខ្ញុំត្រូវ យាន ចាត់ឲ្យរាយខ្សែភ្លើងចេញពីឌីណាម៉ូម៉ាស៊ីនហាន់ថ្នាំក្នុងព្រះវិហារនិងកុដិមួយដែលជាកន្លែងស្នាក់នៅរបស់ អ៊ុក ប៊ុនឈឿន និងតាសុខ ប្រធានពេទ្យស្រុកពាមជីលាំង ។ នៅខាងកើតវត្តនេះមានរោងបាយមួយសម្រាប់សិក្ខាកាមមកពីមូលដ្ឋានស្នាក់នៅ ។ ការហូបចុករបស់អ្នកទាំងនោះគឺបបរពេលព្រឹក មានបាយ បន្ថែមនៅពេលថ្ងៃត្រង់និងល្ងាច ។ ក្រោយពីបញ្ចប់វគ្គ សិក្ខាកាមទាំងអស់ត្រូវត្រឡប់ទៅអង្គភាពរៀងៗខ្លួនវិញ ។ រំលងបាន៣ថ្ងៃ ប្រធានឃុំពាមជីលាំង ដែលត្រូវអង្គការអញ្ជើញឡើងមកស្រុកជាមួយកម្មាភិបាលដទៃទៀតក៏ត្រូវសន្តិសុខតំបន់ឈ្មោះ យិន សុភី ចាប់ចងស្លាបសេកបញ្ជូនឡើងឡានរ៉ឺលវ៉ាហ្គែនពណ៌ស្វាទុំយកទៅបាត់ ។ ខ្ញុំកាន់តែមានការតក់ស្លុតព្រោះវណ្ណៈភាព គោលជំហរ សតិអារម្មណ៍របស់ខ្ញុំមិនល្អ ។ បន្ទាប់មក អ៊ុក ប៊ុនឈឿន ក៏បានចូលមកមើលសិប្បកម្មខ្ញុំដោយមាន យាន អមដំណើរជាមួយខណៈដែលខ្ញុំកំពុងផលិតសាប៊ូដុំ ។ អ៊ុក ប៊ុនឈឿន បានជំរុញឲ្យមិត្ត យាន ខិតខំពង្រីកសិប្បកម្មនេះឲ្យកាន់តែធំថែមទៀត ។

## ការធ្វើវិសុទ្ធកម្ម

កម្មាភិបាលទូទាំងស្រុកពាមជីលាំងភាគច្រើនត្រូវទទួលរងនូវការចាប់ចងយកទៅសម្លាប់ចោលដូចជាប្រធានយោធាស្រុកពាមជីលាំងត្រូវបានចាប់ខ្លួនជាមួយកម្មាភិបាលកងទ័ពមួយចំនួន ។ បន្ទាប់មកចាប់ខ្លួន តាអោក ប្រធានសន្តិសុខស្រុកនិងកម្មាភិបាលរបស់គាត់មួយចំនួន និង កែវ ស៊ីថាន ជាអនុប្រធានស្រុក ។ ទន្ទឹម

នឹងការចាប់ខ្លួននេះ ស្រាប់តែលេចឮព្រឹត្តការណ៍ សោ ភឹម ធ្វើអត្តឃាត និងមានឮស្នូរផ្ទុះអាវុធនៅតាមដងផ្លូវជាតិលេខ៧ ក្នុងស្រុកត្បូងឃ្មុំ ។ កងកម្លាំងប្រដាប់អាវុធមួយចំនួនបានបាក់ទ័ព ទម្លាក់អាវុធ រត់មកពួនសម្ងំរស់នៅក្នុងផ្ទះប្រជាជន ។ ក្រោយមក ទៀតឮថា ភូមិភាគនិរតីធ្វើរដ្ឋប្រហារ ។

នៅស្រុកពាមជីលាំងឯណោះវិញ មានការប្រមូលបុគ្គលិក កម្មករគ្រប់អង្គភាពឲ្យកាន់អាវុធប្រយុទ្ធជាមួយកងទ័ព ប៉ុល ពត ។ អាវុធ *AK CKC B40* ថ្មីសន្លាងជាប់ខ្លាញ់គោ បានដឹកពីក្រុចឆ្មារ មកចែកឲ្យកងទ័ពស្រុកពាមជីលាំង ។ កម្មាភិបាលបុគ្គលិកកម្មករ ទាំងអស់កាន់អាវុធយ៉ាងសង្ងាត់ឈរជ្រែងនៅគល់ស្ពានពាមជីលាំង ព្រោះការងារនៅក្នុងអង្គភាពមន្ទីរត្រូវបានផ្អាកដោយម្នាក់ៗគិត តែបញ្ហានយោបាយ ។ ពេលនោះមានខ្ទម្អាគចក្រមួយគ្រឿង បានហោះពីលើផ្សារពាមជីលាំងបាចគ្រាក់អំពាវនាវឲ្យប្រឆាំងនឹង កងទ័ពក្បត់ជាតិ សោ ភឹម ។ នៅពេលយប់ស្ងាត់ ខ្ញុំបានដើរចល័ត ចុះឡើងដើម្បីពិនិត្យសភាពការណ៍ ប៉ុន្តែមិនឃើញមានអ្វីឡើយ ។ ព្រឹកឡើង យាន ដើរត្រហេបត្រហបមករាយការណ៍ថា សភាព ការណ៍មិនស្រួលទេ ត្រូវបំបែកផ្លូវទៅរស់នៅតាមផ្ទះសិន ។ ឮដូច្នេះ ខ្ញុំបានទៅយកថ្នាំកូតាបលីងជាមួយក្រដាសពុម្ពមួយចំនួននិងសេះ មួយក្បាលយកទៅផ្ទះ ។ ចំណែកបុគ្គលិកកម្មករដទៃទៀតក៏យក អីវ៉ាន់បន្តិចម្នាក់ៗដែរជាមួយរទេះគោផង ។ ទៅដល់ផ្ទះបានមួយ យប់ ព្រឹកឡើងប្រធានកងតូចប្រើខ្ញុំឲ្យទៅកាប់ព្រៃត្រែងនៅឯមាត់ ទន្លេ ។ ប្រហែលជាម៉ោង៩ព្រឹក កងទ័ពប៉ុល ពត បានដៅ្វងគ្រាប់ ៧៩មួយគ្រាប់ពីក្បាលកោះជ្រូកមកធ្លាក់នៅមាត់ប្រាំងកំពង់ចន្ទុះ លិច ។ ក្រោយពេលហូបបាយថ្ងៃត្រង់រួច មានការប្រកាសឲ្យ បុគ្គលិកកម្មករទៅជួបជុំនៅវត្តពាមជីលាំង ដោយកងទ័ពភូមិភាគ និរតីនិយាយរដឺនៗជាអ្នកដឹកនាំអង្គប្រជុំ បានចោទប្រកាន់អ្នក ដឹកនាំកន្លងមកថា ជាជនក្បត់ជាតិធ្វើបាបបងប្អូន ។ ពេលនោះ ខ្ញុំបានប្រាប់ប្រពន្ធខ្ញុំថា យើងមានកូនតូចៗឈឺញឹកញាប់យើងត្រូវ តែនៅទីនេះ ព្រោះនៅជិតមន្ទីរពេទ្យស្រុក ។ ប៉ុន្តែដោយខ្ញុំមិនអាច ជម្នះចិត្តប្រពន្ធខ្ញុំបាន ខ្ញុំក៏ស្របតាមការសម្រេចរបស់ប្រពន្ធខ្ញុំ ទៅរស់នៅជាមួយឪពុកម្ដាយបង្កើតខ្ញុំនៅភូមិកំពង់ឫស្សីវិញ ។

ពេលដែលកងទ័ពនិរតីចូលមកគ្រប់គ្រងស្រុកពាមជីលាំង កម្មាភិបាលភូមិភាគនិរតីបានចាប់កម្មាភិបាលកងតូចកងធំ បុគ្គលិក កម្មករ កម្មាភិបាលយុទ្ធជនយុទ្ធនារីក្នុងស្រុកទាំងអស់យកទៅសម្លាប់ ចោល ខ្លះដឹកតាមកាណូតវាយចោលទម្លាក់ទៅក្នុងទឹកទន្លេ ខ្លះដឹក តាមរទេះសេះ តាមរថយន្តយកទៅបាញ់ចោលក្នុងព្រៃ ។ ពេល នោះកងទ័ពពិការជាង១០នាក់នឹកថា បានរួចខ្លួនពីទុក្ខទោសហើយ ក៏ធ្វើដំណើរជ៉ាក់ប៉ើកៗទាំងលំបាកពីជំរំអង្គភាពមកផ្ទះសម្បែង ជួបជុំគ្រួសារបងប្អូនវិញ ប៉ុន្តែទឹកស្មានមិនដល់អ្នកទាំងអស់នេះ ត្រូវកម្មាភិបាលភូមិភាគនិរតីនាំខ្លួនយកទៅសម្លាប់ចោលទាំងអស់ ដោយបោះទៅក្នុងរណ្ដៅនៅក្រោយមន្ទីរសន្តិសុខ តាអោក រួច បោកគ្រាប់បែកកម្ទេចសាកសពទៀត ។ ចំណែក យាន និងនារី ឈាន ជាប្រពន្ធរបស់គាត់ក៏ត្រូវបានចាប់ខ្លួនដាក់កាណូតយកទៅ សម្លាប់ដែរ ។

## ការងារនៅកងចល័ត

ខ្ញុំទៅភ្ជួរដីនៅការដ្ឋានពើកបានពីរ-បីថ្ងៃ ប្រធានមុខព្រួញ បានចាត់តាំងឲ្យខ្ញុំទៅកាន់ភូមិព្រែកកំពែង ឃុំអញ្ចើម និងឃុំជីរោទិ៍១ ។ បន្ទាប់មកខ្ញុំត្រូវបានប្រធានមុខព្រួញចាត់ឲ្យទៅភ្ជួររាស់នៅ ការដ្ឋាន ភូមិរកាឃ្លុច ឃុំជីតាទៀត ដោយសំណាក់នៅលើកុដិឈើ ជិតរបងខាងមុខវត្ត ។ នៅទីតាំងនេះ ប្រធានកងខ្ញុំបានប្រកាសជា រៀងរាល់ពេលល្ងាចថា ហាមមិនឲ្យហាលខោអាវទុកចោលទេ ត្រូវទុកសម្លៀកបំពាក់ក្នុងបាឡូជាប់ជានិច្ចដើម្បីត្រៀមរត់ពេល មានសភាពការណ៍មិនស្រួល ។

តាំងពីធ្វើការនៅទីនេះរយៈពេលជាងពីរខែមក ខ្ញុំមិនដែល បានទៅលេងប្រពន្ធនិងកូនទេ ។ ក្រោយពីទទួលបានការអនុញ្ញាតពី ប្រធានមុខព្រួញ ខ្ញុំក៏ចេញដំណើរពីព្រលឹមដើម្បីទៅជួបប្រពន្ធ ។ ទៅដល់ភូមិជប់ក្រៅ ខ្ញុំបានឃើញរទេះគោក្របីនិងគាវជាច្រើន គ្រឿង ដឹករបស់របរកំប៉ិកកំប៉ុករបស់អ្នកជម្លៀស ។ ពេលទៅដល់ ខ្ញុំមិនបានជួបប្រពន្ធនិងកូនរបស់ខ្ញុំភ្លាមទេ ព្រោះប្រពន្ធខ្ញុំនាំកូនទៅ លេងឪពុកម្ដាយនៅពាមជីលាំង ។ បន្ទាប់មក ខ្ញុំបានសុំម្ចាស់ទូក ចម្លងទៅបឹងកំបោរ និងសម្រាកនៅផ្ទះឪពុកមាឈ្មោះ យាង មួយ យប់ដើម្បីរកទូកធ្វើដំណើរបន្តទៅពាមជីលាំងទៀត ។ ពេលខ្ញុំទៅ ដល់ ឪពុកក្មេកនិងប្រពន្ធខ្ញុំចេញមកទទួលខ្ញុំទាំងភ្នែកនៅកញ្ចឹងក ។ ប្រពន្ធខ្ញុំកើតជំងឺហើមពេញខ្លួនប្រាណនិងដៃជើងមើលទៅដូចជា

មនុស្សឃាត់ ។ សំណាងល្អណាស់ ខ្ញុំបានដាក់ស៊ីរ៉ាំងនិងថ្នាំអំពូលមួយចំនួនតាមខ្លួន ដូចជាថ្នាំអំពូលក័រពីគុលពីរ-បីអំពូលដែលនៅសល់តាំងពេលជម្លៀសឆ្នាំ១៩៧៣ ។ បន្ទាប់មកខ្ញុំសម្រេចចិត្តចាក់ថ្នាំនេះឲ្យប្រពន្ធខ្ញុំទាំងការមិនទុកចិត្តពីគុណភាពថ្នាំនិងគ្មានអាល់កុលសម្រាប់ជូតទៀតផង ។ ប៉ុន្តែក្រោយពេលចាក់រួចប្រពន្ធខ្ញុំក៏បានជាសះស្បើយ ។ ខ្ញុំនៅជាមួយក្រុមគ្រួសារមិនបានយូរទេ ប្រធានផ្ដាំឲ្យខ្ញុំប្រញាប់ត្រឡប់ទៅការដ្ឋានពើកវិញដើម្បីវាយសម្រុកការងារព្រោះទឹកចាប់ផ្ដើមស្រក ។ កងបុរសភ្លូរវាស់កំពុងវាយសម្រុកភ្លូរវាស់និងកៀរដីស្រែថ្មីឲ្យរាបស្មើដើម្បីស្ទូងស្រូវប្រដេញទឹក ។

ខែ១០ ឆ្នាំ១៩៧៨ នៅការដ្ឋានពើក ប្រធានមុខព្រួញខ្ញុំបានអានប្រកាសរបស់អង្គការថា អង្គការបញ្ឈប់ការចាប់និងសម្លាប់មនុស្សទៀតហើយ ។ ដូច្នេះប្រជាជនត្រូវមានសតិអារម្មណ៍នឹងនរ ហើយខិតខំវាយសម្រុកការងារ ។ ខ្ញុំត្រូវបានប្រធានមុខព្រួញ អនុញ្ញាតឲ្យទៅផ្ទះវិញ និងជួយរែកទឹកស្រោចកូនថ្នាំជាមួយឪពុកខ្ញុំ ។ ចំណែកប្រពន្ធខ្ញុំ ត្រូវបានចាត់តាំងឲ្យទៅដកស្ទូងកូនថ្នាំនៅកន្លែងខ្ញុំនៅឃុំមង់រៀវ ។ ប្រធានកងបានឲ្យកងឈ្លបដើរប្រមូលចានឆ្នាំងតាមផ្ទះ ប៉ុន្តែប្រពន្ធខ្ញុំនៅតែលួចលាក់ទុកបានសម្រាប់ដាំបាយឲ្យកូនៗហូបជានិច្ច ។ ប្រពន្ធខ្ញុំក៏នៅមានថ្នាំខ្មែរនិងថ្នាំសរសៃដូរបានស្ករនិងអំបិលហូបផងដែរ ។

ក្នុងឆ្នាំនេះនៅក្នុងសហករណ៍មានការខ្វះខាតអង្ករសម្រាប់ដាំបបរ ប្រធានរោងបាយមិនទទួលខុសត្រូវលើការមាន ឬគ្មានបបររាវហូបនោះទេ ដោយគ្រាន់តែស្រែកប្រកាសប្រាប់ប្រជាជនថាគ្មានអង្ករប៉ុណ្ណោះ ។ ប៉ុន្តែបែរជាអង្គការដឹកស្រូវចេញពីតំបន់នានាក្នុងស្រុកត្បូងឃ្មុំតាមដងទន្លេមេគង្គដើម្បីងាយស្រួលដឹកបន្តទៅត្រើយខាងលិចទន្លេវិញ ។ ទោះបីជាប្រជាជនឃើញមានស្រូវច្រើននៅទីនោះក៏ដោយ ប៉ុន្តែប្រជាជនគ្មានសិទ្ធិប៉ះពាល់ស្បៀងនេះទេ ។ នៅថ្ងៃមួយប្រជាជនក្នុងភូមិនាំគ្នាស្ងួនស្ងោនិងតក់ស្លុតចំពោះហេតុការណ៍ដែលអង្គការប្រកាសឲ្យប្រជាជនទាំងអស់ក្នុងភូមិកំពង់ឫស្សីប្រមែប្រមូលកម្មសិទ្ធរបស់ខ្លួនទាំងប៉ុន្មានយកទៅតាមខ្លួន និងប្រមូលកូនចៅទាំងអស់ទៅជួបប្រជុំនៅមុខព្រះវិហារវត្តកំពង់ឫស្សីនៅវេលាម៉ោង៨ទៀបភ្លឺ ។ អង្គការបានមានមតិលើកឡើងអំពីសភាពការណ៍នយោបាយដែលថាខ្មាំងយួនឈ្លានពានលេបទឹកដីកម្ពុជា ខ្មាំងក្បាលយួនខ្លួនខ្មែរលក់ទឹកដីឲ្យយួន ហើយអ្នកទាំងនេះដែលអង្គការកំពុងស្រាវជ្រាវរកនិងត្រូវកម្ទេចចោល ។ អង្គការមានមតិរហូតដល់ភ្លឺ ទើបប្រកាសរកឈ្មោះ៤គ្រួសារដែលអង្គការត្រូវធ្វើការជម្លៀសទៅត្រើយខាងលិចទន្លេ គឺមានក្រុមគ្រួសារ ពូកន, សំអាត, បងសាំម និងគ្រួសារមួយទៀតដែលខ្ញុំមិនចាំឈ្មោះ ។ ក្រុមគ្រួសារទាំង៣បានចេញបង្ហាញមុខនៅចំពោះអង្គការ ប៉ុន្តែមួយគ្រួសារទៀត គឺក្រុមគ្រួសារ សំអាត មិនគោរពតាមបទបញ្ជារបស់អង្គការនាំគ្នារត់ចេញពីអង្គប្រជុំទៅផ្ទះ ។ ក្រុមយោធាបានតាមចាប់ក្រុមគ្រួសារនេះ រួចដាក់លើរទេះសេះដឹកជញ្ជូនទៅកាន់ទន្លេបិទមុន ចំណែក៣គ្រួសារទៀតបញ្ជូនទៅតាមក្រោយ ។ បន្ទាប់ពីដឹកជញ្ជូនក្រុមគ្រួសារទាំងបួននេះទៅផុត អង្គការបានបញ្ជាឲ្យប្រជាជនបំបែកជួររិលទៅកន្លែងធ្វើការវិញតាមធម្មតា ។ បទបញ្ជារបស់អង្គការនេះ បានបន្ធូរអារម្មណ៍លំបាកវេទនារបស់ប្រជាជនភូមិកំពង់ឫស្សីបានមួយគ្រា ។ ចំណែកប្រជាជន៤គ្រួសារដែលអង្គការដឹកទៅបានទៅដល់ត្រឹមភូមិដីរេកណ្ដាលដែលជាទីតាំងកងធំ ក៏ត្រូវបានអនុគ្រោះឲ្យត្រឡប់មកផ្ទះសិន ដោយសារប្រជាជនជម្លៀសនៅកកកុញត្រង់កំពង់ចម្លងច្រើនពេក ។

## ការបះបោរប្រឆាំងនឹង ប៉ុល ពត

ព្រឹកមួយពេលខ្ញុំកំពុងតែរែកទឹកស្រោចកូនថ្នាំ ស្រាប់តែឮសំឡេងយន្តហោះធុនតេ-២៨ ដែលប្រជាជនហៅថា អាស្ទាបកាត់ចំនួនពីរគ្រឿងបានហោះយ៉ាងទាបពីលើក្បាលខ្ញុំសំដៅទៅទិសខាងកើត ហើយមួយសន្ទុះក្រោយមកយន្តហោះទាំងពីរគ្រឿងបានវិលត្រឡប់ពីកើតទៅលិចវិញ ។ ពេលនោះស្រាប់តែខ្ញុំឃើញយន្តហោះចម្បាំងមួយគ្រឿងហោះយ៉ាងខ្ពស់និងសំយុងក្បាលបោះពួយចុះក្រោមត្រង់កំពង់ចម្លងទន្លេបិទ និងមានស្នូររញ្ជួយគ្រាប់បែកផ្ទុះញ័ររកក្រើកដី ។ ប៉ុន្តែទោះបីមានសភាពការណ៍កក្រើកយ៉ាងនេះក្ដី ក៏ប្រជាជនភូមិកំពង់ឫស្សីនៅតែបន្តការងាររបស់ខ្លួនតាមមុខព្រួញនីមួយៗមិនហ៊ាននិយាយស្ដីអ្វីឡើយ ។ ខ្ញុំចងចាំជានិច្ចនៅថ្ងៃកើតហេតុនេះគឺចំថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៨ ព្រោះចាប់ពីម៉ោង៣រសៀលទៅ ខ្ញុំឃើញប្រជាជនជាច្រើនរយ

គ្រួសារបររទេះគោក្របី រទេះជើងគុល គាវ ក្រែ ទូ ដឹកក្រុមគ្រួសារនៅតាមផ្លូវមាត់ទន្លេពីទន្លេបិទដល់កំពង់ឬស្សីឆ្ពោះទៅកាន់ថ្មពេជ្របន្តកន្ទុយគ្នាលាតសន្ធឹងរហូតដល់ភូមិពើក ។ អ្នកទាំងនោះជាប្រជាជនជម្លៀសដែលប្រមូលមកពីមូលដ្ឋាននានាក្នុងស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ ដែលអ្នកតស៊ូកំពុងវាយដណ្តើមកាន់កាប់ដើម្បីជម្លៀសប្រជាជនទៅភូមិភាគខាងលិចទន្លេវិញ ។ ប៉ុន្តែដោយយន្តហោះចម្បាំងបានវាយប្រហារស្រឡាងលិចអស់បណ្តាលឲ្យប្រជាជនជម្លៀសទាំងអស់ដែលកំពុងរង់ចាំស្រឡាង បាត់ភាពម្ចាស់ការ ។

នៅយប់ថ្ងៃនោះគណៈកងតូចដូចជាដឹងពីបរាជ័យរបស់ខ្លួនក៏បានបញ្ជាឲ្យចុងភៅប្រមែប្រមូលអង្ករដែលនៅសល់ប៉ុន្មានដាំបាយឲ្យប្រជាជនបានហូបឆ្អាញ់មួយពេល ។ ក្រោយពីហូបបាយរួចមួយសន្ទុះស្រាប់តែមានយោធាប៉ុលពតបាក់ទ័ពប្រមាណជា ៥០នាក់ បានមកជួបគណៈកងតូចរួចស្នើសុំបាយហូប ។ គណៈកងតូចភ័យស្លន់ស្លោក៏រត់ត្រហេបត្រហបមកដាំបាយឲ្យយោធាទាំងនោះ ។ ខ្ញុំនិងបុរសប្រមាណ១០នាក់នៅក្នុងភូមិបានទទួលការចាត់តាំងពីគណៈកងតូចឲ្យយាមរោងបាយនៅយប់នោះ ។

ព្រឹកឡើងប្រជាជនកំពង់ឬស្សីទាំងអស់ក៏នាំគ្នាប្រមែប្រមូលកម្មសិទ្ធិដែលមានបន្តិចបន្តួច ដូចជា រទេះគោ ជើងគុល និងគាវដឹកជញ្ជូនកូនចៅក្រុមគ្រួសារសំដៅទៅទិសខាងកើតតាមក្បួនរបស់អ្នកជម្លៀសពីទន្លេបិទ ។ ប្រពន្ធខ្ញុំបានត្អូញត្អែរថា មិនស្រួលខ្លួនគ្មានកម្លាំងកំហែងមិនព្រមធ្វើដំណើរទៅទេ ។ ប៉ុន្តែដោយមានការអង្វរ-ករពីខ្ញុំ និងការដាស់តឿនពីអ្នកជិតខាង ប្រពន្ធរបស់ខ្ញុំក៏យល់ព្រម ។ ប្រពន្ធខ្ញុំប្រមូលបានជាលក្អែកក្រួចពីរយកមកចងរុំប្រទាក់ឆ្វាក់ឲ្យណែនសម្រាប់ឲ្យខ្ញុំរែកជាលមួយដាក់អង្ករចានឆ្នាំងនិងជាលមួយទៀតដាក់កូនស្រីអាយុ១០ខែ ។ ចំណែកប្រពន្ធខ្ញុំ ទូលល្អីដាក់សម្លៀកបំពាក់និងរបស់របរប្រើប្រាស់មួយចំនួន ហើយដឹកដៃកូនប្រុសស្រីទាំងពីរ ។ ធ្វើដំណើរជាក្បួនដូច្នេះ ទាំងអស់គ្នាដូចជាមិនមានការភ័យខ្លាចអ្វីប៉ុន្មានទេ ។ បន្ទាប់មកខ្ញុំបានទៅសម្រាកហូបបាយនៅផ្ទះបងប្អូននៅភូមិទួលដំបង រួចបន្តដំណើរតាមផ្លូវទៅកើតកាត់តាមព្រែកឆ្កែកូន ។ យើងមិនមានទូកសម្រាប់ឆ្លងទេមានតែយករបស់របរនិងលើកកូនឲ្យផុតពីទឹកត្រឹមទ្រូងរួចដើរឆ្លងទៅត្រើយខាងកើតព្រែកឆ្កែកូន ដើម្បីបន្តដំណើរទៅភូមិពើកទៀត ។ ជួនពេលនោះមានយោធាខ្មែរក្រហមប្ដូនប្រាំនាក់ដែលមានកាន់អាវុធគ្រប់ដៃ ហើយមានបំណងឆ្លងព្រែកឆ្កែកូននេះទៅទិសខាងលិចវិញ បានគំរាមលើកកាំភ្លើងតម្រង់ប្រុងបាញ់ខ្ញុំនិងប្រពន្ធឲ្យគេចចេញ ។ ខ្ញុំតក់ស្លុតយ៉ាងខ្លាំងក៏បានស្ទុះរែកសង្រែកឱនត្រុនៗទៅមុខយ៉ាងលឿនចោលប្រពន្ធនិងកូនពីរនាក់ដែលកំពុងដើរមួយៗតាមពីក្រោយ ។

ធ្វើដំណើរអស់ពេលយ៉ាងយូរ ក្រុមគ្រួសារខ្ញុំបានទៅដល់ភូមិចាស់មួយដែលគេបោះបង់ចោល ដែលនៅទីនោះមានដើមស្វាយធំៗជាម្លប់អាចឲ្យពួកយើងចូលជ្រកបាន ។ នៅទីនោះមិនមែនមានតែគ្រួសារខ្ញុំទេ នៅមានបងប្អូនប្រជាជនជាច្រើនទៀតដែលមកពីកំពង់ឬស្សីជាមួយគ្នាដែរ ។ ខ្ញុំទៅកើបស្រូវបានមួយល្អីយកមកបុកដាំបាយ ។ ខ្ញុំសម្រាកនៅទីនេះបានមួយយប់ ព្រឹកឡើងបន្តរែកសង្រែកទៅឈប់នៅភូមិពើក ព្រោះនៅទីនោះខ្ញុំមានបងប្អូនជាប្រជាជនមូលដ្ឋាន ។ ពីរថ្ងៃក្រោយមកទៀត ខ្ញុំបានរួមដំណើរជាមួយប្រពន្ធរបស់បងប្រុសខ្ញុំនិងក្រុមគ្រួសារគាត់ទៅរកប្រូតស្រូវនៅតាមបណ្តោយផ្លូវទៅឃុំសួង ដែលតំបន់ទាំងនោះស្ថិតក្នុងស្រុកត្បូងឃ្មុំ ត្រូវបានរំដោះទាំងស្រុងតាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៩ម្ល៉េះ ។

ខ្ញុំនិងប្រពន្ធប្រូតកាត់បោកបែនស្រូវបានពីររទេះគោក៏ឈប់ព្រោះគិតថាស្រូវនេះគ្រប់គ្រាន់អាចដោះស្រាយបញ្ហាក្រពះបានមួយឆ្នាំហើយ ។ ខ្ញុំនិងប្រពន្ធក៏ឆ្លៀតពេលចូលសាកសួរសុខទុក្ខញាតិមិត្តនិងអ្នកធ្លាប់ស្គាល់នៅឯទីប្រជុំជនសួងដែរ ។ គ្រប់គ្រួសារទាំងអស់ពុំមានគ្រួសារណាមួយដែលថាគ្មានកូនចៅរួចផុតពីការកាប់សម្លាប់របស់ពួកប្រល័យពូជសាសន៍ប៉ុលពតឡើយ ។

ក្រោយពីប្រទេសជាតិបានសុខសន្តិភាព ខ្ញុំនិងប្រពន្ធបានត្រឡប់ទៅរស់នៅឯភូមិកំណើតនៅភូមិកំពង់ឬស្សី ឃុំជីរោទ៍១ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមវិញ ដោយប្រកបមុខរបរជាកសិករ ។ បន្ទាប់មកទៀត ខ្ញុំធ្វើជាគណៈឃុំបឹងព្រួល គណៈឃោសនាអប់រំស្រុកត្បូងឃ្មុំ និងជាប្រធានមន្ទីរស្រុក ។ បច្ចុប្បន្នខ្ញុំមានមុខតំណែងជាអភិបាលស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ **ភី ប៊ុនថាន់**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧**

## សេចក្ដីប្រកាសព័ត៌មាន

ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០៧ នួន ជា ត្រូវបាននាំខ្លួនមកកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមដីកាបង្គាប់ឲ្យនាំខ្លួន។ ការចូលបង្ហាញខ្លួនលើកដំបូងនឹងប្រព្រឹត្តិធ្វើឡើងនាថ្ងៃនេះ ហើយនាពេលជាមួយគ្នាផងដែរ គាត់នឹងត្រូវបានប្រាប់ឲ្យដឹងអំពីបទចោទប្រកាន់ទៅលើរូបគាត់។

សេចក្ដីប្រកាសព័ត៌មានពិស្ដារនឹងធ្វើឡើងនាពេលដ៏ខ្លីខាងមុខ។

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## លិខិតជូនព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត

នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៧ នេះ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញបានដាក់ ឈ្មោះ **នួន ជា** អោយស្ថិតនៅ ក្រោមការត្រួតពិនិត្យចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម និង បានសម្រេចឃុំខ្លួនជននេះ ជាបណ្ដោះអាសន្ន។

ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននឹងដាក់ផ្សាយ នៅលើគេហទំព័ររបស់តុលាការនាពេលខាងមុខ: http://www.eccc.gov.kh

## ដំណឹងសួររកបងស្រី

*នាងខ្ញុំឈ្មោះ យូ សៀមអេង អាយុ៥៨ឆ្នាំ (ឪពុកឈ្មោះ យូ ប៉េងស៊ា និងម្ដាយឈ្មោះ វ៉ាន់ សាវុន) និងស្វាមីឈ្មោះ ប៉ាន់ ជឿន អាយុ៦១ឆ្នាំ ដែលពីមុនរស់នៅភូមិខ្សា ឃុំដា ស្រុកក្រចេះ ខេត្តក្រចេះ ហើយបច្ចុប្បន្នរស់នៅភូមិជើងស្ពឺង ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប សូមសួររកបងស្រីឈ្មោះ យូ សៀមចេង និងស្វាមីឈ្មោះ ជឹង ហាំងវេង មុនឆ្នាំ១៩៧៥ គាត់ទាំងពីររស់នៅទីក្រុងភ្នំពេញហើយត្រូវអង្គការជម្លៀសទៅខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៧៥ ក្រោយមកទើបឮដំណឹងថាប្ដីគាត់ស្លាប់ នៅសល់តែកូននិងបងស្រីខ្ញុំប៉ុណ្ណោះ។ នៅឆ្នាំ១៩៧៩ ឮដំណឹងថាគាត់នៅទឹកថ្លាទីក្រុងភ្នំពេញ តែក្រោយមកបាត់ដំណឹងសូន្យឈឹងតែម្ដង។*

*សូមមេត្តាផ្ដល់ដំណឹងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ឬតាមរយៈទូរស័ព្ទលេខ (៨៥៥) ១២ ៣៧២ ៥៤១ ឬ (៨៥៥) ៩២ ២៥៣ ៧៧០ ។ សូមអរគុណ!*



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 93, September 2007 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.